**ចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

**សំណុំរឿងលេខ** : ០០២/១៩-០៩-២០០៧-អវតក/អជតក
**ដាក់ទៅ** : អង្គជំនុំជម្រះតុលាការកំពូល
**ថ្ងៃដាក់** : ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៤
**ភាគីអ្នកដាក់** : សហព្រះរាជអាជ្ញា
**ភាសាដើម** : អង់គ្លេស

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 28-Nov-2014, 14:06
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

**ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ:** សាធារណៈ

**ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះតុលាការកំពូល:** សាធារណៈ/Public

**ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:**

**ការពិនិត្យចំណាត់ថ្នាក់ឯកសារបណ្ដោះអាសន្នឡើងវិញ:**

**ឈ្មោះមន្ត្រីដែលបានពិនិត្យ:**

**ហត្ថលេខា:**

---

# បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿងលេខ០០២/០១

---

**អ្នកដាក់ឯកសារ:**

**សហព្រះរាជអាជ្ញា:**
លោកស្រី ជា លាង
លោក Nicholas KOUMJIAN

**អ្នកទទួលឯកសារ:**

**អង្គជំនុំជម្រះតុលាការកំពូល:**
ចៅក្រម គង់ ស្រីម, ប្រធាន
ចៅក្រម A. KLONOWIECKA-MILART
ចៅក្រម សោម សិរីវឌ្ឍ
ចៅក្រម C.N. JAYASIINGHE
ចៅក្រម ម៉ុង មុន្នីចរិយា
ចៅក្រម យ៉ា ណារិន
ចៅក្រម Florence Ndepele MUMBA

**ចម្លងជូន:**

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី:**
លោក ពេជ អង្គ
លោកស្រី Marie GUIRAUD

**ជនជាប់ចោទ:**
នួន ជា
ខៀវ សំផន

**មេធាវីការពារក្តីជនជាប់ចោទ:**
លោក សុន អរុណ
លោក Victor KOPPE
លោក គង់ សំអុន
លោកស្រី Anta GUISSÉ
លោក Arthur VERCKEN

# I. សេចក្តីផ្តើម

1. ដោយអនុលោមតាមវិធាន១០៤, ១០៥, ១០៦, ១០៧ និង ១០៨(១)[1] សហព្រះរាជអាជ្ញាសូមដាក់បណ្តឹងសាទុក្ខនេះជូនទៅអង្គជំនុំជម្រះតុលាការកំពូល (“អង្គជំនុំជម្រះ”) ប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿង០០២/០១[2]។ បណ្តឹងសាទុក្ខនេះមានមូលដ្ឋានផ្អែកលើទឡ្ហីករណ៍ដែលថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសលើអង្គច្បាប់ ដោយបានដកចេញនូវលទ្ធភាព[3] ដែលជនជាប់ចោទ ក្នុងឋានៈជាមេដឹកនាំជាន់ខ្ពស់នៃកម្ពុជាប្រជាធិបតេយ្យ[4] អាចនឹងត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ ចំពោះផលវិបាកនៃឧក្រិដ្ឋកម្មផ្សេងៗដែលបានប្រព្រឹត្តដោយពួកចារីដៃដល់ ដោយផ្អែកលើសារៈសំខាន់នៃការចូលរួមចំណែករបស់ជនជាប់ចោទ ក្នុងសហឧក្រិដ្ឋកម្មរួម (“JCE”) នៅក្នុងកាលៈទេសៈដែលជនជាប់ចោទអាចប្រមាណបានយ៉ាងសមហេតុសមផលថា ឧក្រិដ្ឋកម្មទាំងនោះមិនត្រូវបានដាក់បញ្ចូលក្នុងវិសាលភាពនៃសហកម្ម ដែលអាចនឹងត្រូវបានប្រព្រឹត្តយ៉ាងជាក់លាក់។

## II. ប្រវត្តិនីតិវិធី

2. ការទទួលយកតាម និងការបញ្ជាក់អះអាងលើសេចក្តីសម្រេចមួយពីមុនរបស់អង្គបុរេជំនុំជម្រះ[5] ដែលអង្គបុរេជំនុំជម្រះ បានច្រានចោលនូវសេចក្តីសម្រេចរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត (“កសចស”) ដែលថាសហឧក្រិដ្ឋកម្មរួមក្នុងទម្រង់ទី III (JCE III) ជាផ្នែកមួយនៃច្បាប់ទម្លាប់អន្តរជាតិនៅមុនឆ្នាំ១៩៧៥ ហើយសហឧក្រិដ្ឋកម្មរួមក្នុងទម្រង់ទីIIIនេះអាចអនុវត្តបាននៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“អវតក”)[6]។ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា ជនជាប់ចោទទាំងពីរនាក់អាចប្រឈមមុខនឹងការចោទប្រកាន់ខាងព្រហ្មទណ្ឌចំពោះបទល្មើសនានា ដែលបានប្រព្រឹត្ត ក្នុងសហឧក្រិដ្ឋកម្មរួម (JCE) ណាមួយ តែក្នុង ករណី

---

[1] អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា, វិធានផ្ទៃក្នុង (វិសោធនកម្មលើកទី៨), បានធ្វើវិសោធនកម្មនៅថ្ងៃទី៣ សីហា ២០១១ (“វិធាន”)។

[2] **E313** សាលក្រម, ៧ សីហា ២០១៤ (“សាលក្រម”)។

[3] **E313** *ដដែលដូចខាងលើ*, ត្រង់កថាខណ្ឌ៦៩១។

[4] **E313** *ដដែលដូចខាងលើ*, ត្រង់កថាខណ្ឌ១៣-១៤។

[5] **D97/15/19** សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតស្តីពីសហឧក្រិដ្ឋកម្មរួម, ២០ ឧសភា ២០១០ (“សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ”)។

[6] **D97/13** ដីកាសម្រេចស្តីពីការអនុវត្តន៍នៅ អវតក នូវទម្រង់នៃការទទួលខុសត្រូវខាងព្រហ្មទណ្ឌដែលគេហៅថា សហឧក្រឹដ្ឋកម្មរួម (JCE), ៨ ធ្នូ ២០០៩។

ដែលជនជាប់ចោទបានចូលរួមចំណែកយ៉ាងសកម្មក្នុងសហាកម្ម ហើយឧក្រិដ្ឋកម្មទាំងនោះត្រូវបានបញ្ជាក់ច្បាស់ក្នុងបរិបទនៃសហាកម្មនោះ ("សហឧក្រិដ្ឋកម្មរួម ក្នុងទម្រង់ទីI (JCE I)") ឬ ទាំងចេតនារួមចំណែកប្រព្រឹត្តឧក្រិដ្ឋកម្ម អាចទាញសេចក្តីសន្និដ្ឋានចេញមកពីការចូលរួមចំណែករបស់ពួកគាត់នៅក្នុងការគ្រប់គ្រងជាប្រព័ន្ធមួយដែលប្រព្រឹត្តអំពើអមនុស្សធម៌ ("សហឧក្រិដ្ឋកម្មរួមក្នុងទម្រង់ទី II -JCE II")[7]។

3. យ៉ាងណាក៏ដោយ អង្គជំនុំជម្រះសាលាដំបូង ជាថ្មីម្តងទៀត បានទទួលយកការវិភាគរបស់អង្គបុរេជំនុំជម្រះ ដោយមិនអនុញ្ញាតឱ្យមានការចោទប្រកាន់លើជនជាប់ចោទ ក្រោមទម្រង់មួយនៃការចូលរួមចំណែក ដែលនឹងតម្រូវឱ្យពួកគាត់ឱ្យទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនានា ដែលបានប្រព្រឹត្តតាមរូបភាពការជួយជ្រោមជ្រែង ក្នុងសហឧក្រិដ្ឋកម្មរួម(JCE) ដែលអំពើរអាចព្យាករណ៍បានប្រកបដោយហេតុផល ក៏ប៉ុន្តែមិនចាំបាច់មានចេតនាក្នុងការប្រព្រឹត្តឡើយ ("សហឧក្រិដ្ឋកម្មរួមក្នុងទម្រង់ទីIII- JCE III")។ ចាកឆ្ងាយពីសេចក្តីសម្រេចដែលមានលក្ខណៈស្របគ្នារបស់តុលាការអន្តរជាតិ និងតុលាការអន្តរជាតូបនីយកម្មដទៃទៀត ដែលបានយល់ឃើញថាមានការទទួលខុសត្រូវខាងព្រហ្មទណ្ឌដូចគ្នា នៅក្នុងសំណុំរឿងនានា នៅក្រោយសង្គ្រាមលោកលើកទី II (សំណុំរឿងក្តីសង្គ្រាមលោកលើកទីII)[8]។ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថាការទទួលខុសត្រូវនៃសហឧក្រិដ្ឋកម្មរួមក្នុងទម្រង់ទីIII- JCE III គឺមិនខ្លួនឯងជាអ្នកបង្កើតជាទម្រង់មួយនៃការទទួលខុសត្រូវ តាមរយៈករណីរឿងក្តីទាំងនោះទេ[9]។ ផ្អែកលើការស្ទង់មតិមួយលើប្រព័ន្ធតុលាការក្នុងស្រុករបស់ប្រទេសចំនួនប្រាំពីរ ក្រោយសង្គ្រាមលោកលើកទីII អង្គជំនុំជម្រះក៏បានរកឃើញថាកង្វះភាពស៊ីសង្វាក់គ្នាក្នុងការហាមប្រាមនូវអំពើឧក្រិដ្ឋ ដែលអាចព្យាករណ៍ប្រកបដោយហេតុផលបានផាត់ចោលនូវលទ្ធភាពដែលថា សហឧក្រិដ្ឋកម្មរួមក្នុងទម្រង់ទីIII -JCE III គឺជាគោលការណ៍ច្បាប់ទូទៅ មួយដែលត្រូវបានទទួលស្គាល់ដោយប្រជាជាតិនានា ដែលមានអរិយធម៌ល្អគួរសម[10]។

---

[7] **E100/6** សេចក្តីសម្រេចលើភាពអាចអនុវត្តបាននូវសហឧក្រិដ្ឋកម្មរួម, ១២ កញ្ញា ២០១១ ("សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង")។

[8] ដូចដែលអង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTR បានថ្លែងយ៉ាងច្បាស់សាស់ថា៖ "... វាពុំមានចម្ងល់ណាមួយទាល់តែសោះដែលថាការទទួលខុសត្រូវជា JCE ប្រភេទទីបី ត្រូវបានទទួលយកយ៉ាងតឹងរ៉ឹងនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ"។ *សូមអាន ឧ.ទា. Édouard Karemera និងគូកន ទល់នឹង រដ្ឋអាជ្ញា,* សំណុំរឿងលេខ ICTR-98-44-AR72.5, ICTR-98-44-AR72.6, សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ស្តីពីបញ្ញាយុត្តាធិការ៖ សហឧក្រិដ្ឋកម្មរួម (អង្គជំនុំជម្រះឧទ្ធរណ៍), ១២ មេសា ២០០៦ ត្រង់កថាខណ្ឌទី១៣។

[9] **E100/6** សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងអំពីការអនុវត្តបាននូវសហឧក្រិដ្ឋកម្មរួម, ថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១១ "សេចក្តីសម្រេចរបស់អង្គជំនុំជម្រះ" ត្រង់កថាខណ្ឌទី៣១ និង៣៥។

[10] **E100/6** សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងអំពីការអនុវត្តបាននូវសហឧក្រិដ្ឋកម្មរួម, ថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១១ "សេចក្តី

អង្គជំនុំជម្រះសាលាដំបូងបានកំណត់យ៉ាងជាក់លាក់ថា ការដាក់ឱ្យជនជាប់ចោទទទួលខុសត្រូវនៅក្រោមសហឧក្រិដ្ឋកម្មរួមទម្រង់ទីIII នឹងបំពានលើគោលការណ៍ច្បាប់ស្តីពី ( *គ្មានច្បាប់ចែងគ្មានបទល្មើស*)[11]។

4. ដូចដែលសហព្រះរាជអាជ្ញាធ្វើការបង្ហាញខាងក្រោមនេះ ការបដិសេធមិនពិចារណាអំពីការទទួលខុសត្រូវជាក្នុងរូបភាពសហឧក្រិដ្ឋកម្មរួមទម្រង់ទី III (JCE III) នោះគឺជាកំហុសលើអង្គច្បាប់។ លក្ខខណ្ឌតម្រូវចាំបាច់ស្តីពី "ការប្រព្រឹត្តិ" ដើម្បីបង្កើតឱ្យបានជាសហឧក្រិដ្ឋកម្មរួមទម្រង់ទី III (JCE III) គឺមានលក្ខណៈដូចគ្នាទៅនឹងការប្រព្រឹត្តិដែលតម្រូវឱ្យមាន សម្រាប់សហឧក្រិដ្ឋកម្មរួមទម្រង់ទីI (JCE I) ដែរ និងដូច្នេះហើយ ផ្អែកតាមតក្កវិទ្យាដូចជាមិនស៊ីសង្វាក់គ្នាទាល់តែសោះក្នុងការសម្រេចថាសហឧក្រិដ្ឋកម្មរួមទម្រង់ទីI មិនបំពានលើគោលការណ៍ស្តីពីនីត្យានុកូលភាព ក៏ប៉ុន្តែថា សហឧក្រិដ្ឋកម្មរួមទម្រង់ទីIII បំពានលើគោលការណ៍នេះទៅវិញ។ ជាងនេះទៀតការពន្លាតការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនៃសមាជិកនានានៃសហឧក្រិដ្ឋកម្មរួម (JCE) នៅក្រៅផែនការរួម ប៉ុន្តែជាអំពើដែលអាចព្យាករណ៍ទុកជាមុនបានប្រកបដោយហេតុផល គឺត្រូវបង្កើតឡើងយ៉ាងត្រឹមត្រូវនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅមុនឆ្នាំ១៩៧៥។

5. ដើម្បីឱ្យមានភាពច្បាស់លាស់ ពាក្យថា "អាចប្រមើលឃើញជាមុនបានប្រកបដោយហេតុផល" នៅក្នុងបណ្តឹងសាទុក្ខនេះ គឺសំដៅទៅលើលក្ខខណ្ឌច្បាប់ទាំង២ជាអត្តនោម័ត-សត្យានុម័តនៃសហឧក្រិដ្ឋកម្មទម្រង់ទីIII ដែលកត្តា*ទាំងពីរ*តម្រូវថា៖ (ក) ការប្រព្រឹត្តឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ ត្រូវតែជាផលវិបាកពិតប្រាកដ និងអាចប្រមើលឃើញជាមុនបាន នៃការប្រព្រឹត្តសហឧក្រិដ្ឋកម្មរួម ("ភាពអាចប្រមើលឃើញជាមុនបានជាសត្យានុម័ត")[12] (ខ) ជនជាប់ចោទបានទទួលយកហានិភ័យនេះដោយចេតនា ដែលអាចនិយាយម្យ៉ាងទៀតបានថា ជនជាប់ចោទ (i) មានការដឹងមុនជាអត្តនោម័ត (នៅក្នុងញាណនៃការយល់ដឹង) ពីភាពអាចប្រមើលឃើញជាមុនបានជា

---

សម្រេចរបស់អង្គជំនុំជម្រះ" ត្រង់កថាខណ្ឌទី៣៧-៣៨។។

[11] **E100/6** សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងអំពីការអនុវត្តបានទូវសហឧក្រិដ្ឋកម្មរួម, ថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១១ "សេចក្តីសម្រេចរបស់អង្គជំនុំជម្រះ" ត្រង់កថាខណ្ឌទី២៦។

[12] រដ្ឋអាជ្ញា ទល់នឹង *Tihomir Blaškić* សំណុំរឿងលេខ IT-95-14-A, សាលដីកា (អង្គជំនុំជម្រះសាលាឧទ្ធរណ៍) ចុះថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០០៤ ("សាលដីកាក្នុងសំណុំរឿង *Blaškić*") ត្រង់កថាខណ្ឌ ៣៣។ រដ្ឋអាជ្ញា ទល់នឹង . *Ramush Haradinaj និងជនជាប់ចោទដទៃទៀត* សំណុំរឿងលេខ IT-04-84-T, សាលក្រម (អង្គជំនុំជម្រះសាលាដំបូង I) ចុះថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០០៨ ត្រង់កថាខណ្ឌ ១៣៧-១៣៨។

សត្យានុម័តនៃឧក្រិដ្ឋកម្មនេះ និង (ii) បានទទួលយកហានិភ័យនេះដោយចេតនាដែលថា ឧក្រិដ្ឋកម្មនេះអាចនឹងត្រូវបានប្រព្រឹត្តឡើង ("ការធ្វេសប្រហែសដោយការដឹងជាមុន (*advertent recklessness*)" ដែលអាចប្រៀបធៀបបានជិតបំផុតទៅនឹងការដឹងជាមុនអំពីលទ្ធផល ដែលទំនងនឹងកើតមានឡើង (*dolus eventualis*))[13]។

## III. ភាពអាចទទួលយកបាន

6. អង្គជំនុំជម្រះនេះបានសម្រេចនៅក្នុងសំណុំរឿង០០១ ថាខ្លួនអាចទទួលកំហុសលើអង្គច្បាប់ ដែលត្រូវបានចោទប្រកាន់អំពី "សារៈសំខាន់ជាទូទៅសម្រាប់យុត្តិសាស្ត្រ"[14] សូម្បីតែ កំហុសទាំងនោះមិននាំឱ្យមោឃៈសាលក្រមដោយខ្លួនឯងក៏ដោយ។ នេះជាមូលដ្ឋានឈរលើជំហរខ្លួនឯង សម្រាប់ភាពទទួលយកបាននៃបណ្តឹងសាទុក្ខ ដែលត្រូវបង្កើតឡើងយ៉ាងត្រឹមត្រូវនៅក្នុងវិធាននីតិវិធីអន្តរជាតិ[15] ហើយបានប្រតិបត្តិដោយឯករាជ្យលើការពិនិត្យឡើងវិញជាធម្មតា នូវកំហុសលើអង្គច្បាប់នៅក្រោមវិធាន១០៤នៃវិធានផ្ទៃក្នុង។ ជាងនេះទៀត វិធាន១០៥(៣)នៃវិធានផ្ទៃក្នុង ចែងថាភាគីមួយដែលប្តឹងសាទុក្ខពីកំហុសលើអង្គច្បាប់មួយនៅក្នុងសាលក្រមមួយត្រូវតែ "បញ្ជាក់ពីកំហុសអង្គច្បាប់ ដែលបានប្តឹងនាំឱ្យមោឃៈ*សេចក្តីសម្រេចនោះ*"។ គួរឱ្យកត់សម្គាល់ថាវិធានផ្ទៃក្នុងមិនតម្រូវថាកំហុសអង្គច្បាប់ដែលបានប្តឹងធ្វើឱ្យសាលក្រមមោឃៈទេ ក៏ប៉ុន្តែអាចធ្វើឱ្យសេចក្តីសម្រេចមោឃៈ។ ដូច្នេះ អង្គជំនុំជម្រះនេះអាចនឹងពិនិត្យឡើងវិញ និងកែតម្រូវកំហុសនានា*ដែលអាចកើតមានឡើង* លើអង្គច្បាប់ទាំងនោះ ដែលបានលើកឡើងជាបញ្ហានានាអំពី "សារៈសំខាន់ទូទៅ" សូម្បីតែការសម្រេចបញ្ចប់នៅក្នុងសាលក្រមមួយរបស់អង្គជំនុំជម្រះសាលាដំបូង ដោយផ្អែកលើនិយាមផ្លូវច្បាប់ត្រឹមត្រូវក៏ដោយ។

---

[13] រដ្ឋអាជ្ញា ទល់នឹង *Milan Martić* សំណុំរឿងលេខ IT-95-11-A, សាលដីកា (អង្គជំនុំជម្រះសាលាឧទ្ធរណ៍) ចុះថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០០៨ ត្រង់កថាខណ្ឌ ៨៣។ រដ្ឋអាជ្ញា ទល់នឹង *Milomir Stakić* សំណុំរឿងលេខ IT-97-24-A, សាលដីកា (អង្គជំនុំជម្រះសាលាឧទ្ធរណ៍) ចុះថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០០៦ ត្រង់កថាខណ្ឌ ១០១។ រដ្ឋអាជ្ញា ទល់នឹង *Miroslav Kvočka និងជនជាប់ចោទផ្សេងទៀត* សំណុំរឿងលេខ IT-98-30/1-A, សាលដីកា (អង្គជំនុំជម្រះសាលាឧទ្ធរណ៍) ចុះថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០០៥ ត្រង់កថាខណ្ឌ ៨៣។ រដ្ឋអាជ្ញា ទល់នឹង *Fatmir Limaj និងជនជាប់ចោទផ្សេងទៀត* សំណុំរឿងលេខ IT-03-66-T, សាលក្រម (អង្គជំនុំជម្រះសាលាដំបូង II) ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៥ ត្រង់កថាខណ្ឌ ៥១១។

[14] សំណុំរឿងលេខ**001-F28** សាលដីកាសម្រេចលើបណ្តឹងសាទុក្ខ ត្រង់កថាខណ្ឌទី១៥។

[15] សូមអាន *នៅខាងក្រោម,* កថាខណ្ឌទី៧-៨។

7. អង្គជំនុំជម្រះសាលាឧទ្ធរណ៍ទាំងពីរ នៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ("ICTY") និងតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា ("ICTR") មានអំណាចពេញលេញក្នុងការប្រកាសច្បាប់ជាធរមានលើបញ្ហានានាស្តីពី "សារៈសំខាន់ជាទូទៅ" បើទោះជាគ្មានមូលហេតុដែលនាំឲ្យមោឃៈសាលក្រម អង្គជំនុំជម្រះសាលាដំបូង[16] ហើយគ្រាន់តែ "មានបណ្តឹងសាទុក្ខមួយដែលផ្អែកតែលើមូលដ្ឋានមួយគត់ គឺសារៈសំខាន់ជាទូទៅ"[17]។ នៅក្នុងករណីរបស់ *Akayesu* អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTR បានសម្រេចថា ៖

> *ការពិចារណាលើបញ្ហាមួយស្តីពីសារៈសំខាន់ជាទូទៅ មានលក្ខណៈសមស្របដោយសារតែ ដំណោះស្រាយរបស់វាមានភាពសំខាន់ ចំពោះការវិវឌ្ឍន៍នៃយុត្តិសាស្ត្ររបស់តុលាការ និងដោយសារតែបញ្ហាមួយត្រង់កន្លែងនេះ គឺជាចំណុចសំខាន់មួយរបស់ច្បាប់ ដែលសាកសមសម្រាប់ការពិនិត្យឡើងវិញ[18] ។ តាមពិតទៅ អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ត្រូវតែផ្តល់នូវសេចក្តីណែនាំដល់អង្គជំនុំជម្រះសាលាដំបូងនានា នៅក្នុងការបកស្រាយច្បាប់[19] ។ តុលាការរួមចំណែកដល់ការវិវឌ្ឍន៍ទូទៅនៃច្បាប់មនុស្សធម៌អន្តរជាតិ និងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ។ និយមន័យបែបមួយនេះត្រូវតែមានលក្ខណៈឯកភាពគ្នា។ ជាលទ្ធផល អង្គជំនុំជម្រះសាលាឧទ្ធរណ៍យល់ថាក្នុងការសម្រេចកន្លងមក ចូលដល់បញ្ហាមួយស្តីពីសារៈសំខាន់ជាទូទៅ អង្គជំនុំជម្រះសាលាឧទ្ធរណ៍កំពុងដើរតួនាទីរបស់ខ្លួនក្នុងការធ្វើឲ្យច្បាប់មានឯកភាព[20] ។*

---

[16] *រដ្ឋអាជ្ញា ទល់នឹង Stanislav Galić,* សំណុំរឿងលេខ IT-98-29-A, សាលដីកា, ៣០ វិច្ឆិកា ២០០៦ ត្រង់កថាខណ្ឌទី៦ ("សាលដីកាលើសំណុំរឿងរបស់ *Galić*")។ *រដ្ឋអាជ្ញា ទល់នឹង Milomir Stakić,* សំណុំរឿងលេខ IT-97-24-A, សាលដីកា, ២២ មីនា ២០០៦ ត្រង់កថាខណ្ឌទី៧ ("សាលដីកាលើសំណុំរឿងរបស់ *Stakić*")។ *រដ្ឋអាជ្ញា ទល់នឹង Zoran Kupreškić និងគូកន,* សំណុំរឿងលេខ IT-95-16-A, សាលដីកា, ២៣ តុលា ២០០១ ត្រង់កថាខណ្ឌទី២២។ *រដ្ឋអាជ្ញា ទល់នឹង Duško Tadić,* សំណុំរឿងលេខ IT-94-1-A, សាលដីកា, ១៥ កក្កដា ១៩៩៩ ត្រង់កថាខណ្ឌទី២៤៧។ *រដ្ឋអាជ្ញា ទល់នឹង Jean-Paul Akayesu,* សំណុំរឿងលេខ ICTR-96-1-A, សាលដីកា, ១ មិថុនា ២០០១ ត្រង់កថាខណ្ឌទី១៨-១៩ ("សាលដីកាលើសំណុំរឿងរបស់ *Akayesu*")។

[17] *រដ្ឋអាជ្ញា ទល់នឹង Jean-Paul Akayesu*, សំណុំរឿងលេខ ICTR-៩៦-១-A, សាលដីកា (សាលដីកាសាលាឧទ្ធរណ៍), ១ ខែមិថុនា ឆ្នាំ ២០០១ ( សាលដីកាលើសំណុំរឿងរបស់ *Akayesu*) ត្រង់កថាខណ្ឌទី២១ [គូសបញ្ជាក់បន្ថែម]។។

[18] *រដ្ឋអាជ្ញា ទល់នឹង Jean-Paul Akayesu,* Case No. ICTR-96-1-A, សាលដីកា (សាលដីកាសាលាឧទ្ធរណ៍*Akayesu*), ចុះថ្ងៃទី១ ខែមិថុនា ឆ្នាំ២០០១ ត្រង់កថាខណ្ឌទី២១។

[19] *រដ្ឋអាជ្ញា ទល់នឹង Jean-Paul Akayesu,* Case No. ICTR-96-1-A, សាលដីកា (សាលដីកាសាលាឧទ្ធរណ៍*Akayesu*), ចុះថ្ងៃទី១ ខែមិថុនា ឆ្នាំ២០០១ ត្រង់កថាខណ្ឌទី២១។

[20] *រដ្ឋអាជ្ញា ទល់នឹង Jean-Paul Akayesu,* Case No. ICTR-96-1-A, សាលដីកា (សាលដីកាសាលាឧទ្ធរណ៍*Akayesu*), ចុះថ្ងៃទី១ ខែមិថុនា ឆ្នាំ២០០១ ត្រង់កថាខណ្ឌទី២២។

8. ឈរលើមូលដ្ឋាននេះ អង្គជំនុំជម្រះសាលាឧទ្ធរណ៍ក្នុងរឿងក្តី *Akayesu* បានទទួលយកបណ្តឹងឧទ្ធរណ៍របស់រដ្ឋអាជ្ញាស្តីពីបញ្ហាច្បាប់ទាំងបីដែលមានធាតុផ្សំនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ទោះបីជាវាមិនប៉ះពាល់ដល់សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងក៏ដោយ[21]។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍ក្នុងរឿងក្តី *Brđanin* ក៏បានទទួលយកសំណើរបស់រដ្ឋអាជ្ញាផងដែរ ដែលស្នើសុំឲ្យ "បំភ្លឺពីបញ្ហាច្បាប់"[22] ស្តីពីការអនុវត្តសហឧក្រិដ្ឋកម្មរួម (JCE) នៃសហឧក្រិដ្ឋកម្មក្នុងទ្រង់ទ្រាយធំ បើទោះបីជាកិច្ចព្រមព្រៀងរបស់ភាគីទាំងអស់ថា ជាលទ្ធផល អង្គជំនុំជម្រះសាលាឧទ្ធរណ៍នឹងមិនមានការផ្តន្ទាទោសថ្មីណាមួយក៏ដោយ[23]។

9. លើសពីនេះទៀត ក្នុងនាមជាស្ថាប័នតុលាការកំពូលរបស់ អ.វ.ត.ក អង្គជំនុំជម្រះនេះគួរប្រើសិទ្ធិអំណាចដូចគ្នាដែលមាននៅក្រោមច្បាប់កម្ពុជា ក្នុងការដោះស្រាយបញ្ហាច្បាប់ទាំងឡាយ ដែលមានលក្ខណៈចាប់បង្ខំ បើទោះជាវាមិនប៉ះពាល់ដល់សាលក្រមស្ថាពរក៏ដោយ។ កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ ជាមួយរដ្ឋាភិបាលកម្ពុជា និងច្បាប់ អ.វ.ត.ក ផ្តល់ឱកាសតែមួយគត់សម្រាប់បណ្តឹងសាទុក្ខ[24] ដោយមិនរាប់បញ្ចូលនូវឱកាសបន្ទាន់បង្ខំផ្សេងៗទៀត សម្រាប់ជាដំណោះស្រាយដែលបានផ្តល់ជូនក្នុងប្រព័ន្ធតុលាការពិនិត្យពីរជាន់របស់កម្ពុជា ហើយអនុញ្ញាតឲ្យមានតែបណ្តឹងមួយគត់នៅមុនពេលសាលក្រមចូលជាស្ថាពរ[25]។

10. អវត្តមាននៃការទទួលយកបណ្តឹងសាទុក្ខនៅដំណាក់កាលនេះ មានន័យថា អង្គជំនុំជម្រះនេះនឹង

---

[21] *រដ្ឋអាជ្ញា ទល់នឹង Jean-Paul Akayesu,* Case No. ICTR-96-1-A, សាលដីកា (សាលដីកាសាលាឧទ្ធរណ៍*Akayesu*), ចុះថ្ងៃទី១ ខែមិថុនា ឆ្នាំ២០០១ ត្រង់កថាខណ្ឌទី២៥-២៨។

[22] *រដ្ឋអាជ្ញា ទល់នឹង Radoslav Brđanin*, សំណុំរឿងលេខ: IT-99-36-A, សាលដីកាឧទ្ធរណ៍, ៣ មេសា ២០០៧, ត្រង់កថាខណ្ឌ៤៤៨ ("សាលដីកាឧទ្ធរណ៍រឿងក្តី *Brđanin*")។ សូមមើលផងដែរ សារណាបណ្តឹងសាទុក្ខរបស់រដ្ឋអាជ្ញាក្នុងរឿងក្តី *Brđanin* ត្រង់កថាខណ្ឌ ៣.៤៩។

[23] *រដ្ឋអាជ្ញា ទល់នឹង Radoslav Brđanin*, សំណុំរឿងលេខ: IT-99-36-A, សាលដីកាឧទ្ធរណ៍, ៣ មេសា ២០០៧, ត្រង់កថាខណ្ឌ៤៤៨ ("សាលដីកាឧទ្ធរណ៍រឿងក្តី *Brđanin*") ត្រង់កថាខណ្ឌ៤៤៨។

[24] ច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ, ១០ សីហា ២០០១ បូកជាមួយច្បាប់វិសោធនកម្មដែលបានប្រកាសឲ្យប្រើ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤ (នស/រកម/១០០៤/០០៦),(ច្បាប់អវតក) មាត្រា៩ថ្មី។ កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ, ចុះហត្ថលេខា នៅថ្ងៃទី ៦ ខែមិថុនា ឆ្នាំ២០០៣ (ចូលជាធរមាន នៅថ្ងៃទី ២៩ ខែមេសា ឆ្នាំ២០០៥), ("កិច្ចព្រមព្រៀង UN-RGC"), មាត្រា៣(២)(ខ)។

[25] ច្បាប់ អ.វ.ត.ក, មាត្រា២ (ថែងអំពីសាលាដំបូង សាលាឧទ្ធរណ៍ និងតុលាការកំពូល)។

គ្មានអំណាចក្នុងការដោះស្រាយបញ្ហាស្តីពីសារៈសំខាន់ជាទូទៅនេះទេ ទាក់ទិននឹងការអនុវត្តសហឧក្រិដ្ឋកម្មរួមក្នុងទម្រង់ទី III នេះ។ កំហុសខាងអង្គច្បាប់ដោយអង្គជំនុំជម្រះសាលាដំបូងបានបដិសេធមិនពិចារណាថាសហឧក្រិដ្ឋកម្មរួមក្នុងទម្រង់ទី III គឺជាទម្រង់មួយនៃការទទួលខុសត្រូវនោះ គេគ្មានអ្វីឲ្យសង្ស័យទេថា កំហុសនេះនឹងកើតមានជាដដែលទៀត នៅក្នុងសវនាការនាពេលខាងមុខក្នុងសំណុំរឿង០០២។ សហព្រះរាជអាជ្ញាបានជូនដំណឹងជាសាធារណៈដល់ជនជាប់ចោទ និងអង្គជំនុំជម្រះសាលាដំបូងរួចហើយថា សហព្រះរាជអាជ្ញានឹងស្វែងរកការអនុវត្តសហឧក្រិដ្ឋកម្មរួមក្នុងទម្រង់ទី III ដោយហេតុថា វាជាអង្គហេតុមួយសមស្រប និងជាទម្រង់នៃការទទួលខុសត្រូវ *តាមរបៀបផ្សេងមួយ* ដែលជាប់ទាក់ទងនឹងការចោទប្រកាន់ជាក់លាក់មួយចំនួន នៅក្នុងកិច្ចដំណើរការនីតិវិធី[26]។ ដោយយោងកិច្ចដំណើរការនីតិវិធីបើតាមការរំពឹងទុកថា នឹងមានរយៈពេលវែង និងដោយសារបទចោទដែលនៅសេសសល់ពីសំណុំរឿង០០២/០២ មិនទំនងជានឹងទទួលបានការជំនុំជម្រះ អង្គជំនុំជម្រះនេះនឹងមិនមានឱកាសជាចុងក្រោយសម្រាប់កំណត់អំពីបញ្ហានេះទេ លើកលែងតែបណ្តឹងសាទុក្ខនេះត្រូវបានបើកសវនាការនៅពេលនេះតែប៉ុណ្ណោះ។

11. ការពិចារណាដែលមានលក្ខណៈចាប់បង្ខំចំពោះគោលនយោបាយសាធារណៈជាអន្តរជាតិ តម្រូវឲ្យមានការពិនិត្យដោយអង្គជំនុំជម្រះនេះ ដូចមានចែង ក្នុងសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា[27]។ ទ្រឹស្តី ស្តីពីសហឧក្រិដ្ឋកម្មរួម ផ្តល់ឲ្យសង្គមមនុស្សនូវយន្តការច្បាប់ដើម្បីដាក់មេដឹកនាំទាំងឡាយឲ្យទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មទាំងអស់ ដែលកើតពីចេតនា និងអាចព្យាករណ៍ទុកបាន ហើយដែលឧក្រិដ្ឋកម្មទាំងនោះជាបច្ច័យនៃសហកម្ម ដោយឈរលើការចូលរួមយ៉ាងសកម្មដោយមានឆន្ទៈ របស់ពួកគាត់។ ការណ៍ដែលទុកឲ្យឧក្រិដ្ឋកម្មដែលអាចព្យាករបានទាំងនេះ ដែលបានប្រព្រឹត្តឡើងដោយបុគ្គលទាំងឡាយដែលយល់ ឬដឹងថាអំពើនោះជាបទល្មើសព្រហ្មទណ្ឌ រួចផុតពីការផ្តន្ទាទោស មិនបម្រើឲ្យផលប្រយោជន៍យុត្តិធម៌ឡើយ។ ការអនុញ្ញាតឲ្យបណ្តឹងសាទុក្ខនេះបន្តដំណើរទៅមុខ នឹងផ្តល់ឱកាសឲ្យអង្គជំនុំជម្រះនេះ ថ្លែងបង្ហាញពីបញ្ហាសំខាន់នេះ និងប្រសិនបើយល់ថា ទង្វើនេះសមស្របបណ្តឹងសាទុក្ខ នឹងផ្តល់ឱកាសឲ្យអង្គជំនុំជម្រះនេះធ្វើឲ្យ ជំហរផ្លូវច្បាប់របស់ អ.វ.ត.ក មានឯកភាពជារួមជាមួយនឹងសេចក្តីសម្រេចនានា

---

[26] **E1/240.1** ប្រតិចារឹក, ៣០ កក្កដា ២០១៤ ត្រង់កថាខណ្ឌ៣៣-៣៤ ម៉ោង 10:12:15។

[27] **E313/3/1** សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញា ស្តីពីបណ្តឹងសាទុក្ខចំពោះសេចក្តីសម្រេចនៅក្នុងសំណុំរឿង០០២/០១, ២៩ កញ្ញា ២០១៤ ត្រង់កថាខណ្ឌ៨។

ក៏ដូចជាសាលក្រមស្ដាពររបស់តុលាការ ICTY, ICTR, SCSL និង STL[28] លើសពីនេះទៀត នឹងធ្វើឱ្យមាន បន្ទាត់សង្គតិភាព ចំពោះករណីយុត្តិសាស្ត្រនៃច្បាប់អន្តរជាតិស្ដីពីសហឧក្រិដ្ឋកម្មរួមក្នុងទម្រង់ទី III។

## IV. អង្គសេចក្ដី

### ក. ការទទួលខុសត្រូវតាមទម្រង់សហឧក្រិដ្ឋកម្ម III មានដាក់បញ្ចូលទៅក្នុងច្បាប់ អវតក

12. ស្របតាមយុត្តិសាស្ត្ររបស់តុលាការ ICTY, ICTR, SCSL អង្គជំនុំជម្រះទាំងអស់របស់ អវតក បានសម្រេចថា សហឧក្រិដ្ឋកម្មរួមត្រូវបានដាក់បញ្ចូលជាទម្រង់នៃការទទួលខុសត្រូវតាមពាក្យថា "ការប្រព្រឹត្ត" ទៅក្នុងមាត្រា២៩ នៃច្បាប់ អវតក[29]។ មិនដូចសហចៅក្រមស៊ើបអង្កេតទេ អង្គបុរេ

[28] នៅចំពោះមុខតុលាការ **ICTY**, សូមមើល សាលដីកាលើបណ្ដឹងសាទុក្ខក្នុងរឿងក្ដី. *Duško Tadić*, Case No. IT-94-1-A សាលដីកា "អង្គជំនុំឧទ្ធរណ៍" ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៩ "សាលដីកាឧទ្ធរណ៍ *Tadić*" ត្រង់កថាខណ្ឌ២៣២ ["ម្ចាស់បណ្ដឹងបានដឹងថា សកម្មភាពរបស់ក្រុមដែលគាត់ជាសមាជិកម្នាក់ដែរនោះ ទំនងជានាំទៅដល់ការកាប់សម្លាប់ដូច្នេះមែន ប៉ុន្តែផ្ទុយទៅវិញ គាត់នៅតែមានចេតនាចង់ប្រថុយនឹងហានិភ័យនោះ"]។ *រដ្ឋអាជ្ញា ទល់នឹង Radislav Krstić*, សំណុំរឿង IT-98-33-A, ១៩ មេសា ២០០៤, សាលដីកាលើបណ្ដឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ១៥១ ("សាលដីកាលើបណ្ដឹងឧទ្ធរណ៍ក្នុងរឿងក្ដី *Krstić*") ["ការទទួលខុសត្រូវរបស់... ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង ...បានកើតចេញពីការចូលរួមប្រព្រឹត្តរបស់បុគ្គលម្នាក់ៗនៅក្នុងសហឧក្រិដ្ឋកម្មរួមក្នុងការជម្លៀសជនស៊ីវិលដោយបង្ខំ។ ឧក្រិដ្ឋកម្មឱកាសនិយមទាំងនេះ មានលក្ខណៈជាធម្មតា និងអាចព្យាករបានពីផលវិបាកនៃសហឧក្រិដ្ឋកម្មរួមនោះ"]។ *រដ្ឋអាជ្ញា ទល់នឹង Milomir Stakić*, Case No, IT-97-24-A, សាលដីកាលើបណ្ដឹងសាទុក្ខក្នុងរឿងក្ដី *Stakić*, *ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០០៦* ត្រង់កថាខណ្ឌ៩៨ ["របបគំហើញខាងអង្គហេតុរបស់អង្គជំនុំជម្រះសាលាដំបូងបង្ហាញឲ្យឃើញថា ម្ចាស់បណ្ដឹងសាទុក្ខមាន*ចេតនាឧក្រិដ្ឋមុន* ដែលបានរកឃើញពីការទទួលខុសត្រូវនៅក្រោមសហឧក្រិដ្ឋកម្មរួមជំពូកទីបី"]។ សូមមើលផងដែរ កថាខណ្ឌ 233-234។ នៅចំពោះមុខតុលាការ **ICTR**, សូមមើល *រដ្ឋអាជ្ញា ទល់នឹង Édouard Karemera* និងគូកន., សំណុំរឿងលេខ: ICTR-97-24-T, សាលក្រមអង្គជំនុំជម្រះសាលាដំបូង, ២ កុម្ភៈ ២០១២ ត្រង់កថាខណ្ឌ៦២៣។ *រដ្ឋអាជ្ញា ទល់នឹង Édouard Karemera* និងគូកន., សំណុំរឿងលេខ: ICTR-97-24-A, សាលដីកាលើបណ្ដឹងឧទ្ធរណ៍, ២៩ កញ្ញា ២០១៤ ត្រង់កថាខណ្ឌ២០០ (កែប្រែការកាត់ទោសដោយផ្អែកលើមូលដ្ឋាន JCE III ដោយសារអវត្តមានការរកឃើញអង្គហេតុជាក់លាក់មួយចំនួននៅក្នុងពេលជំនុំជម្រះ ប៉ុន្តែនៅតម្កល់ច្បាប់ជាធរមានដដែល)។ នៅចំពោះមុខតុលាការ **SCSL**, សូមមើល *រដ្ឋអាជ្ញា ទល់នឹង Alex Tamba Brima* និងគូកន., សំណុំរឿងលេខ: SCSL-04-16-A, សាលដីកាឧទ្ធរណ៍, ២២ កុម្ភៈ ២០០៨ ត្រង់កថាខណ្ឌ៧៣-៧៦ និង៨៧។ នៅចំពោះមុខតុលាការ **STL**, សូមមើល STL-11-01/I សេចក្ដីសម្រេចបណ្ដោះអាសន្នស្ដីពីច្បាប់ជាធរមាន: អំពើភេរវកម្ម, អំពើសមគំនិត, អំពើមនុស្សឃាត, ការប្រព្រឹត្តបទល្មើស, បទចោទត្រួតគ្នា (អង្គជំនុំជម្រះសាលាឧទ្ធរណ៍), ១៦ កុម្ភៈ ២០១១ ត្រង់កថាខណ្ឌ២៤៥។

[29] **E188** សាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ("សាលក្រមសំណុំរឿង០០១") ត្រង់កថាខណ្ឌ៥១១។ សេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះ កំណត់សម្គាល់ជើងទំព័រលេខ៖៥ ត្រង់កថាខណ្ឌ៦៩។ **E100/6** សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង កំណត់សម្គាល់ជើងទំព័រលេខ៖៧ ត្រង់កថាខណ្ឌ១៥ និង២២។ សូមអាន រដ្ឋអាជ្ញា ទល់នឹង *Duško Tadić* Case No. IT-94-1-A សាលដីកា "អង្គជំនុំឧទ្ធរណ៍" កំណត់សម្គាល់ជើងទំព័រលេខ៖១៦ ត្រង់កថាខណ្ឌ១២២០ ២២៧-២២៨។ រដ្ឋអាជ្ញា ទល់នឹង *Elizaphan Ntakirutimana et al.*, Cases Nos. ICTR-96-10-A and ICTR-96-17-A,និង ICTR-96-17-A សាលដីកា "អង្គជំនុំឧទ្ធរណ៍" ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៤ ("សាលដីកាឧទ្ធរណ៍*Ntakirutimana*") ត្រង់កថាខណ្ឌ៤៦១-៤៨៤។ រដ្ឋអាជ្ញា ទល់នឹង *Alex Tamba*

ជំនុំជម្រះបានសម្រេចថា មានតែសហឧក្រិដ្ឋកម្មទម្រង់ I និង II ទេ ដែលអាចអនុវត្តបាន[30]។ សហព្រះរាជអាជ្ញាសន្និដ្ឋានថា (១) មាត្រា២៩ នៃច្បាប់ អវតក ពិតជាដូចគ្នាទៅនឹងបទប្បញ្ញត្តិ ដែលមាននៅក្នុងច្បាប់របស់ ICTY, ICTR និង SCSL[31] (២) អ្នកធ្វើសេចក្តីព្រាងច្បាប់ អវតក មិនបានជំទាស់ និងមិនបានបដិសេធឲ្យបានច្បាស់លាស់នូវការទទួលខុសត្រូវ ក្នុងទម្រង់សហឧក្រិដ្ឋកម្មរួម III ចេញពីច្បាប់របស់ អវតក ទេ ទោះបីជាតុលាការដទៃទៀតបានបញ្ជាក់ពីអត្ថិភាព នៅពេលអនុម័តក៏ដោយ[32] និង (៣) ការដាក់បញ្ចូលរាល់ទម្រង់ទាំងអស់នៃសហឧក្រិដ្ឋកម្មរួម ជាប់ទាក់ទងខ្លាំងនឹងគោលដៅ និងគោលបំណងរបស់ អវតក អង្គជំនុំជម្រះតុលាការកំពូលគួរតែ បកស្រាយមាត្រា២៩ ដើម្បីដាក់បញ្ចូលទម្រង់នៃការទទួលខុសត្រូវនៃសហឧក្រិដ្ឋកម្មរួម III។ ការខកខានរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការកំណត់សហឧក្រិដ្ឋកម្មទម្រង់ទី III ដែលអាចអនុវត្តបាននៅ អវតក គឺមានកំហុស បន្ទាប់ពីសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះដែលបាន សម្រេចថា សហឧក្រិដ្ឋកម្មទម្រង់ទី III មិនមែនជាផ្នែកមួយនៃច្បាប់ទំលៀមទំលាប់អន្តរជាតិ ក្នុងអំឡុងយុត្តាធិការពេលវេលារបស់ អវតក និងដែលអនុវត្តទម្រង់នៃការទទួលខុសត្រូវនេះ អាចរំលោភគោលការណ៍ "គ្មានច្បាប់ចែង គ្មានបទល្មើស"។

---

*Brima et al.,* Case No. SCSL-04-16-T សេចក្តីលើញត្តិរបស់មេធាវីការពារក្តីស្នើសុំឲ្យដោះលែងអនុលោមតាមវិធាន៩៨ "អង្គជំនុំជម្រះ" ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៦ ("សេចក្តីសម្រេចពាក់ព័ន្ធវិធាន៩៨របស់ *Brima*") ត្រង់កថាខណ្ឌទី៣០៨-៣២៦។

[30] **D97/17/6** សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតស្តីពីសហកម្មឧក្រិដ្ឋកម្មរួម ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១០ ("សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ") កថាខណ្ឌ៦៩ ៧២ ៧៧-៨៨។ **E100/6** សេចក្តីសម្រេចស្តីពីការអនុវត្តសហកម្មឧក្រិដ្ឋកម្មរួម ថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១១ ("សេចក្តីសម្រេចរបស់អង្គជំនុំជម្រះ") កថាខណ្ឌ២២ ២៩ ៣០-៣៥ ៣៧-៣៨។

[31] លក្ខន្តិកៈរបស់តុលាការ ICTY, ICTR, និង SCSL មានភាពខុសប្លែកតូចចំនួនពីរក្នុងច្បាប់ អវតក ក្នុងនោះ (១) មានពាក្យ "ម៉្យាងទៀត" មុន ការជួយជ្រោមជ្រែង និង(២) ទម្រង់នៃការទទួលខុសត្រូវនៃការប្រព្រឹត្តិ គឺដាក់នៅមុនពាក្យ ការជួយជ្រោមជ្រែង។ លក្ខន្តិកៈរបស់តុលាការ ICTY ថ្ងៃទី២៥ ខែឧសភា ឆ្នាំ១៩៩៣ វិសោធនកម្មថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០០៩ "ហៅថាច្បាប់លក្ខន្តិកៈរបស់តុលាការ ICTY" មាត្រា៧(១) ចែងអំពីការទទួលខុសត្រូវព្រហ្មទណ្ឌជាលក្ខណៈបុគ្គលចំពោះអ្នកដែលរៀបផែនការ ញុះញង់ ប្រព្រឹត្ត ឬម៉្យាងទៀត ជួយជ្រោមជ្រែង" ជាឧក្រិដ្ឋកម្មដែលតុលាការផ្តន្ទាទោស។ លក្ខន្តិកៈរបស់តុលាការ ICTR ថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ១៩៩៤ វិសោធនកម្ម ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០២ "ហៅថាច្បាប់លក្ខន្តិកៈរបស់តុលាការ ICTR" មាត្រា៦(១) (ដូចគ្នា)។ លក្ខន្តិកៈរបស់តុលាការ SCSL ថ្ងៃទី១៦ ខែមករា ឆ្នាំ២០០២ "ហៅថាច្បាប់លក្ខន្តិកៈរបស់តុលាការ SCSL" មាត្រា៦(១) (ដូចគ្នា)។ ដោយហេតុថា ការទទួលខុសត្រូវខាងព្រហ្មទណ្ឌដែលមានចែងនៅក្នុងបទប្បញ្ញត្តិទាំងនេះ បានរៀបរាប់ការប្រើប្រាស់ពាក្យដូចគ្នានឹងបទប្បញ្ញត្តិរបស់ អវតក។ មិនមានហេតុផលណាគិតថា ការមិនមានពាក្យ "ម៉្យាងទៀត" និងការកត់ត្រាពាក្យខុសគ្នាបន្តិចបន្តួច មានចេតនាថាបទប្បញ្ញត្តិរបស់ អវតក មានន័យខុសគ្នានោះ។

[32] សូមមើល ឧទាហរណ៍ រដ្ឋអាជ្ញា ទល់នឹង *Duško Tadić*, Case No. IT-94-1-A, សាលដីកា "អង្គជំនុំឧទ្ធរណ៍" ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៩ "សាលដីកាឧទ្ធរណ៍ *Tadić*" ត្រង់កថាខណ្ឌ១៨៩ ១៩១ ១៩៥-២២៦។ រដ្ឋអាជ្ញា ទល់នឹង *Elizaphan Ntakirutimana et al.*, Cases Nos. ICTR-96-10-A និង ICTR-96-17-A, សាលដីកា "អង្គជំនុំឧទ្ធរណ៍" ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០៦ ត្រង់កថាខណ្ឌ៤៦១-៤៨៤។ រដ្ឋអាជ្ញា ទល់នឹង *Alex Tamba Brima et al.,* Case No. SCSL-04-16-T សេចក្តីសម្រេចលើញត្តិរបស់មេធាវីការពារក្តីស្នើសុំដោះលែងតាមសាលក្រម អនុលោមតាមវិធាន៩៨ (អង្គជំនុំជម្រះ) ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៦ ត្រង់កថាខណ្ឌ៣០៨-៣២៦។

## ខ. ការទទួលខុសត្រូវក្នុងទម្រង់សហឧក្រិដ្ឋកម្មរួមទម្រង់ទី III ស្របគ្នានឹងគោលការណ៍គ្មានច្បាប់ចែង គ្មានបទល្មើស

13. អង្គបុរេជំនុំជម្រះសម្រេចថា "គោលការណ៍នីត្យានុកូលភាព តម្រូវឱ្យ អ.វ.ត.ក មិនផ្អែកទៅលើទម្រង់ទូលាយនៃសហឧក្រិដ្ឋកម្មរួមឡើយ"[33]។ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីអំពី សហឧក្រិដ្ឋកម្មរួម បានបញ្ជាក់ថា ក្នុងកាលៈទេសៈដែលអង្គជំនុំជម្រះសាលាដំបូង "មិនអាចរកឃើញមូលហេតុរឹងមាំ ដើម្បីងាកចេញពីការវិភាគរបស់អង្គបុរេជំនុំជម្រះ" និងយល់ស្របជាមួយនឹងលទ្ធផលនោះ អង្គជំនុំជម្រះសាលាដំបូងនឹងមិនចេញសេចក្តីសម្រេចដែលវែងនោះទេ[34]។ សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះស្តីអំពីសហឧក្រិដ្ឋកម្មរួមទម្រង់ទី III ដែលយកគោលការណ៍*គ្មានបទល្មើស ប្រសិនបើគ្មានច្បាប់ចែង* ("គោលការណ៍*គ្មានបទល្មើស បើគ្មានច្បាប់ចែង*") មកអនុវត្តមិនត្រឹមត្រូវជាមូលដ្ឋាន នៅក្នុងការសម្រេចថា ការយកទម្រង់ទូលាយនៃសហឧក្រិដ្ឋកម្មរួមមកអនុវត្តនៅ អ.វ.ត.ក នឹងរំលោភទៅលើគោលការណ៍នេះ។ គោលការណ៍*គ្មានបទល្មើស បើគ្មានច្បាប់ចែង* រារាំងតុលាការមិនឱ្យសម្រេចថាបុគ្គលមានការទទួលខុសត្រូវព្រហ្មទណ្ឌចំពោះអំពើដែលមិនមែនជាអំពើឧក្រិដ្ឋ នៅខណៈពេលដែលអំពើនោះត្រូវបានប្រព្រឹត្តិឡើង។ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថាជនជាប់ចោទនៅ អ.វ.ត.ក អាចដាក់ឱ្យទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនៅក្រោមទម្រង់ពីរដំបូងនៃសហឧក្រិដ្ឋកម្ម ដោយសារតែទម្រង់នៃការទទួលខុសត្រូវទាំងនេះ គឺជាផ្នែកនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅត្រឹមឆ្នាំ ១៩៧៥។ វាជាការមិនត្រឹមត្រូវឡើយក្នុងការសម្រេចថា ជនជាប់ចោទនៅ អ.វ.ត.ក អាចដាក់ឱ្យមានការទទួលខុសត្រូវ ក្រោមសហឧក្រិដ្ឋកម្មរួមទម្រង់ទី I ប៉ុន្តែមិនអាចដាក់ឱ្យទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្ម ក្រោមសហឧក្រិដ្ឋកម្មរួមទម្រង់ទី III ដោយផ្អែកលើមូលដ្ឋានថា វានឹងរំលោភលើគោលការណ៍*គ្មានបទល្មើស បើគ្មានច្បាប់ចែង* នោះ។

14. គោលការណ៍*គ្មានបទល្មើស បើគ្មានច្បាប់ចែង* តម្រូវត្រឹមថា ជនជាប់ចោទបានដឹងតាមការសន្មតថា ការប្រព្រឹត្តិរបស់គាត់គឺជាអំពើល្មើសច្បាប់។ ការប្រព្រឹត្តិដែលជាលក្ខខណ្ឌតម្រូវនៃសហឧក្រិដ្ឋ

---

[33] ឯកសារ **D97/17/6** សាលដីការបស់អង្គបុរេជំនុំជម្រះប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ស្តីពីការអនុវត្តសហឧក្រិដ្ឋកម្មរួម ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១០ ("សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ") ត្រង់កថាខណ្ឌ ៨៧។

[34] ឯកសារ **E100/6** សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីការអនុវត្តសហឧក្រិដ្ឋកម្មរួម ថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១១ ("សេចក្តីសម្រេចរបស់អង្គជំនុំជម្រះ") ត្រង់កថាខណ្ឌ ២៦។

កម្មរួមទម្រង់ទីបី គឺដូចគ្នាបេះបិទទៅនឹងការប្រព្រឹត្តិដែលជាលក្ខខណ្ឌតម្រូវនៃសហឧក្រិដ្ឋកម្មទម្រង់ទីមួយ៖ អំពើសកម្ម ឬអកម្ម ដែលបង្កើតបានជាការចូលរួមចំណែកយ៉ាងសំខាន់ដល់សហឧក្រិដ្ឋកម្មរួម ដែលបុគ្គលជាច្រើន មានចេតនាប្រព្រឹត្តបទឧក្រិដ្ឋ ដែលស្ថិតក្នុងយុត្តាធិការរបស់តុលាការ។ ហេតុដូច្នេះ ការអនុវត្តសហឧក្រិដ្ឋកម្មរួមទម្រង់ទីបី អាចមិនធ្វើឱ្យជនជាប់ចោទទទួលខុសត្រូវព្រហ្មទណ្ឌ ក្នុងករណីដែលគាត់មិនត្រូវទទួលខុសត្រូវនោះ ប៉ុន្តែអាចធ្វើឱ្យជនជាប់ចោទនោះ ទទួលខុសត្រូវព្រហ្មទណ្ឌចំពោះបទឧក្រិដ្ឋច្រើន ដោយផ្អែកលើការប្រព្រឹត្តិបទឧក្រិដ្ឋដូចគ្នា។

15. គោលបំណងនៃគោលការណ៍*គ្មានបទល្មើស បើគ្មានច្បាប់ចែង* គឺដើម្បីធានាថា មិនមានបុគ្គលណាម្នាក់ត្រូវទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះអំពើសកម្ម ឬអកម្ម ដែលគាត់មិនមានហេតុផលនឹងប្រមើលមើលដឹងថាជាបទឧក្រិដ្ឋនៅពេលនោះ។ មាត្រា ២២(១) នៃលក្ខន្តិកៈរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ បានបញ្ជាក់ឡើងវិញអំពីគោលការណ៍នេះថា៖

*បុគ្គលម្នាក់មិនត្រូវទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ក្រោមលក្ខន្តិកៈនេះទេ លុះត្រាតែការប្រព្រឹត្តិដែលចោទជាបញ្ហា អាចបង្កើតជាបទឧក្រិដ្ឋដែលស្ថិតក្នុងយុត្តាធិការរបស់តុលាការ នៅពេលដែលការប្រព្រឹត្តិនោះត្រូវបានធ្វើឡើង។*

16. គោលការណ៍*គ្មានបទល្មើស បើគ្មានច្បាប់ចែង* ពាក់ព័ន្ធនឹងបញ្ហាថាតើ ការប្រព្រឹត្តិរបស់ជនជាប់ចោទគឺជាការប្រព្រឹត្តិបទឧក្រិដ្ឋដែរឬយ៉ាងណា នៅពេលដែលមានអំពើនោះ ហើយមិនពាក់ព័ន្ធនឹងបញ្ហាថាតើ បទល្មើស ឬទម្រង់នៃការទទួលខុសត្រូវ ដែលជនជាប់ចោទត្រូវបានផ្តន្ទាទោស ត្រូវបានកំណត់ដោយធាតុផ្សំដូចគ្នាដែលឬយ៉ាងណា នៅពេលដែលមានការប្រព្រឹត្តិអំពើនោះឡើយ។ នៅក្នុងសាលដីកាសំណុំរឿង ឌុច អង្គជំនុំជម្រះតុលាការកំពូលបានដកស្រង់[35] សាលដីកាលើរឿងក្តី *Hadžihasanović* ដែលលើកឡើងអំពីលក្ខខណ្ឌតម្រូវរបស់គោលការណ៍គ្មានបទល្មើស បើគ្មានច្បាប់ចែង ពាក់ព័ន្ធភាពអាចប្រមើលមើលបាន "ថា ការប្រព្រឹត្តិដែលត្រូវបានចោទប្រកាន់ អាចទទួលការផ្តន្ទាទោសព្រហ្មទណ្ឌ នៅពេលដែលឧក្រិដ្ឋកម្មនោះត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្ត"[36]។ ប្រយោគដែលបានដកស្រង់ ហើយដែលអង្គជំនុំជម្រះតុលាការកំពូលបានផ្តល់តែមួយ

[35] ឯកសារ **F28** សាលដីកា, ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១២, កថាខណ្ឌ ៩៦។

[36] *រដ្ឋអាជ្ញា តទល់នឹង* Hadžihasanović *និងអ្នកដទៃទៀត សំណុំរឿងលេខ* IT-01-47-AR72, សាលដីកាលើបណ្តឹងសាទុក្ខបន្ទាន់បង្ខំ ជំទាស់នឹងយុត្តាធិការ ពាក់ព័ន្ធការទទួលខុសត្រូវរបស់ថ្នាក់លើ ("អង្គជំនុំជម្រះឧទ្ធរណ៍"), ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០០៣, ("សេចក្តីសម្រេច *Hadžihasanović*") កថាខណ្ឌ ៣៤។

ផ្នែក នៅក្នុងសាលដីកា បានរៀបរាប់ថា "ចំពោះភាពអាចដឹងជាមុនថាជាបទល្មើសនោះ ការប្រព្រឹត្តិដែលត្រូវជំនុំជម្រះ គឺជាការប្រព្រឹត្តិច្បាស់លាស់របស់ជនជាប់ចោទ។ ជនជាប់ចោទត្រូវតែអាចដឹងថា អំពើដែលខ្លួនប្រព្រឹត្ត គឺជាអំពើព្រហ្មទណ្ឌ ក្នុងន័យដែលគេអាចយល់ដឹងជាទូទៅ ដោយមិនចាំបាច់សំអាងលើបទប្បញ្ញត្តិជាក់លាក់ណាមួយនោះទេ"[37]។ អង្គជំនុំជម្រះតុលាការកំពូលក្នុងរឿងក្ដី *Hadžihasanović* ក៏បានបញ្ជាក់នៅក្នុងកថាខណ្ឌដដែលនោះថា ខ្លួន "យល់ស្រប ជាមួយនឹងចម្លើយដែលផ្ដល់ឲ្យដោយអង្គជំនុំជម្រះ"[38] ចំពោះបញ្ហានេះ។ ហេតុដូច្នេះ ការដកស្រង់ពីអង្គជំនុំជម្រះ ក្នុងរឿងក្ដី *Hadžihasanović* ដែលអង្គជំនុំជម្រះបានសម្រេចនៅក្នុងផ្នែកដែលពាក់ព័ន្ធថា:

> *នៅក្នុងការបកស្រាយ*គោលការណ៍គ្មានបទល្មើស បើគ្មានច្បាប់ចែង *ជាការសំខាន់ត្រូវធ្វើការកំណត់ថាតើ ការប្រព្រឹត្តិជាមូលដ្ឋាន នៅពេលប្រព្រឹត្តនោះ អាចផ្ដន្ទាទោសបាន ឬទេ។ ការផ្ដោតទៅលើការប្រព្រឹត្តិ ជាជាងការផ្ដោតទៅលើការពណ៌នាជាក់លាក់អំពីបទល្មើសនៅក្នុងច្បាប់ព្រហ្មទណ្ឌ មានភាពពាក់ព័ន្ធជាចម្បង*[39] ។

17. ការដកចេញការទទួលខុសត្រូវព្រហ្មទណ្ឌពីក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ អាចបង្កជាបញ្ហាយ៉ាងធ្ងន់ធ្ងរ លុះត្រាតែបទល្មើស ឬទម្រង់នៃការទទួលខុសត្រូវ អាចត្រូវបានបង្ហាញថា មានអត្ថិភាពជាមួយនឹងនិយមន័យដ៏ច្បាស់ដូចគ្នា នៅពេលដែលមានបទល្មើសនោះ។ វិធីសាស្ត្របែបនេះអាចកាត់បង្រួមដោយមិនត្រឹមត្រូវចំពោះវិសាលភាពនៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ព្រោះយុត្តាធិការជាតិ និងសូម្បីតែតុលាការអន្តរជាតិ មានភាពខុសគ្នាយ៉ាងខ្លាំងនៅក្នុងនិយមន័យរបស់ខ្លួនអំពីបទល្មើស និងធាតុផ្សំនៃទម្រង់នៃការទទួលខុសត្រូវ ហើយនិយមន័យទាំងនោះ ប្រែប្រួលជាធម្មតាទៅតាមពេល

---

37 *រដ្ឋអាជ្ញា តទល់នឹង* Hadžihasanović *និងអ្នកដទៃទៀត, សំណុំរឿងលេខ* IT-01-47-AR72 សាលដីកាលើបណ្ដឹងសាទុក្ខបន្ទាន់បន្ទំ ជំទាស់នឹងយុត្តាធិការ ពាក់ព័ន្ធការទទួលខុសត្រូវរបស់ថ្នាក់លើ, ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០០៣, ("សេចក្ដីសម្រេច *Hadžihasanović* ") កថាខណ្ឌ ៣៤។

38 *រដ្ឋអាជ្ញា តទល់នឹង* Hadžihasanović *និងអ្នកដទៃទៀត, សំណុំរឿងលេខ* IT-01-47-AR72 សាលដីកាលើបណ្ដឹងសាទុក្ខបន្ទាន់បន្ទំ ជំទាស់នឹងយុត្តាធិការ ពាក់ព័ន្ធការទទួលខុសត្រូវរបស់ថ្នាក់លើ, ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០០៣, ("សេចក្ដីសម្រេច *Hadžihasanović* ") កថាខណ្ឌ ៣៤។

39 *រដ្ឋអាជ្ញា តទល់នឹង* Hadžihasanović *និងអ្នកដទៃទៀត, សំណុំរឿងលេខ* IT-01-47-PT សេចក្ដីសម្រេចលើការជំទាស់ចំពោះយុត្តាធិការ (អង្គជំនុំជម្រះ), ចុះថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០០២, ("សេចក្ដីសម្រេច *Hadžihasanović* ") កថាខណ្ឌ ៦២។

វេលា។ ដោយគ្រាន់តែលើកយកឧទាហរណ៍តែមួយមកបង្ហាញ វាជាការរារាំងដល់ផលប្រយោជន៍យុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ ក្នុងការដកចេញការចោទប្រកាន់លើបទរំលោភបំពានផ្លូវភេទ ដោយគ្រាន់តែដោយសារតែការប្រព្រឹត្តិបទឧក្រិដ្ឋ ដែលមានលក្ខណៈផ្លូវភេទដែលពាក់ព័ន្ធ មិនត្រូវទៅតាមនិយមន័យនៃការរំលោភបំពានផ្លូវភេទ នៅក្នុងយុត្តាធិការមួយចំនួន នៅពេលដែលមានការប្រព្រឹត្តិនោះ។ នៅក្នុងរឿងក្តី *Furundžija* អង្គជំនុំជម្រះបានផ្តន្ទាទោសជនជាប់ចោទពីបទរំលោភបំពានផ្លូវភេទ ដោយផ្អែកលើការប្រព្រឹត្តិរបស់គាត់ ដែលពាក់ព័ន្ធដល់ការរួមភេទតាមមាត់ដោយបង្ខំ។ ទោះបីជាអង្គជំនុំជម្រះទទួលស្គាល់ថា ការរួមភេទតាមមាត់ដោយបង្ខំបែបនេះ អាចមិនត្រូវបានចាត់ទុកថាជាការរំលោភបំពានផ្លូវភេទ នៅក្នុងអតីតប្រទេសយូហ្គោស្លាវី ឬនៅក្នុងយុត្តាធិការដទៃទៀតជាច្រើន នៅពេលដែលអំពើនេះត្រូវបានប្រព្រឹត្តក៏ដោយ ប៉ុន្តែអង្គជំនុំជម្រះបានសម្រេចថា៖

> *អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា មិនមែនជាការផ្ទុយទៅនឹងគោលការណ៍ទូទៅនៃគោលការណ៍គ្មានបទល្មើស បើគ្មានច្បាប់ចែងទេ ក្នុងការធ្វើការចោទប្រកាន់ជនជាប់ចោទចំពោះការរួមភេទតាមមាត់ដោយបង្ខំ ថាជាការរំលោភបំពានផ្លូវភេទនោះ នៅពេលដែលក្នុងយុត្តាធិការជាតិមួយចំនួន រួមទាំងយុត្តាធិការនៃប្រទេសរបស់គាត់ផ្ទាល់ គាត់អាចត្រូវបានចោទប្រកាន់ត្រឹមតែការបំពារបំពានផ្លូវភេទចំពោះអំពើដូចគ្នានេះ។ នេះមិនមែនជាបញ្ហានៃការកំណត់ជាបទឧក្រិដ្ឋ ចំពោះអំពើដែលមិនមែនជាអំពើឧក្រិដ្ឋ នៅពេលជនជាប់ចោទប្រព្រឹត្តអំពើនោះទេ ព្រោះការរួមភេទតាមមាត់ដោយបង្ខំ ទោះជាក្នុងករណីណាក៏ដោយ គឺជាបទឧក្រិដ្ឋ ហើយតាមពិតទៅជាបទឧក្រិដ្ឋយ៉ាងធ្ងន់ធ្ងរទៀតផង*[40] ។

18. ដោយអនុលោមតាមទស្សនៈនេះ តុលាការបានសម្រេចថា គោលការណ៍គ្មានបទល្មើស បើគ្មានច្បាប់ចែង មិនត្រូវបានរំលោភបំពាន ដោយការ "បញ្ជាក់បំភ្លឺបន្តិចម្តងៗ" អំពីវិធាននៃការទទួលខុសត្រូវព្រហ្មទណ្ឌ តាមរយៈការបកស្រាយរបស់តុលាការ[41]។ ដូចដែលអង្គជំនុំជម្រះក្នុងរឿងក្តី

[40] *រដ្ឋអាជ្ញា តទល់នឹង* Anto Furundžija, *សំណុំរឿងលេខ* IT-95-17/1-T, សាលក្រម (អង្គជំនុំជម្រះ), ចុះថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ១៩៩៨, កថាខណ្ឌ ១៨៥។

[41] សូមមើល តុលាការអឺរ៉ុបសម្រាប់សិទ្ធិមនុស្ស, *S.W. តទល់នឹង ចក្រភពអង់គ្លេស, សាលក្រម តុលាកាការសិទ្ធិមនុស្សអឺរ៉ុប,* កថាខណ្ឌ៣៦ ចុះថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥, (បកស្រាយមាត្រា ៧(១) នៃអនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស ដែលចែងជាផ្នែក "មិនមានបុគ្គលណាម្នាក់ត្រូវមានពិរុទ្ធភាពចំពោះបទល្មើសព្រហ្មទណ្ឌណាមួយ ដែលផ្អែកលើអំពើសកម្ម ឬអកម្ម ដែលមិនអាចចាត់ទុកថាជាបទល្មើសព្រហ្មទណ្ឌ តាមច្បាប់ជាតិ ឬច្បាប់អន្តរជាតិ នៅពេលដែលអំពើនោះត្រូវបានប្រព្រឹត្ត")។ សូមមើលផង

*Hadžiha sanović* បានបញ្ជាក់ "មិនមានភាពចាំបាច់ដែលថា ធាតុផ្សំនៃបទល្មើសមួយត្រូវបានកំណត់នោះទេ ប៉ុន្តែការពិពណ៌នាជាទូទៅពីការប្រព្រឹត្តិដែលត្រូវហាមឃាត់ បានកំណត់"[42]។ ចំណុចនេះគឺពិតជាត្រឹមត្រូវនៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ។ អង្គជំនុំជម្រះក្នុងរឿងក្តី*Karemera* បានសម្រេចថា "ដោយសារតែភាពជាក់លាក់នៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិ គោលការណ៍នីត្យានុកូលភាព មិនអាចអនុវត្តចំពោះច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ក្នុងកម្រិតមួយដូចនឹងការអនុវត្តនៅក្នុងប្រព័ន្ធគតិយុត្តិថ្នាក់ជាតិខ្លះៗនោះឡើយ"[43] ហើយអង្គជំនុំជម្រះ ក្នុងរឿងក្តី *Mucić* និងគូកន *Celibici* បានសម្រេចប្រហែលគ្នានេះថា៖

> *អាចមានការសន្និដ្ឋានថា គោលការណ៍នីត្យានុកូលភាព ក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ខុសពីប្រព័ន្ធគតិយុត្តិជាតិដែលពាក់ព័ន្ធ ត្រង់ការអនុវត្ត និងបទដ្ឋានរបស់គោលការណ៍នីត្យានុកូលភាពទាំងនោះ។ គោលការណ៍ទាំងនេះហាក់ខុសប្លែកពីគេ ត្រង់គោលដៅដ៏ច្បាស់លាស់ក្នុងការរក្សាតុល្យភាពរវាងការថែរក្សាយុត្តិធម៌ចំពោះជនជាប់ចោទ និងការគិតគូរដល់ការថែរក្សាសណ្តាប់ធ្នាប់ពិភពលោក*[44] ។

19. លើសពីនេះទៀត ភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋនៅក្នុងយុត្តាធិការនៃ អ.វ.ត.ក បានផ្តល់នូវការការពារបន្ថែមទៀតប្រឆាំងនឹងការរំលោភបំពានណាមួយទៅលើ គោលការណ៍*គ្មានបទល្មើស បើគ្មានច្បាប់ចែង* ដោយលើកកំពស់ភាពអាចប្រមើលមើលបានពីឧក្រិដ្ឋភាពនៃអំពើ។ អង្គជំនុំជម្រះតុលាការកំពូលធ្លាប់បានសម្រេចកន្លងមកថា "ថ្វីត្បិតតែអំពើអសីលធម៌ ឬអំពើដែលមានចរិតលក្ខណៈគួរឲ្យរន្ធត់ មិនអាចចាត់ជាកត្តាគ្រប់គ្រាន់ ដើម្បីកំណត់ថាជាបទល្មើសព្រហ្មទណ្ឌក៏ដោយ ក៏អំពើបែប

ដែរ តុលាការអឺរ៉ុបសម្រាប់សិទ្ធិមនុស្ស រឿងក្តី *Streletz, Kessler និង Krenz តទល់នឹង អាល្លឺម៉ង់, សាលក្រម,* ចុះថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០០១, កថាខណ្ឌ ៨៩។

[42] *រដ្ឋអាជ្ញា តទល់នឹង Hadžihasanović និងអ្នកដទៃទៀត,* Case No. IT-01-47 សេចក្តីសម្រេចលើការជំទាស់ចំពោះយុត្តាធិការ (អង្គជំនុំជម្រះ), ចុះថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០០២, ("សេចក្តីសម្រេច *Hadžihasanović* ") កថាខណ្ឌ ៥៨ ដកស្រង់ តុលាការអឺរ៉ុបសម្រាប់សិទ្ធិមនុស្ស, S. *W.តទល់នឹង UK សាលក្រម ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ១៩៩៥,* កថាខណ្ឌ ៣៥, និង *Kokkinakis តទល់នឹង* ប្រទេសក្រិច (ឆ្នាំ១៩៩៣) សាលក្រម ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ១៩៩៣, កថាខណ្ឌ ៥២។

[43] *រដ្ឋអាជ្ញា តទល់នឹង Édouard Karemera និងអ្នកដទៃទៀត,* Case No. ICTR-98-44-T សេចក្តីសម្រេចលើសារណាបឋមរបស់មេធាវីការពារក្តី Joseph Nzirorera, Edouard Karemera, Andre Rwamakuba និង Matheieu Ngirumpatze ជំទាស់យុត្តាធិការពាក់ព័ន្ធដល់សហឧក្រិដ្ឋកម្មរួម, *(អង្គជំនុំជម្រះ III)* ចុះថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០០៤, កថាខណ្ឌ ៤៣។

[44] *រដ្ឋអាជ្ញា តទល់នឹង Zenjil Delalić និងអ្នកដទៃទៀត,* Case No. IT-96-21-T សាលក្រម *(អង្គជំនុំជម្រះស្ទួន III)* , ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨, (សាលក្រម *Celebići*) កថាខណ្ឌ ៤០៥។

នេះ អាចដើរតួនាទីមួយ ក្នុងការបដិសេធចំពោះការអះអាងណាមួយរបស់មេធាវីការពារក្តីដែលថា ខ្លួនមិនបានដឹងអំពីចរិតព្រហ្មទណ្ឌនៃអំពើនោះដែរ"[45]។ អង្គជំនុំជម្រះតុលាការកំពូលក្នុងរឿងក្តី *Mucić* និងគូកន *Celibici* បានពន្យល់ថាតើភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋដែលត្រូវដោះស្រាយក្នុងតុលាការឧក្រិដ្ឋកម្មសង្គ្រាម ដោយរបៀបណាជាមួយគោលការណ៍នីត្យានុកូលភាព ដោយអង្គជំនុំជម្រះបានកត់សម្គាល់ថា៖

> *គោលការណ៍គ្មានបទល្មើស បើគ្មានច្បាប់ចែង មិនបានរារាំងតុលាការមិនឱ្យបកស្រាយ និងបញ្ជាក់បំភ្លឺទៅលើធាតុផ្សំនៃឧក្រិដ្ឋកម្មជាក់លាក់មួយឡើយ។ មានការទទួលស្គាល់ជាសកលថា អំពើដូចមានចែងក្នុងមាត្រាបីទូទៅ គឺជាអំពើមិនត្រឹមត្រូវ និងធ្វើឱ្យមនុស្សដែលមានអរិយធម៌មានការរន្ធត់ ហេតុដូច្នេះ តាមពាក្យពេចន៍នៃមាត្រា ១៥(២) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ "គឺជាបទឧក្រិដ្ឋ យោងតាមគោលការណ៍ទូទៅនៃច្បាប់ ដែលត្រូវបានទទួលស្គាល់ដោយបណ្តាជាតិដែលមានអរិយធម៌"[46]។*

20. តាមចរិតលក្ខណៈនៃយុត្តាធិការរបស់ អ.វ.ត.ក ឧក្រិដ្ឋកម្មទាំងអស់ដែលត្រូវបានចោទប្រកាន់នៅ អ.វ.ត.ក មានភាពធ្ងន់ធ្ងរក្រៃលែង។ ហេតុដូច្នេះ សហឧក្រិដ្ឋកម្មរួម ទម្រង់ទីបី តម្រូវឱ្យមានភស្តុតាងហួសពីវិមតិសង្ស័យដែលជនជាប់ចោទបានចូលរួមប្រព្រឹត្តបទល្មើសដោយចេតនាដែលស្ថិតក្នុងយុត្តាធិការរបស់តុលាការនេះ ហើយបានរួមចំណែកដោយចេតនាយ៉ាងសំខាន់ក្នុងការសម្រេចផែនការរួមនេះ។ មិនមានហានិភ័យទេដែលថា ជនជាប់ចោទក្នុងទម្រង់ទីបី នៃសហឧក្រិដ្ឋកម្មរួមអាចមិនបានដឹងថា អំពើល្មើសរបស់ខ្លួនជាបទឧក្រិដ្ឋ ប្រសិនបើខ្លួនត្រូវទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលព្យាករបាន។ ដូនេះ ពិបាកយល់ណាស់ថា តុលាការមួយអាចកំណត់បុគ្គលម្នាក់ដែលចូលរួមយ៉ាងច្រើនដោយចេតនា ក្នុងការបន្ថែមបទឧក្រិដ្ឋមួយក្នុងយុត្តាធិការរបស់ អវតក ដូចដែរតម្រូវដោយសហឧក្រិដ្ឋកម្មរួមទម្រង់ទីបី មិនអាចយល់ថាអំពើរបស់ខ្លួនជាបទឧក្រិដ្ឋនោះ។

21. សហឧក្រិដ្ឋកម្មរួម ទម្រង់ទីបី គ្រាន់តែពង្រីកបន្ថែមលើការទទួលខុសត្រូវចំពោះជនទាំងឡាយណា

[45] ឯកសារ **F28** សាលដីកា, ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១២, កថាខណ្ឌ ៩៦ ដកស្រង់រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Milan Milutinović និងអ្នកដទៃទៀត*, Case No. IT-99-37-AR72, សាលដីកាលើសារណារបស់ Dragoljub Ojdanić ជំទាស់យុត្តាធិការ- សហឧក្រិដ្ឋកម្មរួម, (អង្គជំនុំជម្រះឧទ្ធរណ៍) ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០០៣, កថាខណ្ឌ ៤២។

[46] *រដ្ឋអាជ្ញា តទល់នឹង Zenjil Delalić និងអ្នកដទៃទៀត*, Case No. IT-96-21-T សាលដីកា (អង្គជំនុំជម្រះឧទ្ធរណ៍), ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០០១, ("សាលដីកា *Celebići*") កថាខណ្ឌ ១៧៣។

ដែលបានចូលរួមចំណែកយ៉ាងសំខាន់ក្នុងសហឧក្រិដ្ឋកម្មរួម ដោយមានចេតនារួមគ្នាក្នុងការប្រព្រឹត្តិបទឧក្រិដ្ឋយ៉ាងហោចណាស់ត្រឹមមួយ ដែលស្ថិតក្នុងលក្ខន្តិកៈរបស់តុលាការ បន្ថែមលើឧក្រិដ្ឋកម្មដែលជនជាប់ចោទអាចប្រមើលមើលបានដោយសមហេតុផល អាចកើតចេញពីផែនការនោះ។ ឧទាហរណ៍ ជនជាប់ចោទមួយរូបដែលបានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការរៀបចំផែនការឧក្រិដ្ឋ ដើម្បីជម្លៀសប្រជាជនស៊ីវិលជាទ្រង់ទ្រាយធំ ដោយបង្ខំ ក្នុងស្ថានភាពលំបាកលំបិន នឹងត្រូវទទួលខុសត្រូវចំពោះការស្លាប់ ដែលគាត់អាចប្រមើលមើលឃើញដោយសមហេតុផល អាចកើតចេញពីការអនុវត្តផែនការនេះ។ ស្រដៀងគ្នានេះ ជនជាប់ចោទម្នាក់ដែលបានរួមចំណែកក្នុងសហឧក្រិដ្ឋកម្មរួមនៃការដាក់ឲ្យទៅជាទាសករ និងការធ្វើទុក្ខបុកម្នេញប្រជាជនស៊ីវិល រួមបញ្ចូលទាំងកុមារី និងស្ត្រីវ័យក្មេង ឬ ការបង្ខំឲ្យបុរស ស្ត្រីរៀបការ ដោយផ្ទុយនឹងឆន្ទៈរបស់ពួកគេ អាចទទួលខុសត្រូវចំពោះបទឧក្រិដ្ឋរំលោភបំពានលើផ្លូវភេទ ដែលជនជាប់ចោទអាចប្រមើលដោយសមហេតុសមផលថានឹងកើតចេញពីការអនុវត្តផែនការនេះ។

22. ហេតុដូច្នេះ ចំពោះគោលបំណងនៃគោលការណ៍*គ្មានបទល្មើស បើគ្មានច្បាប់ចែង* មិនមានភាពចាំបាច់នោះឡើយ ក្នុងការពិចារណាថាតើ ការទទួលខុសត្រូវចំពោះសហឧក្រិដ្ឋកម្មរួម ដូចដែលមាននៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ មុនឆ្នាំ១៩៧៥ បានពង្រីកដល់ឧក្រិដ្ឋកម្មដែលអាចប្រមើលមើលបានដែរ ឬយ៉ាងណា ដែលឧក្រិដ្ឋកម្មទាំងនោះស្ថិតក្រៅផែនការរួម (សហឧក្រិដ្ឋកម្មរួម ទម្រង់ទីបី)។ ការប្រព្រឹត្តិបទឧក្រិដ្ឋ ដូចដែលត្រូវបានកំណត់សម្រាប់សហឧក្រិដ្ឋកម្មរួម ទម្រង់ទីបី គឺដូចគ្នាបេះបិទនឹងទម្រង់ទីមួយនៃសហឧក្រិដ្ឋកម្មរួម៖ ជាសមាជិកនៅក្នុងសហឧក្រិដ្ឋកម្មរួមដែលមានចេតនារួមគ្នាក្នុងការប្រព្រឹត្តិបទឧក្រិដ្ឋដែលស្ថិតក្នុងយុត្តាធិការរបស់ អ.វ.ត.ក ហើយបានចូលរួមចំណែកយ៉ាងសំខាន់ដល់សហឧក្រិដ្ឋកម្មនោះ។ មិនមានគ្រោះថ្នាក់ដែលថា បុគ្គលម្នាក់ដែលអាចត្រូវបានផ្តន្ទាទោសនៅ អ.វ.ត.ក ផ្អែកលើសហឧក្រិដ្ឋកម្មរួម ទម្រង់ទីបី ហើយគាត់មិនបានដឹងថា អំពើដែលគាត់បានប្រព្រឹត្តគឺជាបទឧក្រិដ្ឋ នៅពេលនោះឡើយ។ ការពង្រីកការទទួលខុសត្រូវចំពោះអ្នកដែលចូលរួមក្នុងសហឧក្រិដ្ឋកម្មរួមចំពោះបទល្មើសដែលប្រព្រឹត្តដោយសមាជិកផ្សេងទៀតនៃទទួលខុសត្រូវចំពោះសហឧក្រិដ្ឋកម្មរួមទម្រង់ទីបី អាចរំលោភបំពានទៅលើគោលការណ៍*គ្មានបទល្មើស បើគ្មានច្បាប់ចែង* និងដូច្នេះ ប្រសិនបើទម្រង់ទី១ នៃសហឧក្រិដ្ឋកម្មរួមគឺជាទម្រង់នៃការទទួលខុសត្រូវដែលមានសុពលភាពនៅ អវតក នោះសហឧក្រិដ្ឋកម្មរួមទម្រង់ទី៣ត្រូវតែអនុវត្តបានផងដែរ។ លើសពីនេះទៀត សហព្រះរាជអាជ្ញានឹងបង្ហាញនៅផ្នែកខាងក្រោមថា ទម្រង់ទូលាយនៃសហឧក្រិដ្ឋកម្មរួម មានមូលដ្ឋានត្រឹមត្រូវច្បាស់លាស់នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ តាំងពីពេលមុនយុត្តាធិការរបស់តុលាការនេះ ហើយអង្គជំនុំជម្រះសាលាដំបូងមាន

កំហុសឆ្គង ក្នុងការមិនទទួលស្គាល់អង្គហេតុនេះ។

## គ.ការទទួលខុសត្រូវក្នុងទម្រង់ III នៃសហឧក្រិដ្ឋកម្មរួមបានបង្កើតនៅក្នុងច្បាប់ទំលាមទម្លាប់អន្តរជាតិក្រោយសង្គ្រាមលោកលើកទី២

23. ការខិតខំប្រឹងប្រែងជាអន្តរជាតិដ៏សំខាន់ដំបូងបំផុតក្នុងការជំនុំជម្រះឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលបានប្រព្រឹត្តឡើងក្នុងទ្រង់ទ្រាយធំ បានធ្វើឡើងក្រោយសង្គ្រាមលោកលើកទីពីរ។ រឿងក្តីនៃការជំនុំជម្រះទាំងនេះគឺជាយុត្តិសាស្ត្រដ៏ល្អសម្រាប់ធាតុផ្សំនៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ចាប់តាំងពីពេលនោះមក។ ផ្ទុយទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូង[47] ទម្រង់ទាំងអស់នៃសហឧក្រិដ្ឋកម្មរួម រួមទាំងទម្រង់ទីបី ត្រូវបានកំណត់យ៉ាងច្បាស់លាស់នៅក្នុងយុត្តិសាស្ត្ររបស់តុលាការនានា ដែលដោះស្រាយរឿងក្តីទាំងអស់នេះ។ យុត្តិសាស្ត្ររបស់តុលាការយោធាអន្តរជាតិ Nuremberg ("តុលាការ Nuremberg") តុលាការយោធាអាមេរិក និងអង់គ្លេស ដែលប្រតិបត្តិការក្រោមច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង (កិច្ចព្រមព្រៀងជាអន្តរជាតិមួយ សម្រាប់ការជំនុំជម្រះទាំងឡាយសម្រាប់រដ្ឋមួយ ដែលបានចោទប្រកាន់ពីបទឧក្រិដ្ឋកម្មសង្គ្រាម) ព្រមទាំងតុលាការ Batavia នៅអាស៊ីអាគ្នេយ៍ បានបង្ហាញយ៉ាងច្បាស់ថា សហឧក្រិដ្ឋកម្មរួមទម្រង់ទីបី ត្រូវបានទទួលស្គាល់ថាជាទម្រង់នៃការទទួលខុសត្រូវក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ។

24. សារៈសំខាន់របស់តុលាការដែលបង្កើតឡើងក្រោយសង្គ្រាមទាំងនេះ ត្រូវបានបញ្ជាក់ដោយគណៈកម្មាធិការច្បាប់អន្តរជាតិរបស់អង្គការសហប្រជាជាតិ[48] ព្រមទាំងតាមរយៈការអនុម័តរបស់មហាសន្និបាតអង្គការសហប្រជាជាតិ ទៅលើគោលការណ៍នៃធម្មនុញ្ញ Nuremberg ។ ការដែលស្ថាប័នទាំងពីរបញ្ជាក់ថា ច្បាប់សារធាតុ និងទ្រឹស្តីនៃការទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គល (រួមទាំង ការ

[47] ឯកសារ **E100.6** សេចក្តីសម្រេចស្តីពីការអនុវត្តសហឧក្រិដ្ឋកម្មរួម ថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១១ "សេចក្តីសម្រេចរបស់អង្គជំនុំជម្រះ" ត្រង់កថាខណ្ឌ ២៩ ដល់៣៥។

[48] *របាយការណ៍គណៈកម្មាធិការច្បាប់អន្តរជាតិ ស្តីពីលទ្ធផលការងារនៃកិច្ចប្រជុំលើកទីសែសិបប្រាំបីរបស់ខ្លួន*, ចុះថ្ងៃទី ០៦ ខែឧសភា ដល់ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៩៦, ទំព័រ១៩ (រៀបរាប់ពីគោលការណ៍នៃការទទួលខុសត្រូវជាបុគ្គល ព្រមទាំងការដាក់ទណ្ឌកម្មចំពោះឧក្រិដ្ឋកម្ម តាមច្បាប់អន្តរជាតិដែលត្រូវបានទទួលស្គាល់នៅ Nuremberg ថាជា "ចំណុចគោលនៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិ) និងជា "គ្រឹះដ៏ពិតដែលដ៏ចិតថេររបស់ធម្មនុញ្ញ និងសាលក្រមតុលាការ Nuremberg")។

ទទួលខុសត្រូវលើ "ផែនការរួម") បានបង្កើតជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ[49]។

25. ការដែលសាលក្រមរឿងក្តី WWII ទាំងអស់នេះ ជាញឹកញាប់មិនបានបញ្ជាក់ច្បាស់លាស់ពីទម្រង់ជាក់ស្តែងនៃការទទួលខុសត្រូវដែលត្រូវបានអនុវត្ត ឬក៏ពាក្យបច្ចេកទេសដែលត្រូវបានប្រើប្រាស់ ហើយមានភាពខុសគ្នាពីពាក្យដែលបានប្រើប្រាស់បច្ចុប្បន្ន មិនបានរារាំងអ្នកអានដែលយកចិត្តទុកដាក់ មិនឱ្យធ្វើការសន្និដ្ឋានថា ទម្រង់នៃការទទួលខុសត្រូវ ដែលជាប់ពាក់ព័ន្ធនឹងសហឧក្រិដ្ឋកម្មរួម ទម្រង់ទីបី ត្រូវបានអនុវត្តចំពោះរឿងក្តីទាំងអស់នេះឡើយ។ ការប្រើប្រាស់ការទទួលខុសត្រូវលើសហឧក្រិដ្ឋកម្មរួម ទម្រង់ទីបី អាចបង្ហាញបាននៅពេលដែលការយល់ឃើញរបស់តុលាការលើទម្រង់នៃការចូលរួមរបស់ជនជាប់ចោទ ព្រមទាំងស្ថានភាពផ្លូវចិត្ត បូករួមជាមួយនឹងអង្គហេតុនៃរឿងក្តី បានបំពេញតាមធាតុផ្សំស្នូលនៃសហឧក្រិដ្ឋកម្មរួមទម្រង់ទីបី។

26. ដូចដែលបានកត់សម្គាល់ដោយអង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY ក្នុងរឿងក្តី *Tadić* ភស្តុតាងនៃការប្រើប្រាស់សហឧក្រិដ្ឋកម្មរួម ទម្រង់ទីបី នៅក្នុងរឿងក្តីទាំងនេះ ចាប់ផ្តើមឡើងដោយលិខិតុបករណ៍ដែលបង្កើតតុលាការទាំងនេះ។ ធម្មនុញ្ញទីក្រុងឡុងដ៍របស់តុលាការយោធាអន្តរជាតិ[50] និងធម្មនុញ្ញរបស់តុលាការយោធាអន្តរជាតិសម្រាប់ចុងបូព៌ា[51] ប្រើប្រាស់ពាក្យពេចន៍ដូចគ្នា ដោយចែងថា "មេដឹកនាំ អ្នករៀបចំ អ្នកញុះញង់ និងអ្នកសមគំនិត ដែលចូលរួមក្នុងការបង្កើត និងអនុវត្តផែនការរួម ឬសមគំនិតក្នុងការប្រព្រឹត្តបទឧក្រិដ្ឋកន្លងមក ត្រូវទទួលខុសត្រូវចំពោះអំពើទាំងអស់ ដែលបានធ្វើឡើងដោយបុគ្គលណាក៏ដោយ ក្នុងការអនុវត្តផែនការបែបនេះ"។ ពាក្យពេចន៍នេះ "អំពើទាំងអស់ ដែលបានធ្វើឡើងដោយបុគ្គលណាក៏ដោយ ក្នុងការអនុវត្ត" គឺសំដៅហួសពីទម្រង់ទីមួយ នៃសហឧក្រិដ្ឋកម្មរួម ដែលដាក់ការទទួលខុសត្រូវព្រហ្មទណ្ឌ តែទៅលើ

---

[49] សេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិ 95(I), 1946 ការបញ្ជាក់ពីគោលការណ៍នៃច្បាប់អន្តរជាតិដែលបានទទួលស្គាល់ដោយធម្មនុញ្ញរបស់តុលាការ Nuremberg ត្រង់ ១៨៨ (សេចក្តីសម្រេចស្តីពីគោលការណ៍របស់ Nuremberg) បានបង្គាប់ដល់គណៈកម្មាធិការច្បាប់អន្តរជាតិរបស់អង្គការសហប្រជាជាតិ ("ILC") ឱ្យរៀបចំគោលការណ៍ទាំងអស់នេះទៅជាក្រមអន្តរជាតិស្តីពីបទល្មើស ប្រឆាំងនឹងសន្តិភាព និងសន្តិសុខ មនុស្សជាតិ។ សេចក្តីព្រាងលើកទីមួយរបស់ ILC អំពីក្រមក្នុងឆ្នាំ ១៩៥៦ បានរួមបញ្ចូល ជាពិសេស "គោលការណ៍នៃការទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គល ចំពោះការបង្កើតផែនការ ឬការចូលរួមក្នុងផែនការរួម ឬការសមគំនិតក្នុងការប្រព្រឹត្តបទឧក្រិដ្ឋ" (មាត្រា ២, កថាខណ្ឌ ១៣(i))។ *របាយការណ៍គណៈកម្មាធិការច្បាប់អន្តរជាតិ ស្តីពីលទ្ធផលការងារនៃកិច្ចប្រជុំលើកទី សែសិបប្រាំបី របស់ខ្លួន*, ចុះថ្ងៃទី ០៦ ខែ ឧសភា ដល់ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៩៦, ត្រង់ទំព័រ ២១)។

[50] ធម្មនុញ្ញទីក្រុងឡុងដ៍ របស់តុលាការយោធាអន្តរជាតិ, ចុះថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ១៩៤៥, មាត្រា ៦។

[51] ធម្មនុញ្ញរបស់តុលាការយោធាអន្តរជាតិសម្រាប់ចុងបូព៌ា, ចុះថ្ងៃទី ១៩ ខែ មករា ឆ្នាំ ១៩៤៦, មាត្រា ៥។

សមាជិកនៃសហឧក្រិដ្ឋកម្មនៃបទឧក្រិដ្ឋដែលស្ថិតក្នុងផែនការរួមប៉ុណ្ណោះ។ ប្រហាក់ប្រហែលគ្នាដែរ ច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រងចែងថា បុគ្គលណាក៏ដោយ ត្រូវចាត់ទុកថាបានប្រព្រឹត្ត បទឧក្រិដ្ឋ បើបុគ្គលនោះ "មានទំនាក់ទំនងជាមួយផែនការ ឬសហឧក្រិដ្ឋកម្ម ដែលពាក់ព័ន្ធដល់ការ ប្រព្រឹត្តិឧក្រិដ្ឋកម្មនោះ"[52]។

27. យុត្តិសាស្ត្ររបស់តុលាការទាំងអស់នេះ បញ្ជាក់បន្ថែមទៀតថា សហឧក្រិដ្ឋកម្មរួម ទម្រង់ទីបី គឺជា ទម្រង់នៃការទទួលខុសត្រូវដែលត្រូវបានទទួលស្គាល់ ដែលកំណត់ឲ្យបុគ្គលណាម្នាក់ ជាពិសេស មេដឹកនាំត្រូវទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលអាចប្រមើលមើលបានថា អាចកើតចេញពីសហ ឧក្រិដ្ឋកម្ម។ សាលក្រមរបស់តុលាការយោធាអន្តរជាតិបានដាក់ការទទួលខុសត្រូវព្រហ្មទណ្ឌ ចំពោះជនណាដែលបានរួមចំណែកដោយចេតនានៅក្នុងសហឧក្រិដ្ឋកម្ម នៃបទឧក្រិដ្ឋដែលពួកគេ មិនមានចេតនាឲ្យកើត ប្រសិនបើពួកគេបានដឹងឮ ឬអាចប្រមើលមើលថា មានលទ្ធភាពដែល ឧក្រិដ្ឋកម្មទាំងនេះ អាចកើតឡើងដោយសារតែសហឧក្រិដ្ឋកម្ម។ ទោះបីជាសាលក្រមនេះដោះ ស្រាយចំពោះបុគ្គលដែលចូលរួមពាក់ព័ន្ធក្នុងផ្នែកផ្សេងៗគ្នាជាច្រើន នៃយុទ្ធនាការបទឧក្រិដ្ឋរបស់ ណាហ្ស៊ី គិតចាប់ពីជនស៊ីវិលដែលពាក់ព័ន្ធនឹងការប្រើប្រាស់ពលកម្មទាសករ អ្នកគ្រប់គ្រង រដ្ឋបាលតំបន់ដែលជនជាតិជ្វីហ និងជនជតិភាគតិចដទៃទៀត ត្រូវបានកំណត់ជាមុខសញ្ញាសម្រាប់ ការផ្តាច់ពូជ រហូតដល់ឧត្តមនាវី និងឧត្តមសេនីយ៍ដែលទទួលខុសត្រូវក្នុងការសម្លាប់ឈ្លើយសឹក តែចំណុចនេះមានភាពច្បាស់លាស់ណាស់ថា ការផ្តន្ទាទោសចំពោះបុគ្គលនីមួយៗ មិនបានបញ្ជាក់ ច្បាស់លាស់ចំពោះបទឧក្រិដ្ឋជាក់លាក់ ដែលពួកគេត្រូវបានផ្តន្ទាទោសឡើយ ក្រៅពីថាជាបទ ឧក្រិដ្ឋសង្គ្រាម (បទចោទបី) ឬឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ (បទចោទបួន)។ ហេតុដូច្នេះ ជន ជាប់ចោទនីមួយៗ ដែលបានចូលរួមចំណែកដោយចេតនាចំពោះសហឧក្រិដ្ឋកម្មរបស់ណាហ្ស៊ីទាំង អស់ ត្រូវបានផ្តន្ទាទោសចំពោះបទឧក្រិដ្ឋទាំងអស់ ដែលបណ្តាលមកពីសហកម្មនោះ ដោយមិន មានការពិភាក្សាថាតើ បុគ្គលម្នាក់ៗ មានចេតនាចំពោះឧក្រិដ្ឋកម្មនីមួយៗដែរ ឬទេនោះឡើយ។

28. ការអនុវត្តការទទួលខុសត្រូវចំពោះសហឧក្រិដ្ឋកម្មរួម ទម្រង់ទីបី រឹតតែមានភាពច្បាស់លាស់ថែម ទៀត នៅក្នុងការផ្តន្ទាទោសជាបុគ្គលដោយតុលាការយោធាអន្តរជាតិ។ ឧទាហរណ៍ Fritz Sauckel ដែលជាឧត្តមសេនីយ៍ពេញសមត្ថភាពសម្រាប់ការប្រើប្រាស់ពលកម្ម ដែលមានសិទ្ធិ

[52] ច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង, មាត្រា II, 2(ឃ) ស្តីពីការផ្តន្ទាទោសឧក្រិដ្ឋកម្មសង្គ្រាម ឧក្រិដ្ឋកម្មប្រឆាំង សន្តិភាព និងប្រឆាំងមនុស្សជាតិ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៤៥។

អំណាចគ្រប់គ្រងលើ "កម្លាំងពលកម្មទាំងអស់ដែលមានរួមទាំងពលករដែលត្រូវបានជ្រើសរើសមកពីក្រៅប្រទេស និងឈ្លើយសឹក"[53]។ សាលក្រមរបស់តុលាការយោធាអន្តរជាតិបានសម្រេចថា Sauckel ដើរតួនាទីយ៉ាងសំខាន់ក្នុងការប្រើប្រាស់ពលកម្មដោយបង្ខំ (ការដាក់ឱ្យទៅជាទាសករ)។ ក៏ប៉ុន្តែ សាលក្រមក៏បានដកស្រង់ការអះអាងដដែលៗរបស់ Sauckel ដែលថាគាត់មិនមានចេតនាចង់ឱ្យពលករទាំងអស់នោះ ត្រូវទទួលរងការប្រព្រឹត្តិអមនុស្សធម៌ ហើយមិនបានព្យាយាមបដិសេធ ឬចោទសួរពីភាពត្រឹមត្រូវនៃការអះអាងនេះឡើយ។ ផ្ទុយទៅវិញ សាលក្រមនេះបានចង្អុលបង្ហាញថា "ទោះបីជា Sauckel មានចេតនាបែបណាក៏ដោយ ហើយបើទោះបីជាគាត់អាចមានបំណងថាពលករបរទេសគួរទទួលបានការប្រព្រឹត្តិបែបមនុស្សធម៌ក៏ដោយ ប៉ុន្តែភស្តុតាងនៅចំពោះមុខតុលាការបានបង្ហាញអង្គហេតុដែលថា ការធ្វើកំណែនពលករ ក្នុងករណីជាច្រើន ត្រូវបានធ្វើឡើងតាមរយៈមធ្យោបាយហិង្សា និងតឹងតែង"[54]។ ទោះបីជាអង្គជំនុំជម្រះយល់ឃើញថា "មិនមានការស្តែងចេញថា គាត់គាំទ្រដល់អំពើសាហាវយង់ឃ្នង ដើម្បីជាប្រយោជន៍ផ្ទាល់ខ្លួន ឬជាអ្នកគាំទ្រដល់កម្មវិធីមួយចំនួន ដូចជាផែនការរបស់ Himmler ក្នុងការសម្លាប់រង្គាល តាមរយៈការធ្វើការងារ" តែ Sauckel "បានដឹងពីវិធីសាស្ត្រគ្មានធម៌មេត្តា ដែលត្រូវបានប្រើប្រាស់ក្នុងការស្វែងរកពលករ"[55] ហើយ "ត្រូវបានជូនដំណឹងអំពីស្ថានភាពដ៏អាក្រក់ ដែលកើតមានឡើង"[56]។ ផ្អែកលើមូលដ្ឋាននៃទម្រង់នៃការចូលរួមនេះ តុលាការយោធាអន្តរជាតិនេះបានសម្រេចផ្តន្ទាទោស Sauckel ចំពោះបទចោទបី និងបទចោទបួន នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម។

29. ទោះបីជាសាលក្រមរបស់តុលាការយោធាអន្តរជាតិ មិនបានប្រើប្រាស់ពាក្យបច្ចេកទេសថ្មីៗសម្រាប់ទម្រង់នៃការទទួលខុសត្រូវក៏ដោយ តែមានភាពច្បាស់លាស់ណាស់ដែលថា Sauckel ក៏ដូចជាជនជាប់ចោទដទៃទៀតនៅចំពោះមុខតុលាការនេះ ត្រូវបានផ្តន្ទាទោសចំពោះឧក្រិដ្ឋកម្មដែលគាត់ខ្លួនឯង មិនមានចេតនានោះឡើយ តែឧក្រិដ្ឋកម្មទាំងនេះត្រូវបានប្រព្រឹត្តឡើង ជាផ្នែកនៃសហ

[53] ការជំនុំជម្រះឧក្រិដ្ឋជនសង្គ្រាមរបស់អាល្លឺម៉ង់ នីតិវិធីរបស់តុលាការយោធាអន្តរជាតិ នៅ Nuremberg ប្រទេសអាល្លឺម៉ង់ ផ្នែក២២ ថ្ងៃទី២២ សីហា ដល់ ថ្ងៃទី១ ខែតុលា ឆ្នាំ១៩៤៦ (សាលក្រមតុលាការយោធាអន្តរជាតិ), ទំព័រ ៤៦១។

[54] ការជំនុំជម្រះឧក្រិដ្ឋជនសង្គ្រាមរបស់អាល្លឺម៉ង់ នីតិវិធីរបស់តុលាការយោធាអន្តរជាតិ នៅ Nuremberg ប្រទេសអាល្លឺម៉ង់ ផ្នែក២២ ថ្ងៃទី២២ សីហា ដល់ថ្ងៃទី១ ខែតុលា ឆ្នាំ១៩៤៦ (សាលក្រមតុលាការយោធាអន្តរជាតិ), ទំព័រ ៤៦១។

[55] ការជំនុំជម្រះឧក្រិដ្ឋជនសង្គ្រាមរបស់អាល្លឺម៉ង់ នីតិវិធីរបស់តុលាការយោធាអន្តរជាតិ នៅ Nuremberg ប្រទេសអាល្លឺម៉ង់ ផ្នែក២២ ថ្ងៃទី២២ សីហា ដល់ថ្ងៃទី១ ខែតុលា ឆ្នាំ១៩៤៦ (សាលក្រមតុលាការយោធាអន្តរជាតិ), ទំព័រ៥១៥។

[56] ការជំនុំជម្រះឧក្រិដ្ឋជនសង្គ្រាមរបស់អាល្លឺម៉ង់ នីតិវិធីរបស់តុលាការយោធាអន្តរជាតិ នៅ Nuremberg ប្រទេសអាល្លឺម៉ង់ ផ្នែក២២ ថ្ងៃទី២២ សីហា ដល់ថ្ងៃទី១ ខែតុលា ឆ្នាំ១៩៤៦ (សាលក្រមតុលាការយោធាអន្តរជាតិ), ទំព័រ៥១៥។

ឧក្រិដ្ឋកម្ម ដែលគាត់បានចូលរួមចំណែក។ ផ្អែកលើការសម្រេចថា Sauckel មានចេតនាជំរុញកម្មវិធីពលកម្មដោយមិនស្ម័គ្រចិត្ត (ការដាក់ឱ្យទៅជាទាសករ) ហើយគាត់បានរួមចំណែកយ៉ាងសំខាន់ចំពោះការទទួលខុសត្រូវព្រហ្មទណ្ឌ តុលាការបានសម្រេចថា គាត់ត្រូវទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្ម ដែលគាត់មិនមានចេតនាប្រព្រឹត្ត ដោយផ្អែកលើមូលដ្ឋានថា ភស្តុតាងបង្ហាញថា គាត់បានដឹងថាឧក្រិដ្ឋកម្មទាំងអស់នេះប្រហែលជានឹងត្រូវបានប្រព្រឹត្ត។

30. ផ្អែកលើមូលដ្ឋានដូចគ្នានេះ តុលាការបានសម្រេចផ្តន្ទាទោស Albert Speer ពីបទឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ Speer គឺជារដ្ឋមន្ត្រីក្រសួងគ្រឿងសព្វាវុធ និងការបង្កើតសង្គ្រាម នៅក្នុងចក្រភពអាល្លឺម៉ង់ទីបី ហើយបានដឹកនាំទៅដល់កម្មវិធីផលិតកម្មដែលប្រើប្រាស់ពលកម្មទាសករ[57]។ តុលាការបានសម្រេចថា "Speer មិនជាប់ពាក់ព័ន្ធផ្ទាល់ជាមួយនឹងភាពឃោរឃៅក្នុងការគ្រប់គ្រងកម្មវិធីពលកម្មទាសករឡើយ" ហើយម្តងហើយម្តងទៀត "បានទទូចថាពលករទាសករបានទទួលអាហារគ្រប់គ្រាន់ ព្រមទាំងលក្ខខណ្ឌការងារសមរម្យ ដើម្បីឱ្យពួកគេអាចធ្វើការដោយមានប្រសិទ្ធភាព"។ ទោះជាយ៉ាងនេះក្តី គាត់ត្រូវបានផ្តន្ទាទោសពីបទធ្វើទុក្ខទោសចំពោះកម្មករ ព្រោះ "គាត់បានដឹងពីអត្ថិភាពនៃអំពើនេះ [ឧទាហរណ៍ កម្មវិធីពលកម្មទាសករ]"[58]។ ហេតុដូច្នេះ Speer ត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋដែលគាត់មិនមានចេតនា ប៉ុន្តែមានហេតុផលសមស្របដែលថា គាត់អាចប្រមើលមើល ឃើញចំពោះឧក្រិដ្ឋកម្មទាំងនោះ។ ទោះបីជា Speer មានចេតនាច្បាស់លាស់ក្នុងការប្រើប្រាស់ពលកម្មទាសករ ហើយបានរួមចំណែកដល់ផែនការឧក្រិដ្ឋនេះ ប៉ុន្តែគាត់ត្រូវទទួលខុសត្រូវចំពោះការធ្វើទុក្ខទោស ដែលគាត់មិនមានចេតនាឡើយដោយគ្រាន់តែគាត់បានដឹង ដែលនេះគឺជាធាតុផ្សំពិតប្រាកដនៃការទទួលខុសត្រូវលើសហឧក្រិដ្ឋកម្មរួម ទម្រង់ទីបី[59]។

31. សាលដីការឿងក្តី *Tadić* បានពឹងផ្អែកលើការជំនុំជម្រះចំនួនពីរ ដែលធ្វើឡើងក្រោមច្បាប់លេខ ១០

---

[57] សវនាការលើឧក្រិដ្ឋជនសង្គ្រាមសំខាន់ៗ នៅចំពោះមុខតុលាការយោធាអន្តរជាតិ, លេខ ១, សាលក្រម, Nuremberg, ប្រទេសអាល្លឺម៉ង់ ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ដល់ថ្ងៃទី ០១ ខែ តុលា ឆ្នាំ ១៩៤៦ ("រឿងក្តី Speer"), ទំព័រ ៣៣១។

[58] សវនាការលើឧក្រិដ្ឋជនសង្គ្រាមសំខាន់ៗ នៅចំពោះមុខតុលាការយោធាអន្តរជាតិ, លេខ ១, សាលក្រម, Nuremberg, ប្រទេសអាល្លឺម៉ង់ ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ដល់ថ្ងៃទី ០១ ខែ តុលា ឆ្នាំ ១៩៤៦ ("រឿងក្តី Speer"), ទំព័រ ៣៣២ និង៣៣៣។

[59] សវនាការលើឧក្រិដ្ឋជនសង្គ្រាមសំខាន់ៗ នៅចំពោះមុខតុលាការយោធាអន្តរជាតិ, លេខ ១, សាលក្រម, Nuremberg, ប្រទេសអាល្លឺម៉ង់ ផ្នែកទី២២ ចុះថ្ងៃទី២២ ខែសីហា ដល់ថ្ងៃទី ០១ ខែ តុលា ឆ្នាំ ១៩៤៦ ("សាលក្រមតុលាការ"), ទំព័រ ៥២២។

របស់ក្រុមប្រឹក្សាគ្រប់គ្រង។ ការជំនុំជម្រះទីមួយគឺ *រឿងក្តី* Essen Lynching ដែលបានជំនុំជម្រះនៅចំពោះមុខតុលាការតំបន់ដែលត្រួតត្រាដោយអង់គ្លេស។ ក្នុងរឿងក្តីនេះ អនុសេនីយ៍ឯកអាល្លឺម៉ង់បានបង្គាប់ដល់កូនទាហានឱ្យបញ្ជូនឈ្លើសសឹកអង់គ្លេសបីនាក់ ឆ្លងកាត់ទីក្រុង Essen ក្នុងប្រទេសអាល្លឺម៉ង់ ហើយមិនត្រូវធ្វើអន្តរាគមន៍ឡើយ ប្រសិនបើក្រុមប្រជាជនស៊ីវិលវាយដំឈ្លើយសឹកទាំងនោះ[60]។ ប្រជាជនស៊ីវិលបានវាយដំ ហើយសម្លាប់ឈ្លើយសឹកទាំងបីនាក់នោះ។ អនុសេនីយ៍ឯក កូនទាហាន និងជនស៊ីវិលបីនាក់ ត្រូវបានរកឃើញថាមានពិរុទ្ធភាពពីបទមនុស្សឃាត ដែលជាឧក្រិដ្ឋកម្មសង្គ្រាម[61]។ ទោះបីជាមិនមានសាលក្រមជាលាយលក្ខណ៍អក្សរ នៅក្នុងកំណត់ត្រាក៏ដោយ ប៉ុន្តែការវិនិច្ឆ័យ និងការផ្តន្ទាទោសដោយតុលាការ រួមជាមួយទឡ្ហីករណ៍ដែលបានលើកឡើងដោយមេធាវី បានផ្តល់ជាការយល់ដឹងអំពីសំអាងហេតុរបស់តុលាការ[62]។

32. ធាតុផ្សំដ៏សំខាន់នៃសហឧក្រិដ្ឋកម្មរួមទម្រង់ទីបី ត្រូវបានឆ្លុះបញ្ចាំងជាដំបូង នៅក្នុងការផ្តន្ទាទោសអនុសេនីយ៍ឯក និងកូនទាហាន បើទោះបីជាពួកគេមិនបានចូលរួមដោយផ្ទាល់នៅក្នុងឧក្រិដ្ឋកម្មនោះក៏ដោយដែលថាពួកគេយលព្រមឱ្យសម្លាប់អ្នកទោសទាំងនោះ នៅពេលបញ្ជូនពួកគេដោយគ្មានមធ្យោបាយការពារបានសមស្របពីការវាយប្រហារដោយហ្វូងមនុស្ស និងទីពីរគឺ នៅក្នុងការផ្តន្ទាទោសជនស៊ីវិលមួយចំនួន "ព្រោះពួកគេគ្រប់គ្នាបានចូលរួមតាមទម្រង់ផ្សេងៗ នៅក្នុងការធ្វើបាប ដែលចុងក្រោយឈានទៅដល់ការស្លាប់របស់ជនរងគ្រោះ បើទោះបីជាមិនមានជនជាប់ចោទណាម្នាក់ត្រូវបានបង្ហាញភស្តុតាងដោយជាក់ច្បាស់ថា ពួកគេបានបាញ់ដោយផ្ទាល់ ឬបានគប់ដែលបណ្តាលឱ្យស្លាប់នោះទេ"[63]។

---

[60] *របាយការណ៍ស្តីពីការជំនុំជម្រះឧក្រិដ្ឋជនសង្គ្រាមសំខាន់ៗ វ៉ុល១ សង្ខេបនីតិវិធី និងកំណត់សម្គាល់ (តុលាការយោធាអង់គ្លេសសម្រាប់ជំនុំជម្រះឧក្រិដ្ឋជនសង្គ្រាម) ឆ្នាំ១៩៤៧* ("Essen Lynching Case"), ទំព័រ ៨៩។

[61] *របាយការណ៍ស្តីពីការជំនុំជម្រះឧក្រិដ្ឋជនសង្គ្រាមសំខាន់ៗ វ៉ុល១ សង្ខេបនីតិវិធី និងកំណត់សម្គាល់ (តុលាការយោធាអង់គ្លេសសម្រាប់ជំនុំជម្រះឧក្រិដ្ឋជនសង្គ្រាម) ឆ្នាំ១៩៤៧* ("Essen Lynching Case"), ទំព័រ៩០ ៩១។

[62] *របាយការណ៍ស្តីពីការជំនុំជម្រះឧក្រិដ្ឋជនសង្គ្រាមសំខាន់ៗ វ៉ុល១ សង្ខេបនីតិវិធី និងកំណត់សម្គាល់ (តុលាការយោធាអង់គ្លេសសម្រាប់ជំនុំជម្រះឧក្រិដ្ឋជនសង្គ្រាម) ឆ្នាំ១៩៤៧* ("Essen Lynching Case") ទំព័រ ៩១ ។ សូមមើលផងដែរ ប្រតិចារឹក នៅក្នុងការិយាល័យកំណត់ត្រាសាធារណៈ, ទីក្រុងឡុង, WO 235/58, ទំព័រ ៦៥, ដូចដែលបានដកស្រង់ក្នុងរឿងក្តីរដ្ឋអាជ្ញាទល់នឹង *Duško Tadić,* Case No. IT-94-1-A, សាលដីកា (អង្គជំនុំជម្រះឧទ្ធរណ៍) ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៩ ("សាលដីកា Tadić") ទំព័រ ២០៨។

[63] *របាយការណ៍ស្តីពីការជំនុំជម្រះឧក្រិដ្ឋជនសង្គ្រាមសំខាន់ៗ វ៉ុល១ សង្ខេបនីតិវិធី និងកំណត់សម្គាល់ (តុលាការយោធាអង់គ្លេសសម្រាប់ជំនុំជម្រះឧក្រិដ្ឋជនសង្គ្រាម) ឆ្នាំ១៩៤៧* ("Essen Lynching Case") ទំព័រ ៩១។

33. សំអាងហេតុប្រហែលគ្នានេះត្រូវបានយកមកប្រើដោយតុលាការតំបន់ ដែលគ្រប់គ្រងដោយអាមេរិក នៅក្នុងរឿងក្តី *កោះ Borkum*[64] ជារឿងក្តីទីពីរ ដែលត្រូវបានដកស្រង់ក្នុងរឿងក្តី *Tadić* ដើម្បីគាំទ្រដល់ការទទួលខុសត្រូវលើសហឧក្រិដ្ឋកម្មរួមទម្រង់ទីបី។ ក្នុងរឿងក្តីនេះ កងទ័ពអាកាសអាមេរិកមួយក្រុម ត្រូវបានចាប់ខ្លួនក្នុងតំបន់របស់អាល្លឺម៉ង់ ហើយបន្ទាប់មកត្រូវបានបណ្តើរកាត់ទីក្រុង Borkum[65]។ បើទោះបីជាមានវត្តមានរបស់កងទ័ពអាល្លឺម៉ង់ប្រាំពីរនាក់ ដែលត្រូវបានចាត់តាំងឲ្យអមដំណើរអ្នកទោសក៏ដោយ ក៏អ្នកទោសត្រូវបានគេវាយដំ និងចុងក្រោយត្រូវបានបាញ់ស្លាប់ដោយក្រុមប្រជាជនស៊ីវិល និងទាហានអាល្លឺម៉ង់ដែលមិនមានបេសកកម្ម[66]។ តុលាការបានសម្រេចថាជនជាប់ចោទ១៤នាក់ ក្នុងចំណោមជនជាប់ចោទ១៥នាក់ ដោយរួមបញ្ចូលទាំងទាហានដែលអមដំណើរអ្នកទោសនោះ ត្រូវទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ ប៉ុន្តែតុលាការមិនបានចេញសាលក្រម ឬសំអាងហេតុណាមួយចំពោះទម្រង់នៃការទទួលខុសត្រូវដែលបានអនុវត្តនោះឡើយ[67]។ ការផ្តន្ទាទោសទាហានដែលអមដំណើរអ្នកទោស បានបង្ហាញពីសំអាងហេតុនៃសហឧក្រិដ្ឋកម្មរួម ទម្រង់ទីបី៖ ទាហានទាំងនោះមិនបានចូលរួមក្នុងការសម្លាប់ទេ ហើយពួកគេក៏មិនមានចេតនាក្នុងការសម្លាប់អ្នកទោសដែរ។ ប៉ុន្តែ ការបណ្តើរអ្នកទោសឆ្លងកាត់ទីក្រុង ហើយនៅឈរមើល ក្នុងពេលដែលហ្វូងមនុស្សបានវាយដំអ្នកទោសនោះ ផលវិបាកដែលអាចប្រមើលមើលបាន គឺការស្លាប់របស់អ្នកទោស[68]។

---

64 ទោះបីជាមិនបានបោះផ្សាយនៅក្នុងរបាយការណ៍របស់គណៈកម្មាធិការឧក្រិដ្ឋកម្មសង្គ្រាម ប្រចាំអង្គការសហប្រជាជាតិក៏ដោយ ក៏កំណត់ត្រាលម្អិតរបស់រឿងក្តីនេះ អាចរកបានជាសាធារណៈ តាមរយៈការបោះផ្សាយជាមីក្រូហ្វីល នៃបណ្ណាសារជាតិអាមេរិក។ បណ្ណសារជាតិអាមេរិក លេខបោះផ្សាយ, M1103 , កំណត់ត្រាការជំនុំជម្រះឧក្រិដ្ឋកម្មសង្គ្រាមសហរដ្ឋអាមេរិក, *សហរដ្ឋអាមេរិក តទល់នឹង Goebell*, និងអ្នកដទៃទៀត ចុះថ្ងៃទី ០៦ ខែ កុម្ភៈ ដល់ថ្ងៃទី ២១ ខែ មីនា ឆ្នាំ ១៩៤៦។ លើសពីនេះទៀត របាយការណ៍លម្អិតនៃការជំនុំជម្រះ (ផ្អែកលើប្រតិចារឹកសវនាការ) ត្រូវបានបោះពុម្ពផ្សាយក្នុងឆ្នាំ ១៩៥៦។ សូមមើល Maxilimian Koessler, *សោកនាដកម្មនៅកោះ Borkum និងការជំនុំជម្រះ*, (1956) 47 *ព្រឹត្តិប័ត្រច្បាប់ព្រហ្មទណ្ឌទំព័រ* 183-196 ។

65 Maxilimian Koessler, *សោកនាដកម្មនៅកោះ Borkum និងការជំនុំជម្រះ"* ឆ្នាំ១៩៥៦ 47 *ព្រឹត្តិប័ត្រច្បាប់ព្រហ្មទណ្ឌទំព័រ* ១៨៤ ដល់១៨៩។

66 Maxilimian Koessler, *សោកនាដកម្មនៅកោះ Borkum និងការជំនុំជម្រះ"* ឆ្នាំ១៩៥៦ 47 *ព្រឹត្តិប័ត្រច្បាប់ព្រហ្មទណ្ឌទំព័រ* ១៨៤ ដល់១៨៩ ជាពិសេស ទំព័រ ១៨៥។

67 Maxilimian Koessler, *សោកនាដកម្មនៅកោះ Borkum និងការជំនុំជម្រះ"* ឆ្នាំ១៩៥៦ 47 *ព្រឹត្តិប័ត្រច្បាប់ព្រហ្មទណ្ឌទំព័រ* ១៩២។

68 Maxilimian Koessler, *សោកនាដកម្មនៅកោះ Borkum និងការជំនុំជម្រះ"* ឆ្នាំ១៩៥៦ 47 *ព្រឹត្តិប័ត្រច្បាប់ព្រហ្មទណ្ឌទំព័រ*, ១៩៤ ។

34. ជាងនេះទៀត មានឧទាហរណ៍ផ្សេងទៀតនៃការប្រើប្រាស់ការទទួលខុសត្រូវលើសហឧក្រិដ្ឋកម្មរួម ទម្រង់ទីបី នៅក្នុងឧក្រិដ្ឋកម្មសង្គ្រាម នៅក្រោមច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង មិនត្រូវបានពិចារណានៅក្នុងរឿងក្តី *Tadić*។ នៅក្នុងការជំនុំជម្រះ Hans Renoth *និងអ្នកបីនាក់ទៀត* នៅចំពោះមុខតុលាការយោធាអង់គ្លេស[69] ជនជាប់ចោទបួនរូបត្រូវបានចោទប្រកាន់ថា បានប្រព្រឹត្តឧក្រិដ្ឋកម្មសង្គ្រាម ដែលក្នុងនោះពួកគេ "ពាក់ព័ន្ធនឹងការសម្លាប់កងទ័ពអាកាសមិនស្គាល់ឈ្មោះមួយរូបរបស់ក្រុមសម្ព័ន្ធមិត្ត ដែលជាឈ្លើយសឹក"។ ផ្អែកលើការចោទប្រកាន់ អាកាសយានិកនោះបានធ្លាក់យន្តហោះនៅលើទឹកដីអាល្លឺម៉ង់ តែមិនមានគ្រោះថ្នាក់ដល់ខ្លួននោះទេ។ គេត្រូវបានចាប់ខ្លួនដោយ Renoth ដែលជានគរបាលមួយរូប ហើយបន្ទាប់មកត្រូវបានវាយដោយដៃ និងដោយកាំភ្លើងដោយប្រជាជនមួយចំនួន ក្នុងពេលដែលជនជាប់ចោទបីរូបផ្សេងទៀត បានឃើញការវាយដំនេះដែរ ប៉ុន្តែមិនបានធ្វើសកម្មភាពបញ្ឈប់ការវាយដំនេះ ឬក៏ជួយដល់អាកាសយានិកឡើយ។ ចុងក្រោយ Renoth បានបាញ់សម្លាប់អាកាសយានិកនោះ។ "រឿងក្តីដែលត្រូវជំនុំជម្រះគឺថា មានការរៀបចំផែនការរួមគ្នា ដែលក្នុងនោះជនជាប់ចោទទាំងបួន រួមគ្នាប្រព្រឹត្តឧក្រិដ្ឋកម្មសង្គ្រាម ហើយដែលជនជាប់ចោទទាំងបួនបានដឹងអំពីផែនការរួមនេះ ហើយពួកគេទាំងបួននាក់បានធ្វើសកម្មភាពដើម្បីជំរុញដល់ផែនការនេះ"[70] ។ ជនជាប់ចោទទាំងអស់ត្រូវបានរកឃើញថាមានពិរុទ្ធភាព ទោះបីជាមិនមានជនជាប់ចោទណាម្នាក់ ក្រៅពី Renoth បានប្រើប្រាស់កម្លាំងដែលអាចបណ្តាលឱ្យស្លាប់ ឬមានចេតនាសម្លាប់នោះឡើយ។ ដូច្នេះចំណុចនេះបង្ហាញថា តុលាការបានសម្រេចថា ត្រឹមវត្តមាន និងការយល់ព្រមដោយស្ងៀមស្ងាត់របស់ជនជាប់ចោទបីនាក់ផ្សេងទៀត ចំពោះការវាយដំនោះ គឺអាចចាត់ទុកថាបានរួមចំណែកក្នុងការវាយដំ និងបង្ហាញថា យ៉ាងហោចណាស់ក៏ពួកគេមានចេតនាចង់ឱ្យអាកាសយានិកនោះត្រូវគេវាយដំដែរ។ ជនជាប់ចោទទាំងបីនេះ ដូចជាត្រូវបានគេផ្តន្ទាទោសពីបទមនុស្សឃាត ដោយផ្អែកលើអង្គហេតុដែលថា ពួកគេអាចប្រមើលមើលបានថា ការវាយដំនេះនឹងឈានទៅដល់ការសម្លាប់ ដែលបានបំពេញតាមគ្រប់ធាតុផ្សំទាំងអស់របស់សហឧក្រិដ្ឋកម្មរួមទម្រង់ទីបី។

[69] *របាយការណ៍ស្តីពីការជំនុំជម្រះឧក្រិដ្ឋជនសង្គ្រាមសំខាន់ៗ វ៉ុល១១ សង្ខេបនីតិវិធី និងកំណត់សម្គាល់ (តុលាការយោធាអង់គ្លេសសម្រាប់ជំនុំជម្រះឧក្រិដ្ឋជនសង្គ្រាម) ឆ្នាំ១៩៤៩* ("សវនាការលើ Hans Renoth និង បីនាក់ផ្សេងទៀត") ទំព័រ ៧៦។

[70] *របាយការណ៍ស្តីពីការជំនុំជម្រះឧក្រិដ្ឋជនសង្គ្រាមសំខាន់ៗ វ៉ុល១១ សង្ខេបនីតិវិធី និងកំណត់សម្គាល់ (តុលាការយោធាអង់គ្លេសសម្រាប់ជំនុំជម្រះឧក្រិដ្ឋជនសង្គ្រាម) ឆ្នាំ១៩៤៩* ("សវនាការលើ Hans Renoth និង បីនាក់ផ្សេងទៀត") ទំព័រ ៧៦។

35. នៅក្នុងរឿងក្តី *Pohl*[71] ដែលបានជំនុំជម្រះនៅតុលាការតំបន់ដែលគ្រប់គ្រងដោយអាមេរិក មន្ត្រី ១៨នាក់ នៃនាយកដ្ឋានរដ្ឋបាល និងសេដ្ឋកិច្ច *Schutzstaffel* ("SS") រួមទាំង មន្ត្រីប្រតិបត្តិ Hohberger និងសវនករ Baier ត្រូវបានសម្រេចថាត្រូវទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្ស និងឧក្រិដ្ឋកម្មសង្គ្រាម ដោយផ្អែកលើមូលដ្ឋាននៃការចូលរួមរបស់ពួកគេក្នុងសហឧក្រិដ្ឋកម្មរួម ដោយពួកគេមិនបាន "ធ្វើទារុណកម្មដោយផ្ទាល់ចំពោះជនជាតិជ្វីហ ឬអ្នកជាប់ឃុំឃាំងដទៃទៀតនៃរបបចក្រភពអាល្លឺម៉ង់ឡើយ"[72]។ Hohberger មិនបានចូលរួមដោយសកម្មក្នុងឧក្រិដ្ឋកម្ម ហើយបានលើកឡើងថា ដោយសារតែ "គាត់មិនមែនជាសមាជិកនៃបក្សសង្គមនិយមជាតិ និងមិនមែនជាសមាជិកនៃ SS" គាត់អាចទាមទារឱ្យមាន "ការការពារពីការទទួលខុសត្រូវចំពោះអំពើហួសហេតុរបស់ SS"[73]។ ប៉ុន្តែ តុលាការបានសន្និដ្ឋានថា "ដោយសារការទៅពិនិត្យមើលជំរំប្រមូលផ្តុំជាច្រើន ទើបគាត់មិនអាចតវ៉ាថាគាត់មិនបានដឹងអំពីអ្វីដែលកើតឡើងនៅក្នុងជំរំនោះឡើយ"។ SS គឺជាផលវិបាកដែលអាចប្រមើលមើលបាននៃផែនការរួម[74]។

36. សំអាងហេតុប្រហែលគ្នានេះ ត្រូវបានប្រើប្រាស់ចំពោះ Baier ដែលត្រូវបានរកឃើញថា "ចូលរួមយ៉ាងសកម្ម និងបានឯកភាពក្នុងការកេងប្រវ័ញ្ចលើពលកម្មទាសករ"[75] បើទោះបីជាគាត់មិនបានចូលរួមដោយផ្ទាល់ក៏ដោយ។ Baier ត្រូវបានផ្តន្ទាទោសចំពោះឧក្រិដ្ឋកម្មទាំងអស់នេះ តាមរយៈ

[71] សវនាការឧក្រិដ្ឋជនសង្គ្រាមនៅចំពោះមុខតុលាការយោធា *Nuremberg* អនុលោមតាមច្បាប់ក្រុមប្រឹក្សាត្រួតពិនិត្យលេខ ១០ វ៉ុល៥ សាលក្រម (តុលាការយោធាសហរដ្ឋអាមេរិក II) ខែតុលា ឆ្នាំ១៩៤៦ ដល់ខែមេសា ឆ្នាំ១៩៤៩ ("Pohl Case") ទំព័រ ៩៩៣-១២៧៣។

[72] សវនាការឧក្រិដ្ឋជនសង្គ្រាមនៅចំពោះមុខតុលាការយោធា *Nuremberg* អនុលោមតាមច្បាប់ក្រុមប្រឹក្សាត្រួតពិនិត្យលេខ ១០ វ៉ុល៥ សាលក្រម (តុលាការយោធាសហរដ្ឋអាមេរិក II) ខែតុលា ឆ្នាំ១៩៤៦ ដល់ខែមេសា ឆ្នាំ១៩៤៩ ("Pohl Case") ទំព័រ១០៤៧។

[73] សវនាការឧក្រិដ្ឋជនសង្គ្រាមនៅចំពោះមុខតុលាការយោធា *Nuremberg* អនុលោមតាមច្បាប់ក្រុមប្រឹក្សាត្រួតពិនិត្យលេខ ១០ វ៉ុល៥ សាលក្រម (តុលាការយោធាសហរដ្ឋអាមេរិក II) ខែតុលា ឆ្នាំ១៩៤៦ ដល់ខែមេសា ឆ្នាំ១៩៤៩ ("Pohl Case") ទំព័រ១០៤១។

[74] សវនាការឧក្រិដ្ឋជនសង្គ្រាមនៅចំពោះមុខតុលាការយោធា *Nuremberg* អនុលោមតាមច្បាប់ក្រុមប្រឹក្សាត្រួតពិនិត្យលេខ ១០ វ៉ុល៥ សាលក្រម (តុលាការយោធាសហរដ្ឋអាមេរិក II) ខែតុលា ឆ្នាំ១៩៤៦ ដល់ខែមេសា ឆ្នាំ១៩៤៩ ("Pohl Case") ទំព័រ១០៤១ ១០៤២។

[75] សវនាការឧក្រិដ្ឋជនសង្គ្រាមនៅចំពោះមុខតុលាការយោធា *Nuremberg* អនុលោមតាមច្បាប់ក្រុមប្រឹក្សាត្រួតពិនិត្យលេខ ១០ វ៉ុល៥ សាលក្រម (តុលាការយោធាសហរដ្ឋអាមេរិក II) ខែតុលា ឆ្នាំ១៩៤៦ ដល់ខែមេសា ឆ្នាំ១៩៤៩ ("Pohl Case") ទំព័រ១០៤៧។

ការទទួលខុសត្រូវចំពោះសហឧក្រិដ្ឋកម្មរួម ទម្រង់ទីបី ដោយផ្អែកលើមូលដ្ឋានថា ផលវិបាកដែលអាចប្រមើលមើលបានចំពោះពលកម្មទាសករ គឺ "ការធ្វើទុក្ខបុកម្នេញជាប្រព័ន្ធ ការបាក់កម្លាំង ការឃុំឃាំង និងជាចុងក្រោយគឺការសម្លាប់ ដែលមិនអាចធ្វើទៅបានឡើយ ប្រសិនបើមិនមានគ្រឿងម៉ាស៊ីនដ៏ទូលំទូលាយរបស់ SS"[76]។

37. ប្រហាក់ប្រហែលគ្នានេះ នៅក្នុងរឿងក្តី *RuSHA* តុលាការតំបន់ដែលគ្រប់គ្រងដោយអាមេរិកបានសម្រេចថា ជនជាប់ចោទ ១៤នាក់ ដែលពួកគេទាំងអស់នោះជាមន្ត្រីនៃអង្គការ SS ជាច្រើន មានពិរុទ្ធភាពដែលសារពួកគេបានចូលរួមក្នុងការជំរុញសហឧក្រិដ្ឋកម្ម៖ "កម្មវិធីបន្សុតពូជសាសន៍"។ ប្រធានការិយាល័យពូជសាសន៍ និងការតាំងទីលំនៅថ្មីរបស់ SS គឺលោក Hildebrandt ត្រូវបានសម្រេចថាត្រូវទទួលខុសត្រូវចំពោះការសម្លាប់ដោយព្យួរក ដោយសារតែគាត់ជាអ្នកទទួលខុសត្រូវលើការបញ្ជាឲ្យមាន "ការប្រព្រឹត្តិជាពិសេស" ចំពោះជនបរទេសដែលត្រូវបានរកឃើញថាបានរួមភេទជាមួយស្ត្រីជនជាតិអាល្លឺម៉ង់[77]។ តុលាការបានសម្រេចថា បើទោះបីជា Hildebrandt "ពីដំបូងបានបដិសេធថាគាត់មិនយល់ពីអត្ថន័យនៃពាក្យ 'ការប្រព្រឹត្តិពិសេស' ប៉ុន្តែនៅពេលក្រោយមក គាត់បានសារភាពថា គាត់បានដឹងថា ក្នុងករណី 'ការប្រព្រឹត្តិពិសេស' អាចមានលទ្ធផលនៃការព្យួរក"។ សំអាងហេតុរបស់អង្គជំនុំជម្រះបានបង្ហាញយ៉ាងច្បាស់ថា Hildebrandt ត្រូវទទួលខុសត្រូវចំពោះការព្យួរក ដែលគាត់មិនមានចេតនានោះទេ ប៉ុន្តែគាត់មានហេតុផលអាចប្រមើលមើលឃើញ។

38. នៅក្នុងរឿងក្តី *Einsatzgruppen* មេដឹកនាំជាន់ខ្ពស់ ២៤ នាក់ នៅក្នុងអង្គការការិយាល័យរដ្ឋបាលត្រូវបានចោទប្រកាន់ថា ត្រូវទទួលខុសត្រូវលើការស្លាប់របស់ប្រជាជនជាងមួយលាននាក់ នៅទូទាំងទ្វីបអឺរ៉ុប[78]។ ពាក់ព័ន្ធជាមួយនឹងជនជាប់ចោទមួយរូប គឺ Franz Six ដែលជាប្រធាន

---

[76] សវនាការឧក្រិដ្ឋជនសង្គ្រាមនៅចំពោះមុខតុលាការយោធា *Nuremberg* អនុលោមតាមច្បាប់ក្រុមប្រឹក្សាត្រួតពិនិត្យលេខ ១០ វ៉ុល៥ សាលក្រម (តុលាការយោធាសហរដ្ឋអាមេរិក II) ខែតុលា ឆ្នាំ១៩៤៦ ដល់ខែមេសា ឆ្នាំ១៩៤៩ ("Pohl Case") ទំព័រ១០៤៧។

[77] សវនាការឧក្រិដ្ឋជនសង្គ្រាមនៅចំពោះមុខតុលាការយោធា *Nuremberg* អនុលោមតាមច្បាប់ក្រុមប្រឹក្សាត្រួតពិនិត្យលេខ ១០ វ៉ុល៥ មតិ និងសាលក្រម (តុលាការយោធាសហរដ្ឋអាមេរិក II) ខែតុលា ឆ្នាំ១៩៤៦ ដល់ខែមេសា ឆ្នាំ១៩៤៩ ("រឿងក្តី RuSHA") ទំព័រ១-១៩២។

[78] សវនាការឧក្រិដ្ឋជនសង្គ្រាមនៅចំពោះមុខតុលាការយោធា *Nuremberg* អនុលោមតាមច្បាប់ក្រុមប្រឹក្សាត្រួតពិនិត្យលេខ ១០ វ៉ុល៤ មតិ និងសាលក្រម (តុលាការយោធាសហរដ្ឋអាមេរិក II) ខែតុលា ឆ្នាំ១៩៤៦ ដល់ខែមេសា ឆ្នាំ១៩៤៩ ("រឿងក្តី

Vorkomma ndo Moscow តុលាការបានសម្រេចថា "បើទោះបីជាមានការរកឃើញថា Vorkommando Moscow គឺជាផ្នែកនៃ Einsatzgruppe B ហើយបើទោះបីរកឃើញថា Six បានដឹងពីគោលបំណងឧក្រិដ្ឋនៃ Einsatzgruppe B ក៏តុលាការមិនអាចសន្និដ្ឋានដោយមានការជឿជាក់បែបវិទ្យាសាស្ត្រថា Six បានចូលរួមយ៉ាងសកម្មក្នុងកម្មវិធីមនុស្សឃាតរបស់អង្គការនោះដែរ។ ក៏ប៉ុន្តែ មានភស្តុតាងដែលថា Six គឺជាផ្នែកមួយនៃអង្គការដែលចូលរួមក្នុងអំពើសាហាវយង់ឃ្នង ការប្រមាថមើលងាយ និងអំពើអមនុស្សធម៌ប្រឆាំងនឹងប្រជាជនស៊ីវិល"[79]។ ហេតុដូចនេះ តុលាការសម្រេចផ្តន្ទាទោសគាត់ពីបទឧក្រិដ្ឋទាំងអស់ រួមទាំង ការសម្លាប់ ដែលធ្វើឡើងដោយអង្គការ ដែលគាត់គឺជាផ្នែកមួយដែរ បើទោះបីជាគាត់មិនបានចូលរួម ព្រមទាំងមិនមានចេតនានៅក្នុងឧក្រិដ្ឋកម្មជាក់លាក់ទាំងនោះក៏ដោយ។

39. ទម្រង់នៃការទទួលខុសត្រូវទាក់ទងនឹងសហឧក្រិដ្ឋកម្មរួម ក៏ត្រូវបានអនុវត្តផងដែរក្នុងរឿងក្តី *Sch. និងអ្នកដទៃទៀត*។ នេះគឺជាសាលដីកាលើបណ្តឹងសាទុក្ខរបស់តុលាការកំពូលសម្រាប់តំបន់គ្រប់គ្រងដោយអង់គ្លេស ដែលធ្វើការពិនិត្យមើលលើសាលក្រមរបស់ក្រុមប្រឹក្សាជំនុំជម្រះ នៅ Braunsch weig (Brunswick) តាមច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង។ តុលាការកំពូលយល់ឃើញថា ក្រុមប្រឹក្សាជំនុំជម្រះមានកំហុសឆ្គងអង្គច្បាប់ចំពោះ "អ្វីដែលតាមអង្គហេតុ ត្រូវចាត់ទុកថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ"[80]។ *Sch* និងអ្នកដទៃទៀតបានចាប់ខ្លួន N ដោយមិនមានភស្តុតាងថា N បានចូលរួមក្នុងឧក្រិដ្ឋកម្ម ដែលជាផ្នែកនៃយុទ្ធនាការធ្វើទុក្ខបុកម្នេញចំពោះជនជាតិជ្វីហ។ *Sch.* បាននាំអ្នកទោស N របស់គាត់ទៅកាន់ប៉ុស្តិ៍នគរបាល និងទៅវិហារជនជាតិជ្វីហ ដែលត្រូវបានគេដុត ដែលនៅទីនោះ N ត្រូវបានគេទាត់ធាក់ ហើយបន្ទាប់មកត្រូវបានគេបាញ់។ តុលាការសម្រេចថា អ្វីដែលបានកើតឡើងចំពោះ N នៅយប់នោះ "គឺជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តាំងពីដំបូងរហូតដល់ចុងក្រោយ"។ ទោះបីជាមិនមានភស្តុតាងថា *Sch.* ខ្លួនគាត់បានចូលរួមក្នុងការទាត់ធាក់ និងបាញ់ N ក៏ដោយ ក៏តុលាការសម្រេចថា "ប្រសិនបើតុលាការរកឃើញថា ជនជាប់ចោទបានដឹង ឬក៏*សូម្បីតែអាចស្មានពីលទ្ធភាពដែលថា គាត់អាចត្រូវទទួលខុសត្រូវចំពោះ*

("Einsatzgruppen") ទំព័រ៤២៧-៤៣៣។

[79] សវនាការឧក្រិដ្ឋជនសង្គ្រាមនៅចំពោះមុខតុលាការយោធា *Nuremberg* អនុលោមតាមច្បាប់ក្រុមប្រឹក្សាត្រួតពិនិត្យលេខ ១០ វ៉ុល៤ មតិ និងសាលក្រម (តុលាការយោធាសហរដ្ឋអាមេរិក II-A) ខែតុលា ឆ្នាំ១៩៤៦ ដល់ខែមេសា ឆ្នាំ១៩៤៦ ("រឿងក្តី ("Einsatzgruppen") ទំព័រ៥២៦។

[80] សេចក្តីសម្រេចរបស់តុលាការកំពូលក្នុងតំបន់អង់គ្លេស វ៉ុល II សេចក្តីសម្រេចប្រឆាំងនឹង *Sch. et. al.,* ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ១៩៤៩ ("Sch. Case") ត្រង់ទំព័រ១១-១៥ ឬកថាខណ្ឌ៣.១។

ជោគវាសនាដ៏អាក្រក់របស់ N នៅពេលដែលគាត់នាំ N ទៅទីនោះ គាត់ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ចំពោះអ្វីគ្រប់យ៉ាងដែលបានកើតឡើងចំពោះ N នៅឯវិហារជនជាតិជ្វីហ ដែលត្រូវបានគេដុត"[81]។ ការសម្រេចនេះស្របជាមួយសហឧក្រិដ្ឋកម្មរួម ទម្រង់ទីបី ព្រោះតុលាការបានសម្រេចថា បើទោះបីជា *Sch.* មិនមានចេតនាឲ្យមានឧក្រិដ្ឋកម្មក៏ដោយ ក៏គាត់ត្រូវទទួលខុសត្រូវចំពោះអំពើឧក្រិដ្ឋរបស់អ្នកចូលរួមដទៃទៀតនៅក្នុងសហឧក្រិដ្ឋកម្ម ប្រសិនបើគាត់បានដឹង ("អាចស្មានបាន") ពីលទ្ធភាពដែលឧក្រិដ្ឋកម្មទាំងនេះអាចកើតមានឡើង។

40. នៅក្នុងរឿងក្តី *Martin Gottfried Weiss* ដែលត្រូវបានជំនុំជម្រះក្រោមច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រងដដែលនោះ ចៅក្រមតុលាការយោធា (Staff Judge Advocate) បានបញ្ជាក់ពីច្បាប់ស្តីពីការទទួលខុសត្រូវលើផែនការរួម។ ពាក្យពេចន៍របស់គាត់គឺសឹងតែស្មើនឹងការប្រកាសពីសហឧក្រិដ្ឋកម្មរួម ទម្រង់ទីបី៖

> *បុគ្គលទាំងអស់ដែលចូលរួមក្នុងផែនការរួម ដើម្បីប្រព្រឹត្តអំពើខុសច្បាប់ ត្រូវតែទទួលខុសត្រូវចំពោះផលវិបាកទាំងអស់ ដែលបណ្តាលមកពីការអនុវត្តសកម្មភាព ប្រសិនបើសកម្មភាពទាំងនោះត្រូវបានធ្វើឡើងដើម្បីជំរុញបន្ថែមដល់ផែនការ បើទោះបីជាភាគីទាំងនោះមិនបានគិតទុកជាពិសេសក៏ដោយ ឬក៏បើទោះបីជាត្រូវបានហាមឃាត់ដោយជនជាប់ចោទក៏ដោយ ឬបើទោះបីជាចារីពិតប្រាកដ មិនត្រូវបានកំណត់អត្តសញ្ញាណក៏ដោយ*[82] ។

41. ដូចបានបង្ហាញពីខាងលើ ធាតុផ្សំដែលស្ថិតនៅចំណុចស្នូលនៃសហឧក្រិដ្ឋកម្មរួម ទម្រង់ទីបី ដែលជាទម្រង់នៃការទទួលខុសត្រូវ ត្រូវបានទទួលស្គាល់ និងអនុវត្តនៅក្នុងរឿងក្តីក្រោយសង្គ្រាមលោកលើកទី II នៅក្នុងទ្វីបអឺរ៉ុប។ លើសពីនេះទៀត សហឧក្រិដ្ឋកម្មរួម ទម្រង់ទីបី ត្រូវបានទទួលស្គាល់ និងអនុវត្តនៅក្នុងសវនាការ Batavia នៅក្រោយសង្គ្រាម ដែលដំណើរការដោយអាជ្ញាធរប្រទេសហូឡង់នៅលើទឹកដីប្រទេសឥណ្ឌូនេស៊ី។ វរសេនីយ៍ឯកជប៉ុន Shoichi Ikeda ត្រូវបានចោទប្រកាន់ពីបទរំលោភបំពានផ្លូវភេទ ការចាប់ពង្រត់ និងពេស្យាកម្មដោយបង្ខំ ព្រមទាំងឧក្រិដ្ឋកម្មដទៃទៀត

---

[81] សេចក្តីសម្រេចរបស់តុលាការកំពូលក្នុងតំបន់អង់គ្លេស វ៉ុល II សេចក្តីសម្រេចប្រឆាំងនឹង *Sch. et. al.*, ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ១៩៤៩ ("Sch. Case") ត្រង់ទំព័រ១១-១៥ [មានការគូសបញ្ជាក់បន្ថែម]។

[82] ការពិនិត្យមើលនីតិវិធីឡើងវិញនៃតុលាការយោធាទូទៅក្នុងករណីរឿងក្តី *US v. Martin Gottfried Weiss et. al.* ដែលមានអនុសាសន៍របស់ចៅក្រម (១៩៤៥) ត្រង់ទំព័រ ១៤១។

ដែលកើតចេញពីការជ្រើសរើសដោយមិនស្ម័គ្រចិត្តនូវ "ស្ត្រីកំដរអារម្មណ៍" ចេញពីជំរំឃុំឃាំងនៅតណ្ឌាណេស៊ី[83]។ បើទោះបីជាផែនការឧក្រិដ្ឋពីដំបូង គឺបង្កើតជាបនពេស្យា ហើយធ្វើការជ្រើសរើសនារីៗ ដើម្បីផ្តល់សេវាផ្លូវភេទដល់អតិថិជនក៏ដោយ ក៏តុលាការយល់ឃើញថា Ikeda *បានដឹង ឬគួរបានដឹង* ថាស្ត្រីទាំងអស់នោះត្រូវបានគេជួញដូរ ដោយខុសពីឆន្ទៈរបស់ពួកគាត់ ហើយត្រូវបានគេបង្ខំឲ្យចូលរួមក្នុងសកម្មភាពផ្លូវភេទ ខុសពីឆន្ទៈរបស់ពួកគាត់ដែរ[84]។ ការដឹងបែបនេះបង្ហាញថា ផលវិបាកដែលអាចប្រមើលមើលបានចំពោះផែនការឧក្រិដ្ឋបឋម គឺការរំលោភបំពានផ្លូវភេទ និងពេស្យាកម្មដោយបង្ខំ បើទោះបីជាជនជាប់ចោទបានអះអាងថា គាត់មិនមានចេតនា ឬបានស្មានទុកមុន ឬបានដឹងថាស្ត្រីទាំងនោះត្រូវបានគេនាំយកដោយបង្ខំទៅបនពេស្យា ដែលនៅទីនោះស្ត្រីទាំងនេះត្រូវទទួលរងការរំលោភបំពានផ្លូវភេទ និងអំពើហិង្សា[85]។ ទោះជាយ៉ាងនេះក្តី អង្គជំនុំជម្រះយល់ឃើញថា ជនជាប់ចោទត្រូវទទួលខុសត្រូវព្រហ្មទណ្ឌចំពោះសហឧក្រិដ្ឋកម្មដំបូង និងឧក្រិដ្ឋកម្មផ្សេងៗទៀត។

42. លក្ខន្តិកៈសម្រាប់តុលាការនានាដែលកើតក្រោយសង្គ្រាមលោកលើកទីពីរ និងច្បាប់យុត្តិសាស្ត្រចែងយ៉ាងច្បាស់ថា ជនទាំងឡាយណាដែលចូលរួមដោយចេតនា និងគាំទ្រដល់សហឧក្រិដ្ឋកម្មមួយដើម្បីប្រព្រឹត្តឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ត្រូវតែទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មរបស់សហអ្នកចូលរួម ដែលពួកគេអាចប្រមើលឃើញជាមុនបានចំពោះលទ្ធផលដែលកើតចេញពីសហឧក្រិដ្ឋកម្មនេះ។ ដូច្នេះ JCE III គឺជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅឆ្នាំ ១៩៧៥។ សេចក្តីសន្និដ្ឋាននេះត្រូវបានបញ្ជាក់បន្ថែមដោយភាពលើសលុបនៃការទទួលខុសត្រូវដែលបានពន្លាតសម្រាប់ឧក្រិដ្ឋកម្មជាក្រុមនៅក្នុងប្រព័ន្ធតុលាការជាតិ ដូចដែលបានបង្ហាញនៅក្នុងផ្នែកខាងក្រោមនៃបណ្តឹងសាទុក្ខនេះ។

---

[83] *The Queen v. Shoichi Ikeda*, សំណុំរឿង No. 72A/1947, សាលក្រមសង្ខេបដែលបានបកប្រែ (តុលាការយោធាបណ្តោះអាសន្ន) [Temporaire Krijgsraad] ក្នុង Batavia), ថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៤៨, ("សាលក្រមសង្ខេបរបស់ Batavia")។

[84] *The Queen v. Shoichi Ikeda*, សំណុំរឿង No. 72A/1947, សាលក្រមសង្ខេបដែលបានបកប្រែ (តុលាការយោធាបណ្តោះអាសន្ន) [Temporaire Krijgsraad] ក្នុង Batavia), ថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៤៨, ("សាលក្រមសង្ខេបរបស់ Batavia"), ត្រង់ទំព័រ ១ និង ៨ [មានការគូសបញ្ជាក់បន្ថែម]។

[85] *The Queen v. Shoichi Ikeda*, សំណុំរឿង No. 72A/1947, សាលក្រមសង្ខេបដែលបានបកប្រែ (តុលាការយោធាបណ្តោះអាសន្ន) [Temporaire Krijgsraad] ក្នុង Batavia), ថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៤៨, ("សាលក្រមសង្ខេបរបស់ Batavia"), ត្រង់ទំព័រ ៧ ១០ និង១១។

## ឃ.ការទទួលខុសត្រូវក្នុងទម្រង់JCE III បានបញ្ជាក់នៅក្នុងច្បាប់ទំលាមទម្លាប់អន្តរជាតិ មុនឆ្នាំ១៩៧៥

43. អង្គជំនុំជម្រះសាលាដំបូងបានសម្រេចដោយការយល់ឃើញដែលថា "ការទទួលខុសត្រូវចំពោះចេតនារួម" មិនត្រូវបានប្រព័ន្ធច្បាប់ជាតិភាគច្រើនសម្រេចយកតាមទេ"[86]។ ក្រោយពីបានសិក្សាស្រាវជ្រាវទៅលើលក្ខន្តិកៈនៃ JCE III តាមគំនិតផ្តួចផ្តើមរបស់ខ្លួនផ្ទាល់ (*proprio motu*) នៅក្នុងប្រព័ន្ធច្បាប់ជាតិចំនួនប្រាំពីរប្រទេស ប្រព័ន្ធច្បាប់ជាតិទាំងនោះបានលើកឡើងថា "ការអនុវត្តរបស់រដ្ឋនៅក្នុងផ្នែកទាំងនេះមិនមានការឯកភាពគ្នាឲ្យបានគ្រប់គ្រាប់ ដែលត្រូវបានយកមកពិចារណាជាគោលការណ៍ទូទៅនៃច្បាប់នោះទេ"[87]។

44. ទោះបីជាយ៉ាងណាក៏ដោយ មានភាពខុសគ្នាយ៉ាងខ្លាំងរវាងសំអាងហេតុ "គោលការណ៍ទូទៅនៃច្បាប់" និងសំអាងហេតុដែលថា "ទម្លាប់អនុវត្តរបស់រដ្ឋ" បង្ហាញឲ្យឃើញនូវអត្ថិភាពនៃបទដ្ឋាននៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ។ អង្គជំនុំជម្រះរបស់ អ.វ.ត.ក និងអង្គជំនុំជម្រះតុលាការកំពូល ក្នុងរឿងក្តី *Tadić* ពុំបានធ្វើការពិនិត្យឡើងវិញជាប្រព័ន្ធទៅលើទម្លាប់អនុវត្តរបស់រដ្ឋសម្រាប់គោលបំណងនេះឡើយ។ អង្គជំនុំជម្រះតុលាការកំពូលក្នុងរឿងក្តី *Tadić* បានព្រមានឲ្យដឹងថា ការយោងរបស់អង្គជំនុំជម្រះទៅលើយុត្តិសាស្ត្រ និងច្បាប់ជាតិ គឺសម្រាប់គោលបំណងក្នុងកម្រិតតិចតួចបំផុត៖ "ដើម្បីបង្ហាញថា សញ្ញាណនៃគោលបំណងរួមដែលត្រូវបានតម្កល់នៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ មានមូលដ្ឋាននៅក្នុងប្រព័ន្ធច្បាប់ជាតិជាច្រើន" ដែលបានកំណត់រួចហើយអំពីអត្ថិភាពនៃទម្រង់ទាំងបី នៃការទទួលខុសត្រូវសហឧក្រិដ្ឋកម្មរួម ដោយផ្អែកទៅលើមូលដ្ឋាននៃអនុសញ្ញាអន្តរជាតិ និងសំណុំរឿងសង្គ្រាមលោកលើកទី II[88]។ អង្គជំនុំជម្រះនេះ ក៏ប្រុងប្រយ័ត្នផងដែរក្នុង

---

86 ឯកសារ **E100/6** សេចក្តីលើភាពអនុវត្តបាននូវសហឧក្រិដ្ឋកម្មរួម ចុះថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០១១ ("សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង") ត្រង់កថាខណ្ឌ ២៨។ ឯកសារ **D97/17/6** សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម (JCE) ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១០ ("សាលដីការបស់អង្គបុរេជំនុំជម្រះ") ត្រង់កថាខណ្ឌ ៨៥។ រដ្ឋអាជ្ញា ទល់នឹង *Duško Tadić* សំណុំរឿងលេខ IT-94-1-A សាលដីកា (អង្គជំនុំជម្រះសាលាឧទ្ធរណ៍) ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៩៩៩ ("សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ Tadić") ត្រង់កថាខណ្ឌ ២២៥។

87 ឯកសារ **E100/6** សេចក្តីលើភាពអនុវត្តបាននូវសហឧក្រិដ្ឋកម្មរួម ចុះថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០១១ ("សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង") ត្រង់កថាខណ្ឌ ៣៧។

88 *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង* Duško Tadić សំណុំរឿងលេខ IT-94-1-A *សាលដីកា (អង្គជំនុំជម្រះតុលាការកំពូល) ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៩៩៩("សាលដីកាលើរឿងក្តី* Tadić") *ត្រង់កថាខណ្ឌ ២២៥។*

ការបញ្ជាក់ថា ចំពោះការបង្ហាញថា សហឧក្រិដ្ឋកម្មរួមគឺជាគោលការណ៍ទូទៅនៃច្បាប់នោះ "វាចាំបាច់ត្រូវបង្ហាញឱ្យឃើញថា ប្រទេសភាគច្រើន ប្រសិនបើមិនទាំងអស់ទេ បានអនុម័តសញ្ញាណនៃគោលបំណងរួមដូចគ្នា"[89]។ នៅក្នុងបណ្តឹងសាទុក្ខនេះ សហព្រះរាជអាជ្ញាពុំអះអាងថា សហឧក្រិដ្ឋកម្មរួមទម្រង់ទី III មានឋានៈនៃគោលការណ៍ទូទៅនៃច្បាប់ឡើយ ប៉ុន្តែនឹងបង្ហាញយ៉ាងច្បាស់អំពីឋានៈនៃសហឧក្រិដ្ឋកម្មរួមទម្រង់ទី III ថាជាវិធាននៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ មុនឆ្នាំ១៩៧៥។

45. អត្ថិភាពនៃវិធានច្បាប់ទំនៀមទម្លាប់អន្តរជាតិ ត្រូវបានបង្កើតឡើងជាផ្លូវការដោយសារមានការបង្ហាញអំពីទម្លាប់ក្នុងការអនុវត្តរបស់រដ្ឋ ដែលមានន័យថា (i) ដូចគ្នាជាក់ស្តែង (ii) ទូលំទូលាយ និងធ្វើជាតំណាង ព្រមទាំងបង្ហាញពី (iii) *កាតព្វកិច្ចផ្លូវច្បាប់*[90]។ តុលាការយុត្តិធម៌អន្តរជាតិ ("ICJ") បានសម្រេចថា "ទម្លាប់ក្នុងការអនុវត្តយ៉ាងទូលំទូលាយ និងគួរឱ្យជឿជាក់បានគ្រប់គ្រាន់" តែមួយ អាចបញ្ជាក់បានពី*កាតព្វកិច្ចផ្លូវច្បាប់*[91]។ តាមពិត យើងធ្លាប់សង្កេតឃើញថា ICJ "មិនធ្លាប់មានបញ្ហាចំពោះខ្លួនឯងនៅក្នុងការស្វែងរក *កាតព្វកិច្ចផ្លូវច្បាប់* នៅទីណាដែលទម្លាប់នៃការអនុវត្តល្អត្រូវបានបង្កើតឡើងរួចហើយនោះទេ"[92]។

---

[89] *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Duško Tadić* សំណុំរឿងលេខ IT-94-1-A *សាលដីកា (អង្គជំនុំជម្រះតុលាការកំពូល) ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៩៩៩*("*សាលដីកាលើរឿងក្តី* Tadić") *ត្រង់កថាខណ្ឌ ២២៥*។

[90] រឿងក្តី North Sea Continental Shelf, *Germany v. the Netherlands and Denmark,* របាយការណ៍របស់តុលាការ ICJ ១៩៦៩ ត្រង់ទំព័រ៣ សាលក្រម, ២០ កុម្ភៈ ១៩៦៩ ត្រង់ទំព័រ៤៤, ([អំពើនោះ] ត្រូវតែដូចគ្នាទៅនឹង ឬ ត្រូវបានប្រព្រឹត្តឡើងតាមរបៀបមួយដែលអាចជាភស្តុតាងបញ្ជាក់ពីជំនឿមួយថា ទម្លាប់នៅក្នុងការអនុវត្តត្រូវធ្វើឡើងដោយមានកាតព្វកិច្ចចំពោះអត្ថិភាពនៃវិធានច្បាប់ដែលដាក់លក្ខខណ្ឌនោះ)។ តម្រូវការឱ្យមានជំនឿដូច្នេះគឺថា អត្ថិភាពនៃធាតុផ្សំអត្តនោម័ត គឺជាន័យបញ្ឆិតបញ្ឆៀងនៅក្នុងវិចារណញ្ញាណនៃគោលការណ៍ *កាតព្វកិច្ចផ្លូវច្បាប់ ឬកាតព្វកិច្ចចាំបាច់)*។

[91] *ករណី* The *Gulf of Maine* ជាករណីពាក់ព័ន្ធនឹង*ការកំណត់ព្រំដែនទឹកនៅក្នុងឈូងសមុទ្រម៉ែន (U.S. ទល់នឹង Canada),* របាយការណ៍ ICJ, ឆ្នាំ១៩៨៤ ត្រង់ទំព័រ២៤៦ សាលក្រម ICJ ចុះថ្ងៃទី ១២ តុលា ១៩៨៤ ត្រង់កថាខណ្ឌ ១១១ ('…*កាតព្វកិច្ចផ្លូវច្បាប់* របស់រដ្ឋមួយ អាចត្រូវបានធ្វើតេស្តតាមរយៈការណែនាំឱ្យស្គាល់ ដោយផ្អែកលើការវិភាគអំពីទម្លាប់នៃការអនុវត្តទូលំទូលាយគ្រប់គ្រាន់ និងគួឱ្យជឿជាក់បាន")។ សូមមើលផងដែរ *ករណីពាក់ព័ន្ធនឹងសិទ្ធិឆ្លងកាត់ទឹកដីឥណ្ឌា*។ សូមមើលបន្ថែម គណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ "ការពិនិត្យជាអន្តរជាតិរបស់កាកបាទក្រហម" ទំព័រ ១៨២ ("នៅពេលណាមានការអនុវត្តរបស់រដ្ឋយ៉ាងក្រាស់ក្រែលគ្រប់គ្រាន់ហើយ នោះ *កាតព្វកិច្ចផ្លូវច្បាប់* ជាទូទៅមាននៅក្នុងទម្លាប់នោះរួចហើយៗជាលទ្ធផល ជាធម្មតាគេមិនចាំបាច់បង្ហាញដាច់ដោយឡែកពីអត្ថិភាពនៃ*កាតព្វកិច្ចផ្លូវច្បាប់*ទេ។

[92] Brian D Lepard, 'ភាពចាំបាច់នៃ *កាតព្វកិច្ចផ្លូវច្បាប់* នៅក្នុងការបង្កើតច្បាប់ទម្លាប់អន្តរជាតិ, ឯកសារពិភាក្សាសម្រាប់អង្គគណៈកម្មការស្តីពី "តើច្បាប់ទម្លាប់អន្តរជាតិត្រូវការ *កាតព្វកិច្ចផ្លូវច្បាប់* ដែរឬទេ? ទំព័រ២ ដោយលើកយោង Maurice Mendelson, 'ធាតុផ្សំអត្តនោម័តនៃច្បាប់អន្តរជាតិ (១៩៩៥) 66 (១) សៀវភៅប្រចាំឆ្នាំរបស់អង់គ្លេសស្តីពីច្បាប់អន្តរជាតិ ១៧៧ ។

46. ទាក់ទងនឹងសណ្ឋាណដូចគ្នានៃការអនុវត្តរបស់រដ្ឋវិញ ខណៈដែលកម្រិតនៃភាពស៊ីសង្វាក់គ្នាជាក់លាក់មួយក្នុងការអនុវត្តច្បាប់ទម្លាប់គឺជាលក្ខខណ្ឌតម្រូវក៏ដោយ មិនមានសិទ្ធិអំណាចច្បាស់លាស់ស្តីពីចំនួនចាំបាច់ទេ[93]។ ផ្អែកលើការពិនិត្យយុត្តិសាស្ត្ររបស់ ICJ គឺថាវិសាលភាពនៃទម្លាប់ក្នុងការអនុវត្តដែលបង្កើតបានជាតួអង្គសេចក្តីនៃច្បាប់ទម្លាប់ ត្រូវបានគេឱ្យនិយមន័យថា "មានលក្ខណៈទូទៅ"[94], "សាមញ្ញ ស្របគ្នា និង ត្រូវគ្នា[95]" ហើយ "ទាំងពីរ មានលក្ខណៈទូលំទូលាយ និងសណ្ឋាណជាក់ស្តែង"[96] - ប៉ុន្តែមិនមានលក្ខណៈ "ជាឯកច្ឆន្ទ" ឬ "ជាសកល"[97] ទេ។ ជាសំខាន់ ICJ បានបញ្ជាក់ថា ការអនុវត្ត *មិន*ចាំបាច់ទាល់តែមានសណ្ឋាណដូចគ្នា ដោយផ្អែកទៅលើមូលដ្ឋាននៃទម្លាប់ទេឱ្យតែស៊ីសង្វាក់គ្នា[98]។ គេសង្កេតឃើញថា "ទម្លាប់អនុវត្តទូទៅគ្រប់គ្រាន់" ដើម្បីបង្កើត

---

[93] Robbie Sabel, *នីតិវិធីនៅសន្និសីទអន្តរជាតិ: ការសិក្សាអំពីវិធាននីតិវិធីនៃសន្និសីទអន្តររដ្ឋាភិបាលអន្តរជាតិ* (សារព័ត៌មានសកលវិទ្យាល័យ Cambridge, ឆ្នាំ១៩៩៧) ទំព័រ៣៨។ Anthea E Roberts, 'ទំនៀមទំលាប់ និងអភិក្រមសម័យទំនើបចំពោះច្បាប់ទម្លាប់អន្តរជាតិ: ការផ្សះផ្សា (២០០១) លេខ ៩៥ នៃ *American Journal of International Law* 757, 767 ('ដំណើរការនៃការបង្កើតទម្លាប់ គឺមានភាពមិនប្រាកដប្រជាតាំងពីដើមមក ដោយគ្មានមគ្គុទេសន៍ណែនាំអំពីចំនួន ថិរវេលា ភាពញឹកញាប់ និងនិរន្តរភាពនៃទម្លាប់នៃការអនុវត្តរបស់រដ្ឋដែលជាលក្ខខណ្ឌតម្រូវ ក្នុងការបង្កើតទម្លាប់នោះឡើយ')។ Anthony D'Amato, *គំនិតអំពីទម្លាប់នៅក្នុងច្បាប់អន្តរជាតិ* (London: Cornell University Press,1971) 56-66។ Ulrich Fastenrath, 'ប្រក្រតីភាពប្រហាក់ប្រហែលនៅក្នុងច្បាប់អន្តរជាតិ(១៩៩៣) 4 *European Journal of International law* 305, កថាខណ្ឌ 317 ('តួយ៉ាងនិមួយៗស្តីពីទម្លាប់នៃការអនុវត្តតាមច្បាប់ទម្លាប់អន្តរជាតិមិនដូចគ្នាបះបិទទេ') 318។

[94] *ករណីពាក់ព័ន្ធនឹងសកម្មភាពយោធា និងយោធាប្រតិព័ទ្ធនៅក្នុង ហើយដែលប្រឆាំងនឹង Nicaragua, (Nicaragua ទល់នឹង USA)* (អង្គសេចក្តី) [1986] របាយការណ៍ ICJ 14, ទំព័រ 98។ *ករណីយុត្តាធិការជលផល (ចក្រភពអង់គ្លេស និងអៀរឡង់ខាងជើង ទល់នឹងអ៊ីស្លង់ (អង្គសេចក្តី) (មតិជំទាស់រួមរបស់ចៅក្រម Forster, Bengzon, Jimenez de Arechaga, Nagendra Singh and Ruda)* [1974] របាយការណ៍ ICJ 3, ទំព័រ៥២។

[95] *ករណីពាក់ព័ន្ធនឹងសកម្មភាពយោធា និងយោធាប្រតិព័ទ្ធនៅក្នុង ហើយដែលប្រឆាំងនឹង Nicaragua, (Nicaragua ទល់នឹង USA)* (អង្គសេចក្តី) [1986] របាយការណ៍ ICJ 14, ទំព័រ 98។ *ករណីយុត្តាធិការជលផល (ចក្រភពអង់គ្លេស និងអៀរឡង់ខាងជើង ទល់នឹងអ៊ីស្លង់ (អង្គសេចក្តី) (មតិជំទាស់រួមរបស់ចៅក្រម Forster, Bengzon, Jimenez de Arechaga, Nagendra Singh and Ruda)* [1974] របាយការណ៍ ICJ 3, ទំព័រ៥០។

[96] *ករណី North Sea Continental Shelf, (Germany v Denmark and Netherlands) (សាលក្រម)* [1969] របាយការណ៍ ICJ 4 ទំព័រ 44។

[97] Prosper Weil, 'ប្រក្រតីភាពប្រហាក់ប្រហែលនៅក្នុងច្បាប់អន្តរជាតិ(១៩៨៣) 77 *American Journal of International Law* 413, ទំព័រ 434; Emily Crawford, 'ភាពស្រពិចស្រពិលនៃខ្សែបន្ទាត់នៃទំនាស់ប្រដាប់អាវុធអន្តជាតិ និងមិនមែនអន្តរជាតិ - ការវិវឌ្ឍន៍នៃច្បាប់ទម្លាប់អន្តរជាតិជាធរមាននៅក្នុងទំនាស់ប្រដាប់អាវុធផ្ទៃក្នុង (២០០៨) ១៥ *Australian International Law Journal* 29, ទំព័រ 32 (''សណ្ឋាណដូចគ្នាជាក់ស្តែង" មិនចាំបាច់មានន័យថា ដូចគ្នាដាច់ខាតនោះទេ')។

[98] *ករណីពាក់ព័ន្ធនឹងសកម្មភាពយោធា និងយោធាប្រតិព័ទ្ធនៅក្នុង ហើយដែលប្រឆាំងនឹង Nicaragua, (Nicaragua v USA) (អង្គសេចក្តី)* [1986] របាយការណ៍ ICJ 14, ទំព័រ 98 ('តុលាការមិនពិចារណាថា ដើម្បីឱ្យវិធានមួយត្រូវបានកំណត់ថាជាទម្លាប់ការអនុវត្តដែលមានលក្ខណៈឆ្លើយតបត្រូវតែរឹងត្អឹងដាច់ខាតស្របនឹងវិធាននោះឡើយ')។ សូមមើលផងដែរ Jeane-Marie Henckaerts, 'ការវាយតម្លៃច្បាប់នានា និងទម្លាប់នៃសង្គ្រាម: ការបោះពុម្ពផ្សាយ *ច្បាប់ទម្លាប់មនុស្សធម៌អន្តរជាតិ*' ឆ្នាំ២០០៦ សេចក្តីសង្ខេបខ្លីអំពីសិទ្ធិមនុស្ស លេខ 13. ទំព័រ៩ ('ដើម្បីឱ្យមានសណ្ឋាណដូចគ្នាជាក់ស្តែង មានន័យថា រដ្ឋទាំងឡាយមិនត្រូវពាក់ព័ន្ធនៅក្នុងអំពើខុសគ្នាជាសារវ័ន្ត

បាននូវវិធាននៃទម្លាប់ដែលដាក់កាតព្វកិច្ចចំពោះរដ្ឋទាំងអស់[99] បើសិនជាគេមានភ័ស្តុតាងបញ្ជាក់ពីតំណ ឬកម្មវត្ថុមួយដែលមានការឯកភាពគ្នា[100] ឬការអនុវត្តដែលមាន "ចរឹកសាមញ្ញជាវិធានទូទៅមួយ[101] ដែលទម្លាប់នៃការអនុវត្តដូច្នេះ អាចបង្កើតបានជាវិធាននៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ។

47. តុលាការ និងសាលាក្តីនានាមិនធ្លាប់ធ្វើការវិភាគទៅលើគ្រប់រដ្ឋទាំងអស់ទេ នៅពេលធ្វើការកំណត់អំពីទម្លាប់នៃការអនុវត្តរបស់រដ្ឋ[102] ហើយអភិក្រមដូច្នេះក៏មិនចាំបាច់ដែរ ហើយ "បើតាមការអនុវត្តជាក់ស្តែង ក៏មិនអាចទៅរួចដែរ"[103]។ តាមពិត សូម្បីរដ្ឋភាគច្រើនក៏មិនចាំបាច់អ្វីត្រូវពាក់ព័ន្ធ

ណាមួយឡើយ')។

[99] គណៈកម្មាធិការបង្កើតច្បាប់ទម្លាប់(ទូទៅ)អន្តរជាតិ, សមាគមច្បាប់អន្តរជាតិ, *របាយការណ៍ចុងក្រោយរបស់គណៈកម្មាធិការ; សេចក្តីថ្លែងការណ៍អំពីគោលការណ៍ជាធរមានក្នុងការបង្កើតច្បាប់ទម្លាប់ទូទៅអន្តរជាតិ* (២០០០) ទំព័រ២៤។ *ករណីយុត្តាធិការជលផល (United Kingdom v Norway)* [1951] ICJ Rep 116 ទំព័រ 138 ('គេមិនត្រូវផ្តល់សារៈសំខាន់ខ្លាំងពេក ទៅលើការយកចិត្តទុកដាក់ចំពោះភាពមិនប្រាកដប្រជា ឬភាពផ្ទុយគ្នាពីរបីចំណុចនោះឡើយ តាមពិតទៅទម្លាប់នៃការនុវត្តរបស់រដ្ឋពិតប្រាកដ ឬជាក់ស្តែង ដែលរដ្ឋាភិបាលចក្រភពអង់គ្លេសទាមទារឱ្យលាតត្រដាងក្នុងការអនុវត្តរបស់ Norwegian )។ សូមមើលផងដែរ Sir Gerald Fitzmaurice, 'ច្បាប់ និងនីតិវិធីរបស់តុលាការយុត្តិធម៌អន្តរជាតិ, 1951-54: គោលការណ៍ទូទៅ និងប្រភពច្បាប់' (1953) 30 *British Yearbook of International Law* 1, ទំព័រ 45 ('មិនត្រូវគិតគូច្រើនពេកអំពីភាពផ្ទុយគ្នា និងភាពមិនស៊ីសង្វាក់គ្នាសើរៗនោះទេ)។

[100] Michael Wood, អ្នករាយការណ៍ពិសេស, *របាយការណ៍ទីពីរ ស្តីពីការកំណត់អត្តសញ្ញាណច្បាប់ទម្លាប់អន្តរជាតិ សម័យប្រជុំលើកទី៦៦* UN Doc A/CN/.4/672 (22 May 2014) ត្រង់ជើងទំព័រ 174 លើកយោង *អនុស្សរណៈលេខាធិការដ្ឋាន* ទំព័រ ១២ ('វិបរិណាមធម៌ជាក់លាក់នៅក្នុងទម្លាប់នៃការអនុវត្ត ជាញឹកញាប់មិនច្រានចោលគណៈកម្មការនេះ មិនឱ្យកំណត់អត្តសញ្ញាណវិធាននៃច្បាប់ទម្លាប់អន្តរជាតិឡើយ')។

[101] M. Villiger, *ច្បាប់ទម្លាប់អន្តរជាតិ និងសិទ្ធិសញ្ញានានា* (ទីក្រុងឡាអេ: Kluwer Law International, 1997) 44 ('... ភាពតឹងរ៉ឹងហួសហេតុ... នឹងធ្វើឱ្យខូចដល់ការបង្កើតច្បាប់ទម្លាប់អន្តរជាតិ … អ្វីដែលគេមើលឃើញមួយភ្លែតដំបូងអំពីការអនុវត្តមិនស៊ីសង្វាក់គ្នា អាចមានលក្ខណៈជាវិធានសាមញ្ញជាទូទៅមួយ...'។ សូមមើលផងដែរ Michael Wood, អ្នករាយការណ៍ពិសេស, *របាយការណ៍ទីពីរ ស្តីពីការកំណត់អត្តសញ្ញាណច្បាប់ទម្លាប់អន្តរជាតិ សម័យប្រជុំលើកទី៦៦* UN Doc A/CN/.4/672 (22 May 2014) *ទំព័រ* 38, ('ខណៈកាលៈទេសៈជាក់លាក់ពាក់ព័ន្ធនឹងអំពើនិមួយៗអាចខុសគ្នាជាធម្មតា "អត្ថន័យស្នូលដែលមិនផ្លាស់ប្តូរ"ដែលជារឿងធម្មតាចំពោះកាលៈទេសៈទាំងនោះ នៅតែជាលក្ខខណ្ឌតម្រូវ: បន្ទាប់មក និយ័តភាពមួយនៃអំពើអាចត្រូវបានគេសង្កេតឃើញ') លើកយោង J. Barboza, 'វិធាននៃទម្លាប់: ពីដង្កូវទៅជាមេអំបៅ', នៅក្នុង C.A. Armas Barea និងគូកន (eds.), *Liber Amicorum 'ដើម្បីរំលឹក' ដល់ចៅក្រម José María Ruda* (ទីក្រុងឡាអេ: Kluwer Law International, 2000) *ទំព័រ ៧* និង G.M. Danilenko, *ការធ្វើច្បាប់នៅក្នុងសហគមន៍អន្តរជាតិ* (Martinus Nijhoff Publishers, 1993) *ទំព័រ* 96 ('វិធាននៃទម្លាប់ណាក៏ដោយ គឺជាសព្វប្រការធម្មតាពីបុព្វកម្មនិមួយៗ')។

[102] William T Worster, 'ការផ្លាស់ប្តូរបរិមាណទៅជាគុណភាព: មាឧសរុបមិនអាចខ្វះបានក្នុងការបង្កើតច្បាប់ទម្លាប់អន្តរជាតិ' (2013) 31 *Boston University International Law Journal 1* , *ទំព័រ* 60 ('តុលាការ និងសាលាក្តីអន្តរជាតិនានា មិនធ្លាប់ចាប់យក អភិក្រមវាយតម្លៃអំពីការអនុវត្តរបស់រដ្ឋនិមួយៗគ្រប់សព្វទាំងអស់ លើគ្រប់ចំណោទដាច់ដោយឡែកទាំងឡាយស្តីពីច្បាប់អន្តរជាតិឡើយ')។

[103] Anthea E Roberts, 'ទំនៀមទំលាប់ និងអភិក្រមសម័យទំនើបចំពោះច្បាប់ទម្លាប់អន្តរជាតិ: ការផ្សះផ្សា', (2001) លេខ ៩៥ *American Journal of International Law* 757, *ទំព័រ* 767 លើកយោង Jonathan Charney 'ច្បាប់អន្តរជាតិជាសកល' (1993) 8 American Journal of International Law 529, *ទំព័រ* 537 និង David Fidler, 'ការប្រឈមនឹងផ្នត់គំនិតស្តីពីទម្លាប់'(1996)

នៅក្នុងការអនុវត្តដូច្នេះដែរ[104]។ ផ្ទុយទៅវិញ បីមានតែប្អូនដប់រដ្ឋ ក៏អាចជាការគ្រប់គ្រាន់ហើយ[105] ឲ្យតែគេគ្មានភស្តុតាងផ្ទុយ ឬការជំទាស់ជាសារវ័ន្តណាមួយទៅនឹងវិធានដែលបានចោទឡើងនោះ គឺជាការស្រេច[106]។

48. នៅពេលឈានមកដល់ទម្រង់នៃការទទួលខុសត្រូវ លក្ខខណ្ឌវិនិច្ឆ័យដែល "មានលក្ខណៈសង្គតិភាព" មិនអាចមានន័យថា ទម្លាប់អនុវត្តរបស់រដ្ឋត្រូវតែប្រើប្រាស់ធាតុផ្សំដូចគ្នាទាំងស្រុងសម្រាប់ទម្រង់នីមួយៗឡើយ។ ប្រសិនបើដូច្នេះមែន តុលាការអន្តរជាតិនានា នឹងមិនអាចអនុវត្តទម្រង់នៃការទទួលខុសត្រូវណាមួយ ដោយផ្អែកលើមូលដ្ឋាននៃច្បាប់ទំនៀមទម្លាប់អន្តរជាតិឡើយ។ សូម្បីតែទម្រង់នៃការទទួលខុសត្រូវសាមញ្ញបំផុត ដូចជា ការរៀបចំផែនការ និងការបញ្ជា មានលក្ខខណ្ឌតម្រូវខុសគ្នា នៅក្នុងយុត្តាធិការផ្សេងៗគ្នា ជាពិសេស ទាក់ទិននឹងលក្ខខណ្ឌតម្រូវអត្តនោម័ត។ ឧទាហរណ៍ យុត្តាធិការមួយចំនួន តម្រូវឲ្យមាន "ចេតនា", យុត្តាធិការផ្សេងទៀត តម្រូវឲ្យមាន*ភាពធ្វេសប្រហែសធ្ងន់ធ្ងរ*, រីឯយុត្តាធិការមួយចំនួនទៀត តម្រូវថា ជនជាប់ចោទដឹងថា ឧក្រិដ្ឋកម្មនឹងកើតមានឡើង "នៅក្នុងស្ថានភាពព្រឹត្តិការណ៍ធម្មតា" ហើយយុត្តាធិការខ្លះទៀត (ដូចជា អ.វ.ត.ក) តម្រូវថាជនជាប់ចោទដឹងអំពីភវនីយភាពច្បាស់លាស់ដែលថានឹងមានការប្រព្រឹត្តិឧក្រិដ្ឋកម្មផ្សេងៗ។ ដូច្នេះ នៅពេលពិនិត្យមើលថាតើ សហឧក្រិដ្ឋកម្មរួមទម្រង់ទី III ដែលមានលក្ខខណ្ឌតម្រូវនៃអំពើដូចគ្នាទាំងស្រុងទៅនឹងសហឧក្រិដ្ឋកម្មរួមទម្រង់ទី I ជាផ្នែកនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅត្រឹមឆ្នាំ១៩៧៥ ឬយ៉ាងណានោះ ភាពខុសគ្នាបន្តិចបន្តួចនៅក្នុងរបៀបនៃការបញ្ជាក់អំពីលក្ខខណ្ឌតម្រូវអត្តនោម័ត ពីប្រព័ន្ធមួយទៅប្រព័ន្ធមួយទៀតនោះ មិនគួររារាំងដល់សំអាងហេតុបែបនេះឡើយ។

---

*German Year Book of International Law* 198, ត្រង់កថាខណ្ឌ 203, 217។

[104] គណៈកម្មាធិការបង្កើតច្បាប់ទម្លាប់(ទូទៅ)អន្តរជាតិ, សមាគមច្បាប់អន្តរជាតិ, *របាយការណ៍ចុងក្រោយរបស់គណៈកម្មាធិការ; សេចក្តីថ្លែងការណ៍អំពីគោលការណ៍ជាធរមានក្នុងការបង្កើតច្បាប់ទម្លាប់ទូទៅអន្តរជាតិ* (២០០០) *ទំព័រ* ២៥ ('ចែងថា ការចូលរួម គឺជាតំណាងគ្រប់គ្រាន់ដែលជាធម្មតា គេមិនចាំបាច់ឡើយសូម្បីតែសម្រាប់រដ្ឋភាគច្រើន ដើម្បីចូលរួមពាក់ព័ន្ធក្នុងការអនុវត្តដូច្នេះ ឲ្យតែពុំមានការជំទាស់ជាសារវ័ន្តណាមួយ គឺជាការស្រេច')។

[105] Anthea E Roberts, 'ទំនៀមទំលាប់ និងអភិក្រមសម័យទំនើបចំពោះច្បាប់ទម្លាប់អន្តរជាតិ: ការផ្សះផ្សា' (២០០១), លេខ ៩៥ *American Journal of International Law* 757, *ទំព័រ* 767 ('ទម្លាប់ភាគច្រើនត្រូវបានគេរកឃើញថា មាននៅក្នុងមូលដ្ឋាននៃការអនុវត្តរបស់បណ្តារដ្ឋមួយចំនួនមិនលើសពីពីរបីរដ្ឋប៉ុណ្ណោះ')។

[106] គណៈកម្មាធិការបង្កើតច្បាប់ទម្លាប់(ទូទៅ)អន្តរជាតិ, សមាគមច្បាប់អន្តរជាតិ "*របាយការណ៍ចុងក្រោយរបស់គណៈកម្មាធិការ; សេចក្តីថ្លែងការណ៍អំពីគោលការណ៍ជាធរមានក្នុងការបង្កើតច្បាប់ទម្លាប់ទូទៅអន្តរជាតិ* (២០០០) *ទំព័រ* ២៥"។ Michael Akehurst, 'ទម្លាប់ជាប្រភពមួយនៃច្បាប់អន្តរជាតិ', (1975) 47 *British Handbook of International Law* 1, *ទំព័រ* 12។

49. នៅពេលធ្វើការវាយតម្លៃពីទម្លាប់នៃការអនុវត្តរបស់រដ្ឋណាមួយ គេត្រូវសួរថាតើមានការគាំទ្រចំពោះអត្ថិភាពនៃ JCE III ដែរឬអត់នោះ កត្តាសម្រេចគឺថាតើផ្នែកស្នូល និងគោលការណ៍នៃគំនិតដែលជាចំណែកនៅក្នុងការកំណត់អំពីក្រុមឧក្រិដ្ឋកម្ម និងភាពអាចព្យាករបានសមហេតុផលនោះ - មាននៅក្នុងប្បញ្ញត្តិ និងយុត្តិសាស្ត្រច្បាប់ជាធរមានរបស់រដ្ឋនោះដែរឬទេ។ វាមិនមែនសម្រេចដោយការប្រើពាក្យពេចន៍ខុសគ្នារបស់រដ្ឋនោះឡើយ ទាំងពាក្យដែលបានបង្កើតឡើងដោយខ្លួនឯង និងពាក្យដែលបានអនុម័តតាមករណីយុត្តិសាស្ត្រអន្តរជាតិ ដែលមានចែងទាក់ទងការទទួលខុសត្រូវ JCE III។ ដោយសារមានភាពខុសគ្នាយ៉ាងទូលំទូលាយនៃប្រព័ន្ធច្បាប់ទំនៀមទំលាប់ និងភាសា ដែលមិនអាចជៀសរួច នៅក្នុងការប្រើពាក្យពេចន៍ដែលបញ្ញត្តិអំពើជាក់លាក់មួយចំនួន។

50. ផ្អែកលើមូលដ្ឋាននៃការវិភាគលើការអនុវត្តក្នុងស្រុករបស់ប្រទេសចំនួន ៤០[107] សហព្រះរាជអាជ្ញាសន្និដ្ឋានថា យ៉ាងយូរបំផុតត្រឹមឆ្នាំ១៩៧៥ ការទទួលខុសត្រូវព្រហ្មទណ្ឌជាលក្ខណៈបុគ្គលចំពោះឧក្រិដ្ឋកម្មដែលអាចប្រមើលមើលឃើញ បើទោះជាគ្មានចេតនាក្តី ដែលកើតចេញពីសហឧក្រិដ្ឋកម្មរួម គឺជាវិធាននៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ។ ដើម្បីឲ្យមានភាពជាតំណាងគ្រប់គ្រាន់ វិធីសាស្ត្រដែលបានប្រើប្រាស់ដោយសហព្រះរាជអាជ្ញា ធានាថា ប្រទេសនានាដែលបានពិនិត្យឡើងវិញ គឺជាភាពជាតំណាងសមស្របនៃសហគមន៍អន្តរជាតិ ដែលតំណាងនូវ **(១) ទីតាំងភូមិសាស្ត្រ** ខុសៗគ្នា - ទ្វីបអាហ្វ្រិក (១១ ប្រទេស)[108] ទ្វីបអាស៊ី (១០ ប្រទេស)[109] ទ្វីបអឺរ៉ុប (៧ ប្រទេស រួមទាំង សហភាពសូវៀត)[110] មជ្ឈិមបូព៌ា (៣ ប្រទេស)[111] ទ្វីបអាមេរិកខាងជើង (២

---

107 ប្រទេសអូស្ត្រាលី ប្រទេសអូទ្រីស ប្រទេសបង់ក្លាដេស ប្រទេស Bermuda ប្រទេសបុតស្វាណា ប្រទេសកម្ពុជា ប្រទេសកាណាដា ប្រទេសអេហ្ស៊ីប ប្រទេសអេត្យូពី ប្រទេសហ្វីជី ប្រទេសបារាំង ប្រទេសអាល្លឺម៉ង់ ប្រទេសហ្គាណា ប្រទេសក្រិច ប្រទេសឥណ្ឌា ប្រទេសអ៊ីរ៉ាក់ ប្រទេសអ៊ីស្រាអែល ប្រទេសជប៉ុន ប្រទេសកេនយ៉ា ប្រទេសម៉ាឡាវី ប្រទេសម៉ាឡេស៊ី ប្រទេសប្រទេសនូវែលសេឡង់ ប្រទេសនីហ្សេរីយ៉ា ប្រទេសប៉ាគីស្ថាន ប្រទេសប៉ាពូហ្គីណេ ប្រទេសហ្វីលីពីន ប្រទេសប៉ូឡូញ សហភាពសូវៀត ប្រទេសសីស្ហែល ប្រទេសអាហ្វ្រិកខាងត្បូង កូរ៉េខាងត្បូង ប្រទេសស្រីលង្កា ប្រទេសតង់សានី ប្រទេសថៃ ប្រទេសអ៊ូហ្គង់ដា ចក្រភពអង់គ្លេស សហរដ្ឋអាមេរិក ប្រទេសអ៊ុយរូហ្គាយ ប្រទេស Western Samoa និងប្រទេសសំប៊ី។

108 ប្រទេសបុតស្វាណា ប្រទេសអេត្យូពី ប្រទេសហ្គានណា ប្រទេសកែ្កនយ៉ា ប្រទេសម៉ាឡាវី ប្រទេសនីហ្សេរីយ៉ា ប្រទេសសីស្ហែល ប្រទេសអាហ្វ្រិកខាងត្បូង ប្រទេសតង់សានី ប្រទេសអ៊ូហ្គង់ដា និងប្រទេសសំប៊ី។

109 ប្រទេសបង់ក្លាដេស ប្រទេសកម្ពុជា ប្រទេសឥណ្ឌា ប្រទេសជប៉ុន ប្រទេសម៉ាឡេស៊ី ប្រទេសប៉ាគីស្ថាន ប្រទេសហ្វីលីពីន ប្រទេសកូរ៉េខាងត្បូង ប្រទេសស្រីលង្កា និងប្រទេសថៃ។

110 ប្រទេសអូទ្រីស ប្រទេសបារាំង ប្រទេសអាល្លឺម៉ង់ ប្រទេសក្រិច ប្រទេសប៉ូឡូញ សហភាពសូវៀត និងចក្រភពអង់គ្លេស។

111 ប្រទេសអេហ្ស៊ីប ប្រទេសអ៊ីរ៉ាក់ និងប្រទេសអ៊ីស្រាអែល។

ប្រទេស)[112] ទ្វីបអូសេអានី (៥ ប្រទេស)[113] និងទ្វីបអាមេរិកខាងត្បូង/កណ្តាល (២ ប្រទេស)[114] (២) **ប្រព័ន្ធច្បាប់ផ្សេងៗគ្នា**[115] - ប្រព័ន្ធច្បាប់ស៊ីវិលឡូ (១៥ ប្រទេស)[116] ប្រព័ន្ធច្បាប់ខំមិនឡូ (២៣ ប្រទេស)[117] និងប្រព័ន្ធច្បាប់ចម្រុះ (២ ប្រទេស)[118] និង (៣) កម្រិតនៃ**ឥទ្ធិពលអន្តរជាតិទៅតាមពេលវេលាជាក់ស្តែង** - មហាអំណាចធំៗ (៦ ប្រទេស)[119] និងផ្សេងទៀត (៣៤ ប្រទេស)[120]។

51. ក្រៅពីភាពខុសគ្នាលើពាក្យបច្ចេកទេស វាបង្ហាញច្បាស់ចេញពីច្បាប់ និងសេចក្តីសម្រេចរបស់តុលាការរបស់ប្រទេសនានាដែលត្រូវបានគេវិភាគថា ប្រទេសភាគច្រើនបំផុតនោះបានទទួលយកយ៉ាងច្បាស់លាស់ ឬ តាមការសន្និដ្ឋាននូវទម្រង់នៃការទទួលខុសត្រូវដែលមានលក្ខណៈស្រដៀងគ្នាខ្លាំងទៅនឹងសហឧក្រិដ្ឋកម្មរួម ទម្រង់ទី III នៅមុនឆ្នាំ ១៩៧៥ ដោយបញ្ជាក់ច្បាស់ ឬមិនច្បាស់។

---

112 ប្រទេសកាណាដា និងសហរដ្ឋអាមេរិក។

113 ប្រទេសអូស្ត្រាលី ប្រទេសហ្វីជី ប្រទេសនូវែលសេឡង់ ប្រទេសនូវែលហ្គីណេ និងប្រទេស Western Samoa.

114 ប្រទេស Bermuda និងប្រទេសអុយរ៉ាហ្គាយ។

115 ប្រទេសដែលប្រើទម្លាប់ច្បាប់ស៊ីវិល ឬក៏ common law ត្រូវបានជ្រើសរើស យកមក ដើម្បីឆ្លុះបញ្ចាំងប្រព័ន្ធច្បាប់សំខាន់ជាងគេនៅលើពិភពលោក។ ទោះបីជាមានភាពខុសៗគ្នាយ៉ាងពិតប្រាកដនៅក្នុងប្រព័ន្ធនេះក៏ដោយ ភាពខុសគ្នាបែបនេះរួមមានប្រព័ន្ធតូចៗ *នៅក្នុង*ក្របខណ្ឌច្បាប់ស៊ីវិល -common law ទូលាយជាងនេះ។

116 ប្រទេសអូទ្រីស ប្រទេសអេហ្ស៊ីប ប្រទេសអេត្យូពី ប្រទេសបារាំង ប្រទេសអាល្លឺម៉ង់ ប្រទេសក្រិច ប្រទេសអ៊ីរ៉ាក់ ប្រទេសជប៉ុន ប្រទេសហ្វីលីពីន ប្រទេសប៉ូឡូញ សហភាពសូវៀត ប្រទេសកូរ៉េខាងត្បូង ប្រទេសថៃ និងប្រទេសអ៊ុយរូហ្គាយ។

117 ប្រទេសអូស្ត្រាលី ប្រទេសបង់ក្លាដេស ប្រទេស Bermuda ប្រទេសបុតស្វាណា ប្រទេសកាណាដា ប្រទេសហ្វីជី ប្រទេសហ្គាណា ប្រទេសឥណ្ឌា ប្រទេសអ៊ីស្រាអែល ប្រទេសកេនយ៉ា ប្រទេសម៉ាឡាវី ប្រទេសម៉ាឡេស៊ី ប្រទេសនូវែលសេឡង់ ប្រទេសនីហ្សេរីយ៉ា ប្រទេសប៉ាគីស្ថាន ប្រទេសនូវែលហ្គីណេ ប្រទេសសីង្ហបុរី ប្រទេសតង់សានី ប្រទេសអ៊ូហ្គង់ដា ចក្រភពអង់គ្លេស សហរដ្ឋអាមេរិក ប្រទេស Western Samoa និងប្រទេសសំប៊ី។

118 ប្រទេសអាហ្វ្រិកខាងត្បូង និងប្រទេសស្រីលង្កា។

119 ប្រទេសបារាំង ប្រទេសអាល្លឺម៉ង់ ចក្រភពអង់គ្លេស សហរដ្ឋអាមេរិក និងសភាពសូវៀត។

120 ប្រទេសអូស្ត្រាលី ប្រទេសអូទ្រីស ប្រទេសកាណាដា ប្រទេសអេហ្ស៊ីប ប្រទេសឥណ្ឌា ប្រទេសជប៉ុន ប្រទេសកេនយ៉ា ប្រទេសម៉ាឡេស៊ីប្រទេសនូវែលសេឡង់ ប្រទេសនីហ្សេរីយ៉ា ប្រទេសអាហ្វ្រិកខាងត្បូង និងប្រទេសសំប៊ី។ ប្រទេសបង់ក្លាដេស ប្រទេស Bermuda ប្រទេសបុតស្វាណា ប្រទេសអេត្យូពី ប្រទេសហ្វីជី ប្រទេសហ្គាណា ប្រទេសក្រិច ប្រទេសអ៊ីរ៉ាក់ ប្រទេសអ៊ីស្រាអែល ប្រទេសម៉ាឡាវី ប្រទេសប៉ាគីស្ថាន ប្រទេសនូវែលហ្គីណេ ប្រទេសហ្វីលីពីន ប្រទេសប៉ូឡូញ ប្រទេសសីង្ហបុរី ប្រទេសកូរ៉េខាងត្បូង ប្រទេសស្រីលង្កា ប្រទេសតង់សានី ប្រទេសថៃ ប្រទេសអ៊ូហ្គង់ដា ប្រទេសអ៊ូហ្គង់ដា និងប្រទេស Western Samoa។

52. ប្រទេសចំនួនម្ភៃបី (២៣) មានច្បាប់ព្រហ្មទណ្ឌជាធរមាន នៅក្នុងប្រទេសរបស់ខ្លួននៅមុនឆ្នាំ ១៩៧៥ ដែលបានបញ្ចូលពាក្យបច្ចេកទេសដូចគ្នាបេះបិទ ឬស្រដៀងគ្នាខ្លាំងទៅនឹងពាក្យបច្ចេកទេសនៃសហឧក្រិដ្ឋកម្មរួម ទម្រង់ទី III។ ប្រទេសទាំងនេះមានដូចជា៖ ប្រទេសអូស្ត្រាលី[121] ប្រទេស Bermuda[122] ប្រទេសបុតស្វាណា[123] ប្រទេសកាណាដា[124] ប្រទេសបារាំង[125] ប្រទេសហ្វីជី[126] ប្រទេសហ្គាណា[127] ប្រទេសអ៊ីរ៉ាក់[128] ប្រទេសអ៊ីស្រាអែល[129] ប្រទេសអ៊ីតាលី[130] ប្រទេសកេនយ៉ា[131] ប្រទេសម៉ាឡាវី[132] ប្រទេសនូវែលសេឡង់[133] ប្រទេសនីហ្សេរីយ៉ា[134] ប្រទេស

---

121 *ច្បាប់ព្រហ្មទណ្ឌរបស់* New South Wales *ឆ្នាំ ១៩០០*, s. 18(1)(a)។ *ក្រមព្រហ្មទណ្ឌឆ្នាំ ១៩២៤* ប្រទេស Tasmania, ss. 4, 157(1)(c)។ *ក្រមព្រហ្មទណ្ឌឆ្នាំ ១៨៩៩* រដ្ឋ Queensland, s. 302(2)។ *ក្រមព្រហ្មទណ្ឌឆ្នាំ ១៩០២* រដ្ឋ Western Australia, s. 8។ *កម្រងក្រមព្រហ្មទណ្ឌឆ្នាំ ១៩១៣* រដ្ឋ Western Australia, s. 279។ រឿងក្តី *Brennan ទល់នឹង The King* (1936) 55 CLR 253។ រឿងក្តី *Johns* ទល់នឹង *R* (1980) 143 CLR 108។ រឿងក្តី *Kaporonovski ទល់នឹង R* (1973) 47 ALJR 472។ រឿងក្តី *R ទល់នឹង Solomon* [1959] Qd R 123 ត្រង់កថាខណ្ឌ១២៩។ រឿងក្តី *R ទល់នឹង Surridge* (1942) 42 SR (NSW) 278។ រឿងក្តី *R ទល់នឹង Vandine* [1970] 1 NSWR 252 ត្រង់កថាខណ្ឌ២៥៧។ រឿងក្តី *Stuart ទល់នឹង The Queen* (1974) 4 ALR 545។

122 *ក្រមព្រហ្មទណ្ឌរបស់ប៊ែរមុដា ឆ្នាំ ១៩៧០* s. 28។

123 *ក្រមព្រហ្មទណ្ឌរបស់បុស្វាណា ឆ្នាំ ១៩៦៤* s. 22, 23។

124 *ក្រមព្រហ្មទណ្ឌរបស់កាណាដា ឆ្នាំ ១៨៩៣* s. 61(2)។ រឿងក្តី *Cathro ទល់នឹង The Queen* [1956] SCR 101។ រឿងក្តី *R ទល់នឹង Guay & Guay* [1957] OR 120។ រឿងក្តី *R ទល់នឹង LeBlanc* (1948) 92 CCC 47។ រឿងក្តី *R ទល់នឹង Silverstone* [1931] OR 50។

125 *ក្រមព្រហ្មទណ្ឌរបស់បារាំង ឆ្នាំ១៨១០* មាត្រា ៩៧, ២៦៥-២៦៦ និង៣១៣ Cour de Cassation, Chambre Criminelle, du 7 Décembre 1966 ។

126 *ក្រមព្រហ្មទណ្ឌរបស់ហ្វីជីឆ្នាំ ១៩៧០* s. 22។

127 *ក្រមព្រហ្មទណ្ឌរបស់ហ្គាណាឆ្នាំ ១៩៦០* s. 21។

128 *ក្រមព្រហ្មទណ្ឌរបស់អ៊ីរ៉ាក់ ឆ្នាំ ១៩៦៩* មាត្រា ៥៣។

129 *ក្រមព្រហ្មទណ្ឌរបស់អ៊ីស្រាអែល ឆ្នាំ ១៩៣៦* s. 24។ រឿងក្តី *Goldstein ទល់នឹង អគ្គរដ្ឋអាជ្ញា* [1954] PD 10, ត្រង់កថាខណ្ឌ 505។ រឿងក្តី *Yossef Dahan និង David Ben Haroush ទល់នឹង ប្រទេសអ៊ីស្រាអែល* (1969) 23(i) PD, 197។

130 *ក្រមព្រហ្មទណ្ឌរបស់ប្រទេសអ៊ីតាលី* ឆ្នាំ១៩៣០ មាត្រា ១១០, ១១៦។ សាលដីការបស់តុលាការធម្មនុញ្ញអ៊ីតាលីចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ១៩៦៥ លេខ ៤២ Court of Cassation (3 March 1978), Court of Cassation (4 March 1988), Rivista Penale, 1986 ទំព័រ 421 ។

131 *ក្រមព្រហ្មទណ្ឌកេនយ៉ា ឆ្នាំ ១៩៣០* ss. 21, 22(1)។ រឿងក្តី *Dickson Mwangi Munene និង Anor ទល់នឹង R* [2011] eKLR។ រឿងក្តី *R ទល់នឹង Mikaeri Kyeyune និង Ors* (1941) 8 EACA 84។ រឿងក្តី *Solomon Mungai និង Ors ទល់នឹង Republic* [1965] EA 363។ រឿងក្តី *Wanjiro d/o Wamario ទល់នឹង R* (1955) 22 EACA 521។

នូវែលហ្គីណេ[135] ប្រទេសសីស្ហែល[136] ប្រទេសអាហ្វ្រិកខាងត្បូង[137] ប្រទេសស្រីលង្កា[138] ប្រទេសតង់សានី[139] ប្រទេសអ៊ូហ្គង់ដា[140] សហរដ្ឋអាមេរិក[141] ប្រទេសសាម័រ[142] និងប្រទេសសំប៊ី[143]។

---

132 *ក្រមព្រហ្មទណ្ឌ ម៉ាឡាវី ឆ្នាំ ១៩៣០* s. 22។

133 *ច្បាប់ព្រហ្មទណ្ឌណូវែលហ្សេឡង់ដ៍ ឆ្នាំ ១៩៦១* s. 66។ រឿងក្ដី *R ទល់នឹង Gush* [1980] 2 NZLR 92 ត្រង់កថាខណ្ឌ 94-96។

134 *ក្រមព្រហ្មទណ្ឌ នីហ្សេរីយ៉ា ឆ្នាំ ១៩១៦* s. 8។ រឿងក្ដី *Digbehin និង Ors ទល់នឹង R* (1963) All NLR 388។ រឿងក្ដី *Garba* ។ *ទល់នឹង Hadejia Native Authority* (1961) NRNLR 44។

135 *ក្រមព្រហ្មទណ្ឌ របស់ប៉ាពួញូហ្គីណេ ឆ្នាំ ១៩៧៤* s. 8។

136 *ក្រមព្រហ្មទណ្ឌ របស់ស៊ីស្ហែល ឆ្នាំ ១៩៥៥* s. 23។

137 *ក្រមព្រហ្មទណ្ឌរបស់ទឹកដីជនជាតិដើមនៃប្រទេសអាហ្វ្រិកខាងត្បូង ឆ្នាំ1886* s. 78។ រឿងក្ដី *R ទល់នឹង Garnsworthy និង Ors* [1923] WLD 17 ត្រង់ 19។ រឿងក្ដី *R ទល់នឹង Morela* 1947 (3) SA 147 (A)។ រឿងក្ដី *R ទល់នឹង Skjepe និង Ors* 1946 AD 1101។ សូមមើលផងដែរ រឿងក្ដី *Gaillard និង Andere ទល់នឹង S* 1966 (1) PH H74 (AD)។ រឿងក្ដី *R ទល់នឹង Kubuse និង Ors* 1945 AD 189 ត្រង់200។ រឿងក្ដី *R ទល់នឹង Matsitwane និង Anor*1942 AD 213។ រឿងក្ដី *R ទល់នឹង Ndhlangisa & Anor* 1946 AD 1101។ រឿងក្ដី *R ទល់នឹង Ngcobo* 1928 AD 372។ រឿងក្ដី *S ទល់នឹង Nkomo និង Anor* 1966 (1) SA 831 (AD)។ រឿងក្ដី *S ទល់នឹង Dambalaza និង Ors* 1964 (2) SA 783 (AD)។

138 *ក្រមព្រហ្មទណ្ឌ របស់ប្រទេសស្រីលង្កា ឆ្នាំ ១៨៨៣* s. 146។ រឿងក្ដី *Khan ទល់នឹង Ariyadasa* (1965) 67 NLR 145 (PC) ត្រង់កថាខណ្ឌ 154-155។ រឿងក្ដី *The King ទល់នឹង Abeywickrema និងគូកន* (1943) 44 NLR 254 ត្រង់កថាខណ្ឌ 256។ រឿងក្ដី *The King ទល់នឹង Sellathurai* (1947) 48 NLR 570 ត្រង់កថាខណ្ឌ 574។ រឿងក្ដី *The Queen ទល់នឹង Appuhamy* [1960] LKSC 8 ត្រង់កថាខណ្ឌ 485 490-491។

139 *ក្រមព្រហ្មទណ្ឌរបស់ប្រទេសតង់ស្សានី ឆ្នាំ ១៩៤៥* s. 23។

140 *ក្រមព្រហ្មទណ្ឌរបស់ប្រទេសអ៊ូហ្គាន់ដា ឆ្នាំ ១៩៥០* s. 20។ រឿងក្ដី *Dracaku s/o Afia ទល់នឹង R* [1963] EA 363។ រឿងក្ដី *R ទល់នឹង Dominiko Omenyi s/o Obuka* (1943) 10 EACA 81។ រឿងក្ដី *Stanley Musinga និង Ors ទល់នឹង R* (1951) 18 EA CA 211។

141 *ក្រមព្រហ្មទណ្ឌ ឆ្នាំ ១៩៦៩ របស់រដ្ឋ Kansas,* s. 21-3205។ *ក្រមព្រហ្មទណ្ឌ ឆ្នាំ១៩៦៣ របស់រដ្ឋ Minnesota,* s. 609.05។ *ក្រមព្រហ្មទណ្ឌ ឆ្នាំ ១៩៧៣ របស់រដ្ឋ Texas,* s. 7.02(b)។ *ក្រមព្រហ្មទណ្ឌ ឆ្នាំ ១៩៥៥ របស់រដ្ឋ Wisconsin,* s. 939.05។ រឿងក្ដី *Pinkerton ទល់នឹង សហរដ្ឋអាមេរិក* 328 US 640 (1946) ។ រឿងក្ដី *សហរដ្ឋអាមេរិក ទល់នឹង Decker* 543 F.2d 1102 (1976)។ សូមមើលផងដែរ រឿងក្ដី *Park ទល់នឹង Huff* 506 F.2d 849 (1975) ត្រង់កថាខណ្ឌ ៥៧-៥៩ ៧៥-៧៦។ រឿងក្ដី *State ទល់នឹង Moore* 580 S.W.2d 747 (1979) ត្រង់កថាខណ្ឌ 752។ រឿងក្ដី *State ទល់នឹង Stein*, 70 N.J. 369 (1976)។

142 *ច្បាប់ព្រហ្មទណ្ឌ របស់ប្រទេសសាម៉ោខាងលិច ឆ្នាំ ១៩៦១* s. 23(2)។

143 *ក្រមព្រហ្មទណ្ឌ ឆ្នាំ ១៩៣១* s. 22។ រឿងក្ដី *Mutambo និង 5 Others ទល់នឹង The People* [1965] ZR 15 1។ រឿងក្ដី *Petro និងជនម្នាក់ទៀត ទល់នឹង The People* (1967) ZR 140 (CA)។ រឿងក្ដី *Winfred Sakala ទល់នឹង People*

បើទោះជាប្រទេសភាគច្រើនទាំងនេះបានប្រើប្រាស់ពាក្យ "ផលវិបាកដែលអាចកើតមាន" ខុសពីពាក្យ "ផលវិបាកដែលអាចប្រមើលមើលឃើញ" (ដូចបានប្រើប្រាស់ដោយអង្គជំនុំជម្រះសាលាដំបូង)ក៏ដោយ ក៏ការពិនិត្យឡើងវិញលើយុត្តិសាស្ត្រដែលមានស្រាប់ពីបណ្តាប្រទេសទាំងនេះបង្ហាញឲ្យឃើញថា ឃ្លាទាំងពីរនេះត្រូវបានបកស្រាយក្នុងលក្ខណៈដូចគ្នា និងនាំឲ្យចេញសេចក្តីសម្រេចរបស់តុលាការស៊ីសង្វាក់គ្នានៅទូទាំងបណ្តាប្រទេសទាំងអស់ ដែលត្រូវបានសិក្សាអង្កេតទាំងនេះ។

53. ទោះបីជាពុំបានពង្រីកយ៉ាងច្បាស់លាស់នូវការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្ម ដែលអាចប្រមើលមើលឃើញនៅក្រៅផែនការរួមក៏ដោយ ប្រទេសចំនួន ១៨ ប្រទេសផ្សេងទៀតដែលត្រូវបានពិនិត្យមើលនោះ បានទទួលស្គាល់ថា ទស្សនាទានចំបងស្តីអំពីការទទួលខុសត្រូវនៃសហឧក្រិដ្ឋកម្មរួម ទម្រង់ទី III – ការចាប់ឲ្យទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មជាក្រុម និងចំពោះឧក្រិដ្ឋកម្មដែលអាចប្រមើលមើលឃើញយ៉ាងសមហេតុសមផល។ ទោះបីជាមានបទប្បញ្ញត្តិចែងពាក់ព័ន្ធនឹងបទល្មើសនីមួយៗក៏ដោយ ក៏បទប្បញ្ញត្តិទាំងនេះរួមមានបទប្បញ្ញត្តិដែលបានដាក់ការទទួលខុសត្រូវព្រហ្មទណ្ឌក្នុងករណីដែលឧក្រិដ្ឋកម្មនោះអាចត្រូវបានប្រមើលមើលឃើញ ឬអាចជាផលវិបាកដែលអាចកើតឡើងចេញពីអំពើរបស់បុគ្គលណាម្នាក់។ ច្បាប់នេះគូសបញ្ជាក់ថា ភាពអាចប្រមើលមើលឃើញគឺជាធាតុផ្សំសំខាន់នៃ សហឧក្រិដ្ឋកម្មរួម ទម្រង់ទី III ហើយនៅពេលដែលបទប្បញ្ញត្តិទាំងនេះត្រូវបានអានរួមជាមួយនឹងបទប្បញ្ញត្តិស្តីពីការប្រព្រឹត្តជាក្រុម ការអនុវត្តរបស់ប្រទេសទាំងនេះ *គឺ* គាំទ្រចំពោះការចាប់ឲ្យទទួលខុសត្រូវចំពោះសហឧក្រិដ្ឋកម្មរួម ទម្រង់ទី III ឬ យ៉ាងហោចណាស់ ការអនុវត្តរបស់ប្រទេសទាំងនេះមានលក្ខណៈស៊ីសង្វាក់គ្នានឹងការទទួលខុសត្រូវបែបនេះ។ ប្រទេសទាំងនេះរួមមាន៖ ប្រទេសអូទ្រីស[144] ប្រទេសបង់ក្លាដេស[145] ប្រទេសកម្ពុជា[146] ប្រទេសអេហ្ស៊ីព[147] ប្រទេសអេត្យូពី[148] ប្រទេសអាល្លឺម៉ង់[149] ប្រទេសក្រិច[150] ប្រទេសឥណ្ឌា[151] ប្រទេស

(1987) ZR 23 (SC)។

144 *ច្បាប់ព្រហ្មទណ្ឌ អូទ្រីស្ត ឆ្នាំ ១៨៥២ និងឆ្នាំ ១៩៤៥* ដែលបានធ្វើវិសោធនកម្មនៅក្នុងច្បាប់ព្រហ្មទណ្ឌឆ្នាំ ១៩៦៥ s. 1, 5, 126, 135(2), 195។

145 *ក្រមព្រហ្មទណ្ឌ បង់ក្លាដេស ឆ្នាំ ១៨៦០* s. 34, 146, 149, 110, 111, 112, 146, 149។

146 *ក្រមព្រហ្មទណ្ឌ កម្ពុជា ឆ្នាំ ១៩២៨ និងក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦* មាត្រា ១៤៥, ២៣១។

147 *ក្រមព្រហ្មទណ្ឌ អេហ្ស៊ីប ឆ្នាំ ១៩៣៧* មាត្រា ៤៣។

148 *ក្រមព្រហ្មទណ្ឌ អេត្យូពី ឆ្នាំ ១៩៥៧* s. 35។

149 *ច្បាប់ក្រុមប្រឹក្សាត្រួតពិនិត្យលេខ ១០ (ការដាក់ទណ្ឌកម្មលើជនដែលមានពិរុទ្ធភាពលើឧក្រិដ្ឋកម្មសង្គ្រាម ឧក្រិដ្ឋកម្ម*

ជប៉ុន[152] ប្រទេសម៉ាឡេស៊ី[153] ប្រទេស ប៉ាគីស្ថាន[154] ប្រទេសហ្វីលីពីន[155] ប្រទេសប៉ូឡូញ[156] សហ

---

*ប្រឆាំងនឹងការដាក់ទណ្ឌកម្មលើជនដែលមានពិរុទ្ធភាពលើឧក្រិដ្ឋកម្មសង្គ្រាម ឧក្រិដ្ឋកម្មប្រឆាំងនឹងសន្តិភាព និងប្រឆាំងនឹងមនុស្សជាតិ)* (ចុះថ្ងៃទី ២០ ខែធ្នូ ឆ្នាំ ១៩៤៥) មាត្រា ២(២)។ *ក្រមព្រហ្មទណ្ឌ ឆ្នាំ ១៨៧១* មាត្រា ៤៧, ៨២, ១១៥, ២១៤។ BGH 17. 33 (1967)។ BGH 11.05 (1971) - VI ZR 211/69។ រឿងក្តី *សហរដ្ឋអាមេរិក ទល់នឹង Goebell,* និងអ្នកផ្សេងទៀត ថ្ងៃទី៦ ខែ កុម្ភៈ - ថ្ងៃទី ២១ ខែ មីនា ឆ្នាំ ១៩៤៦ ("រឿងក្តីកោះ *Borkum*")។ សាលាក្តីយោធាចក្រភពអង់គ្លេសសម្រាប់ការជំនុំជម្រះលើឧក្រិដ្ឋជនសង្គ្រាម *ការជំនុំជម្រះ Erich Heyer Essen*)១៩៤៧("*រឿងក្តីសម្លាប់ Essen*") ត្រង់ទំព័រ៨៩, ៩១ ការជំនុំជម្រះឧក្រិដ្ឋជនធំៗនៅចំពោះមុខសាលាក្តីយោធាអន្តរជាតិ វ៉ុល I សាលក្រម នូរ៉ឹមប៊ឺក ថ្ងៃទី២២ សីហា-១ តុលា ១៩៤៦ របស់ UNWCC វ៉ុល I រឿងក្តី *Saucke* ត្រង់ទំព័រ៤៦១, ៥១៥ ការជំនុំជម្រះឧក្រិដ្ឋជនធំៗនៅចំពោះមុខសាលាក្តីយោធាអន្តរជាតិ វ៉ុល I សាលក្រម នូរ៉ឹមប៊ឺក ថ្ងៃទី។ ថ្ងៃទី ១៤ ខែ វិច្ឆិកា ដល់ ថ្ងៃទី ១ ខែ តុលា ឆ្នាំ ១៩៤៦ ("*រឿងក្តី Spee*") ត្រង់ទំព័រ៣៣១, ៣៣២។

150 *ក្រមព្រហ្មទណ្ឌ ក្រិច ឆ្នាំ ១៩៥០* មាត្រា ២៧, ៤៥, ១៨៩(១), ៣៧៤, ៣៨០។ I. Anagnostopoulos and K. Magliveras, 'Criminal Law in Greece' in F. Verbruggen & V. Franssen (eds.) *International Encyclopaedia of Laws* (The Hague: Kluwer Law International 2000) ត្រង់កថាខណ្ឌ ៨៧។

151 *ក្រមព្រហ្មទណ្ឌ ឥណ្ឌា ឆ្នាំ ១៨៦០* ss. 34, 149។ រឿងក្តី *Chikkarange Gowda ទល់នឹង State of Mysore* AIR (1956) SC 731។ រឿងក្តី *Nanak Chand ទល់នឹង The State Of Punjab* (1955) SCR (1)1201។ រឿងក្តី *Queen ទល់នឹង Sabid Ali* (1873) 20 WR 5 Cr។

152 *ក្រមព្រហ្មទណ្ឌ ជប៉ុន ឆ្នាំ ១៩០៧* មាត្រា ៦០, ៦១(១), ៦២, ១១១, ១៨១(១), ១៧៨, ២៤០, ២៤១។ សាលដីការបស់តុលាការកំពូល 12 Keishu 1718 (ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ១៩៥៨)។ សាលដីការបស់តុលាការកំពូល 470 Kei-Ji-Han-Rei-Shu 10 (ថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៣១)។

153 *ក្រមព្រហ្មទណ្ឌ ម៉ាឡេស៊ី ឆ្នាំ ១៩៣៦* មាត្រា ៣៤, ៣៥។ រឿងក្តី *Mimi Wong និងមនុស្សម្នាក់ទៀត Another ទល់នឹង រដ្ឋអាជ្ញា*[1972] 2 MLJ ៧៣។ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Neoh Bean Chye* [1975] 1 MLJ 3។

154 *ក្រមព្រហ្មទណ្ឌ ប៉ាគីស្ថាន ឆ្នាំ ១៨៦០* ss. 110, 111។

155 *ក្រមព្រហ្មទណ្ឌ ហ្វីលីពីន ដែលបានកែសម្រួល ឆ្នាំ ១៩៣០* មាត្រា ៨។ រឿងក្តី *The People of the Philippines ទល់នឹង Amadeo Peralta* (1968) GR No. L-19069។ រឿងក្តី *The People of the Philippines ទល់នឹង Carbonel* (1926) GR No. L-24177។ រឿងក្តី *The People of the Philippines ទល់នឹង Leonido Cadag, Antonino Gaton, Dominador Arado និង Bonifacio Cadag* (1961) GR No. L-13830។ រឿងក្តី *The People of the Philippines ទល់នឹង Santos* (1955) GR No. L-7315។ *សូមមើលផងដែរ* រឿងក្តី *The People of the Philippines ទល់នឹង Acaja* (1955) GR No L-7235។ រឿងក្តី *The People of the Philippines ទល់នឹង Buyco* (195) 47 OG (12th Supp.) 11។ រឿងក្តី *The People of the Philippines ទល់នឹង Del Rosario* (1939) 40 OG (3d Supp.) 25។ រឿងក្តី *The People of the Philippines ទល់នឹង Enriquez* (1933) 58 Phil. 536។ រឿងក្តី *The People of the Philippines ទល់នឹង Pardo* (1947) 45 OG 2023។

156 *ក្រមព្រហ្មទណ្ឌ របស់ប៉ូឡូញ ឆ្នាំ ១៩៣២* មាត្រា ១៤(១)។ *ក្រមព្រហ្មទណ្ឌ ឆ្នាំ ១៩៦៩* មាត្រា ៧(១), ១៦។ រឿងក្តីលេខ ៣៧៖ Trial of Hauptsturmführer Amon Leopold Goeth' in *UN War Crimes Reports Polish Law Concerning Trials of War Criminals* (Vol. VII) (London: His Majesty's Stationery Office, 1949)។

ភាពសូវៀត[157] ប្រទេសកូរ៉េខាងត្បូង[158] ប្រទេសថៃ[159] ចក្រភពអង់គ្លេស[160] និងប្រទេសអ៊ុយរូហ្គាយ[161]។ បទប្បញ្ញត្តិនានាដែលចែងថា ការប្រព្រឹត្តឧក្រិដ្ឋកម្មជាក្រុម គឺជាស្ថានទម្ងន់នៅក្នុងការកំណត់ទោស[162] ក៏ត្រូវបានដាក់បញ្ចូលយកមកពិនិត្យមើលឡើងវិញផងដែរ ដោយហេតុថា ប្រទេសទាំងនេះបង្ហាញនូវការទាក់ទងនឹងគោលនយោបាយនៃសហឧក្រិដ្ឋកម្មរួម ទម្រង់ទី III ចំនួនពីរ។ ដើម្បីបង្កើនភាពធ្ងន់ធ្ងរ ឬ ការស្តីបន្ទោសលើអំពើព្រហ្មទណ្ឌនោះ បទប្បញ្ញត្តិដែលចែងអំពីស្ថានទម្ងន់ក្នុងការកំណត់ទោសឆ្លុះបញ្ចាំងនូវវិធីដែលប្រទេសមួយទទួលស្គាល់ និងឆ្លើយតបទៅនឹងទាំង (i) 'គ្រោះថ្នាក់សង្គមដ៏ធ្ងន់ធ្ងរ' នៃឧក្រិដ្ឋកម្មជាក្រុម ឬ សហឧក្រិដ្ឋកម្មរួម (ប្រសិនបើប្រៀបធៀបជាមួយនឹងទម្រង់នៃឧក្រិដ្ឋកម្មដូចគ្នាដែលត្រូវបានប្រព្រឹត្តឡើងដោយបុគ្គល)[163] និង

---

[157] *គោលការណ៍សារវន្តនៃច្បាប់ព្រហ្មទណ្ឌរបស់សហភាពសូវៀត ឆ្នាំ ១៩២៤* មាត្រា ៨។ *ក្រមព្រហ្មទណ្ឌ*សាធារណរដ្ឋសហភាពសូវៀត *ឆ្នាំ១៩៦០* មាត្រា ៣, ៨, ៩, ១៧, ៧៧, ៩១, ១០២។ F. J. Ferdinand Joseph Maria Feldbrugge, Gerard Pieter Van den Berg and William Bradford Simons (eds), *Encyclopedia of Soviet Law* (The Netherlands, Martinus Nifhoff Publishers, 1985)។ Richard Arens, 'Nuremberg and Group Prosecution' (1951) *Washington University Law Quarterly* 329 ដែលបានដកស្រង់សន្និសីទអន្តរជាតិស្តីពីការជំនុំជម្រះរបស់តុលាការយោធា 7, 135។ Aron Naumovič Trainin, *Hitlerite Responsibility under International Law* (London: Hutchinson & Co, 1944) ត្រង់ 10-11។ Aron Naumovič Trajnin, *Ugolovnaja otvetstvennost gitlerovcev* (Moscow: Juridičeskoe Izdatel'stvo, 1944)។ Kirsten Sellars , ឧក្រិដ្ឋកម្មប្រឆាំងនឹងសន្តិភាព និងច្បាប់អន្តរជាតិ (ញ៉ូយ៉ក សាកលវិទ្យាល័យCambridge University, 2013) ត្រង់ 55។ Valentyna Polunina, 'Soviet War Crimes trials policy in Far East and the contribution towards international law: Aron Trainin's law school and the Trial at Khabarovsk (1949)' (PhD Thesis, Heidelberg University) ដែលអាចរកមើលបានតាមរយៈគេហទំព័រ http://www.asia-europe.uni-heidelberg.de/en/research/a-governance-administration/a16-trans cultural-justice/projects/valentyna-polunina.html។

[158] *ក្រមព្រហ្មទណ្ឌ កូរ៉េខាងត្បូង ឆ្នាំ ១៩៥៣* មាត្រា ១៥, ៣០, ៣១(១), ១១៤(១), ១១៥, ១១៦, ១៦៤, ២៦៣។ *Kei-Ji-Han-Rei-Shu* 10 (ថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៣១)។ សាលដីការបស់តុលាការកំពូល 98 Do30 (ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ១៩៩៨).

[159] *ក្រមព្រហ្មទណ្ឌ ប្រទេសថៃឡង់ដ៍ ឆ្នាំ ១៩៥៦* ss. 59, 86, 87, 213, 215, 299, 340។

[160] *ច្បាប់ស្តីពីជនសមគំនិត និងអ្នកជម្រុញ ឆ្នាំ ១៨៦១* ss. 8។ រឿងក្តី *R ទល់នឹង Anderson និង Morris* (1966) 2 QB 110។ រឿងក្តី *R ទល់នឹង Betts និង Ridley* (1930) 29 Cox CC 259។ រឿងក្តី *R ទល់នឹង Smith* (1963) 3 All E.R. 597.602។ រឿងក្តី *R ទល់នឹង Swindall និង Osborne* (1846) 2 Car. *និង* K. 230។

[161] *ក្រមព្រហ្មទណ្ឌអ៊ុយរ៉ាហ្គាយ ឆ្នាំ១៩៣៣* មាត្រា ៦១, ៦៣, ៦៥។

[162] សូមមើលប្រទេសអូទ្រីស ប្រទេសក្រិច និងសភាពសូវៀត។

[163] សូមមើលផងដែរ See also Lord Justice Steyn in the House of Lords for England and Wales cited in House of Commons, Justice Committee, *Joint Enterprise: Eleventh Report of Session 2010-12: វ៉ុល ១* ត្រង់លេខយោងជើងទំព័រ ២.៤.៥ ('[បទ]ពិសោធន៍បានបង្ហាញថា សហឧក្រិដ្ឋកម្មរួមនឹងនាំឲ្យមានការប្រព្រឹត្តបទល្មើសធំៗរួចជាស្រេច') ហើយ ('បុគ្គលដែលប្រព្រឹត្តអំពើព្រហ្មទណ្ឌជាក្រុមត្រូវបានបង្ហាញថាងាយនឹងប្រើអំពើហិង្សាជាងបុគ្គល

ទាំង (ii) វិធីដែលអ្នកចូលរួមនៅក្នុងសហឧក្រិដ្ឋកម្មបែបនេះ ជាធម្មតា បានគេចផុតពីការទទួលខុសត្រូវ[164]។

54. ដោយគាំទ្រចំពោះការអនុវត្តរបស់រដ្ឋអំពីការទទួលខុសត្រូវ JCE III នោះតុលាការ ICTY[165] និង ICTR[166]និមួយៗសុទ្ធតែបានអះអាងអំពីការទទួលយក JCE III ធ្វើជាវិធានច្បាប់ទម្លាប់អន្តរជាតិ។ តុលាការ ICTY បានសម្រេចថាការទទួលខុសត្រូវ JCE III "បានចាក់ឫសយ៉ាងជ្រៅនៅក្នុងច្បាប់ជាតិរបស់រដ្ឋជាច្រើន"[167]។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍ក្នុងរឿងក្តី *Tadić* បានលើកយោងយុត្តាធិការដូចខាងក្រោម ដើម្បីទុកជាការដាក់នូវការទទួលខុសត្រូវយ៉ាងច្បាស់លាស់ នៅក្នុងទម្រង់ពង្រីកដូច្នេះ[168] ដែលប្រទេសទាំងនេះរួមមានកាណាដា[169] អង់គ្លេស និងវេលហ្ស៍[170]

ដែលប្រព្រឹត្តអំពើតែឯង')។ សាស្ត្រាចារ្យ Professor A P Simester, 'The Mental Element in Complicity' (2006) 122 *Law Quarterly Review* 578 ត្រង់ 599 ('សមាគមឧក្រិដ្ឋជនទំនងជាជម្រុញ និងបញ្ឆោះឱ្យកើតមានអំពើព្រហ្មទណ្ឌ')។

164 សាស្ត្រាចារ្យ A P Simester ដកស្រង់ចេញពី House of Commons, Justice Committee, "Joint Enterprise: Eleventh Report of Session 2010-12: លេខ 1" ត្រង់កថាខណ្ឌទិ. 2.4.5.2 ('[សមាគមឧក្រិដ្ឋជន] បង្កការគម្រាមកំហែងដល់សុវត្ថភាពសាធារណៈដែលការចែងហាមឃាត់បទល្មើសព្រហ្មទណ្ឌសាមញ្ញចំពោះតែចារីម្នាក់ៗ មិនអាចដោះស្រាយបញ្ហានេះបាន')។

165 *សូមមើល ឧទាហរណ៍ រដ្ឋអាជ្ញា ទល់នឹង Tadić* សំណុំរឿងលេខ IT-94-1 *សាលក្រម*, អង្គជំនុំជម្រះសាលាដំបូងICTY, សាលដីកាអង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃICTY ចុះថ្ងៃទី15 កក្កដា 1999 ត្រង់កថាខណ្ឌ204, 228, 220។ *រដ្ឋអាជ្ញា ទល់នឹង Krstić* (សំណុំរឿងលេខ IT-98-33-T *សាលក្រម*) ( អង្គជំនុំជម្រះសាលាដំបូង ICTY, , ២ សីហា ២០០១ ត្រង់កថាខណ្ឌ610-614)។ *រដ្ឋអាជ្ញា ទល់នឹង Stakić* សំណុំរឿងលេខ IT-97-24 *(សាលក្រម*អង្គជំនុំជម្រះសាលាដំបូងICTY, , ៣១ កក្កដា ២០០៣ ត្រង់កថាខណ្ឌ436)។ *រដ្ឋអាជ្ញា ទល់នឹង Brđanin (*សំណុំរឿងលេខ IT-99-36-T *សេចក្តីសម្រេចលើសំណើសុំដោះលែងអនុលោមតាមវិធាន៩៨ស្ទួន)* អង្គជំនុំជម្រះសាលាដំបូង ICTY, , ២៨ វិច្ឆិកា ២០០៣)។ *រដ្ឋអាជ្ញា ទល់នឹង Kvočka* និងគូកន, សំណុំរឿងលេខ IT-98-30/1-A *(*សាលដីកាសាលាឧទ្ធរណ៍*)* ( អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ICTY, , ២៨ កុម្ភៈ ២០០៥ ត្រង់កថាខណ្ឌ83)។ *រដ្ឋអាជ្ញា ទល់នឹង Popovic* និងគូកន, *(*សំណុំរឿងលេខ IT-05-88*សាលក្រម* អង្គជំនុំជម្រះសាលាដំបូង ICTY, ១០ មិថុនា ២០១០ ត្រង់កថាខណ្ឌ1021, 1030-1032)។

166 សូមមើល ឧទាហរណ៍ រដ្ឋអាជ្ញា ទល់នឹង Ntakirutimana និង Ntakirutimanaសំណុំរឿងលេខ ICTR-96-10 និង ICTR-96-17 (សាលដីកាសាលាឧទ្ធរណ៍) (ICTR, អង្គជំនុំជម្រះសាលាឧទ្ធរណ៍) ១៣ ធ្នូ ២០០៤ ត្រង់កថាខណ្ឌ465-468); រដ្ឋអាជ្ញា ទល់នឹង Karemera និងគូកន ,សំណុំរឿងលេខ ICTR-98-44 សាលក្រមនៃអង្គជំនុំជម្រះ ICTR២ កុម្ភៈ ២០១២ ត្រង់កថាខណ្ឌ75 1476-1477។រដ្ឋអាជ្ញា និង *Vasiljević* សំណុំរឿងលេខ IT-98-32 សាលដីកា (អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ICTY) ថ្ងៃទី24 កុម្ភៈ 2004 ត្រង់កថាខណ្ឌ99។

167 *រដ្ឋអាជ្ញា ទល់នឹង Tadić*, សំណុំរឿងៈ IT-94-1-A (អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY) ១១ វិច្ឆិកា ១៩៩៩ ត្រង់កថាខណ្ឌ ២២៤។

168 សូមកត់សំគាល់ថា ប្រទេសទាំងឡាយដែលតុលាការ ICTY បានលើកយោងតែសម្ភារៈក្រោយឆ្នាំ១៩៧៥ មិនបានរាប់បញ្ចូលទេ។

បារាំង[171] អ៊ីតាលី[172] សហរដ្ឋអាមេរិក[173] និងហ្សាមបៀ[174]។ ជាសំខាន់ ទាក់ទិននឹងប្រទេសហ្សាមបៀនេះ មានការកត់សំគាល់ថា ច្បាប់របស់បណ្តាប្រទេសនៃរដ្ឋដូចខាងក្រោមនេះ គឺ*ដូចគ្នាបេះបិទ* ទៅនឹងច្បាប់របស់ហ្សាមបៀដែរ ដែលបានសម្រេចដោយអង្គជំនុំជម្រះសាលាឧទ្ធរណ៍ក្នុងរឿងក្តី *Tadić* ទុកដូចជាការឆ្លុះបញ្ចាំងមួយដែលគ្មានការមន្ទិលសង្ស័យអំពី JCE III ប្រទេសទាំងនោះ រួមមាន Bermuda, Botswana, Fiji, Kenya, Malawi, Nigeria, Seychelles, Tanzania និង Uganda[175]។

55. សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា មិនមានភស្តុតាងគ្រប់គ្រាន់ឲ្យត្រូវទៅនឹងការអនុវត្តនៅតាមប្រទេសនានា ដើម្បីបង្កើតអត្ថិភាពនៃ JCE III ជាគោលការណ៍ច្បាប់ទូទៅមួយ (ដោយពុំចាំបាច់ពិចារណាលើច្បាប់ទំនៀមទម្លាប់អន្តរជាតិ *ខ្លួនវាផ្ទាល់*) គឺមានមូលដ្ឋាននៅលើការវិភាគមួយដែលត្រូវបានកម្រិតជ្រុលទៅលើវិសាលភាព និងជម្រៅខ្លឹមសារ។ ទីមួយ ដូចដែលបានបង្ហាញនៅខាងលើ និងដូចដែលបានទទួលស្គាល់ដោយអង្គជំនុំជម្រះសាលាឧទ្ធរណ៍ ក្នុងករណីរបស់ *Tadić* ស្រាប់ហើយថា ការវិភាគច្បាប់ក្នុងស្រុកនៅប្រទេសអង់គ្លេស និងវ៉េលស៍, សហរដ្ឋអាមេរិក និងបារាំង ជាការពិតបានគាំទ្រសេចក្តីអះអាងដែលថាការទទួលខុសត្រូវជា JCE III គឺ

---

169 រដ្ឋអាជ្ញា និង *Tadić* សំណុំរឿងលេខ IT-94-1 សាលដីកា (ICTY អង្គជំនុំជម្រះសាលាឧទ្ធរណ៍) ថ្ងៃទី១៥ កក្កដា ១៩៩៩ ត្រង់លេខសម្គាល់ជើងទំព័រ១៦ លេខយោងជើងទំព័រ២៨៨។

170 រដ្ឋអាជ្ញា និង *Tadić* សំណុំរឿងលេខ IT-94-1 សាលដីកា (ICTY អង្គជំនុំជម្រះសាលាឧទ្ធរណ៍) ថ្ងៃទី១៥ កក្កដា ១៩៩៩ ត្រង់កំណត់សំគាល់ជើងទំព័រ ២៨៧។

171 រដ្ឋអាជ្ញា និង *Tadić* សំណុំរឿងលេខ IT-94-1 សាលដីកា (ICTY អង្គជំនុំជម្រះសាលាឧទ្ធរណ៍) ថ្ងៃទី១៥ កក្កដា ១៩៩៩ កំណត់សំគាល់ជើងទំព័រ ២៨៥។

172 រដ្ឋអាជ្ញា និង *Tadić* សំណុំរឿងលេខ IT-94-1 សាលដីកា (ICTY អង្គជំនុំជម្រះសាលាឧទ្ធរណ៍) ថ្ងៃទី១៥ កក្កដា ១៩៩៩ កំណត់សំគាល់ជើងទំព័រ ២៨៦។

173 រដ្ឋអាជ្ញា និង *Tadić* សំណុំរឿងលេខ IT-94-1 សាលដីកា (ICTY អង្គជំនុំជម្រះសាលាឧទ្ធរណ៍) ថ្ងៃទី១៥ កក្កដា ១៩៩៩ ត្រង់កំណត់សំគាល់ជើងទំព័រ ២៨៩។

174 រដ្ឋអាជ្ញា និង *Tadić* សំណុំរឿងលេខ IT-94-1 សាលដីកា (ICTY អង្គជំនុំជម្រះសាលាឧទ្ធរណ៍) ថ្ងៃទី១៥ កក្កដា ១៩៩៩ ត្រង់កំណត់សំគាល់ជើងទំព័រ ២៩១។

175 *ច្បាប់ព្រហ្មទណ្ឌរបស់ប័រមូដាឆ្នាំ១៩៧០* (Bermuda *Penal Code Criminal Code Act 1970),* s. 28។ *ក្រមព្រហ្មទណ្ឌរបស់បុតស្វាណា ឆ្នាំ១៩៦៤* (Botswana *Penal Code) 1964 s.22*។ *ក្រមព្រហ្មទណ្ឌរបស់ហ្វីជី ទសវត្សរ៍១៩៧០* (Figi *Penal Code 1970*s) 22។ *ក្រមព្រហ្មទណ្ឌរបស់កេនយ៉ា ឆ្នាំ១៩៣០* (Kenya *Penal Code 1930),* s. 21។ *ក្រមព្រហ្មទណ្ឌរបស់ម៉ាឡាវី ឆ្នាំ១៩៣០* (Malawi *Penal Code 1930),* s. 22។ *ច្បាប់ក្រមព្រហ្មទណ្ឌរបស់នីហ្សេរីយ៉ា ឆ្នាំ១៩១៦* (Nigeria P*enal Code Act 1916),* s. 8។ *ក្រមព្រហ្មទណ្ឌរបស់សេសែល ឆ្នាំ១៩៥៥* (Seychelles *Penal Code 1955),* s. 23។ *ក្រមព្រហ្មទណ្ឌរបស់តាន់ហ្សានៀ ឆ្នាំ១៩៤៥* (Tanzania *Penal Code 1945),* s. 23។ *ច្បាប់ក្រមព្រហ្មទណ្ឌរបស់អ៊ូហ្គាន់ដា ឆ្នាំ១៩៥០* (Uganda *Penal Code Act 1950),* s. 20។

ជាផ្នែកមួយនៃច្បាប់ព្រហ្មទណ្ឌរបស់ខ្លួន នៅមុនឆ្នាំ១៩៧៥[176]។ បើអង្គជំនុំជម្រះសាលាដំបូង រ៉ាប់រងទទួលធ្វើការពិនិត្យឡើងវិញមួយដែលទូលំទូលាយលើនីតិកម្ម និងករណីយុត្តិសាស្ត្ររបស់ប្រទេសទាំងបួនដែលបានវិភាគរួចហើយនោះ អង្គជំនុំជម្រះសាលាដំបូងមុខជានឹងរកឃើញនូវបទប្បញ្ញត្តិនានា និងយុត្តិសាស្ត្រដែលគាំទ្រដល់ការទទួលខុសត្រូវជាបុគ្គលចំពោះឧក្រិដ្ឋកម្មនានាដែលមិនមានចេតនាប្រព្រឹត្តទេ ក៏ប៉ុន្តែជាឧក្រិដ្ឋកម្មដែលអាចប្រមាណបានយ៉ាងសមហេតុសមផលនៅក្នុងបរិបទនៃឧក្រិដ្ឋកម្មទាំងឡាយដែលត្រូវបានប្រព្រឹត្តឡើងជាផ្នែកនៃក្រុមមួយ។

56. ការវិភាគរបស់អង្គជំនុំជម្រះសាលាដំបូងចំពោះប្រទេសហូឡង់ គឺពុំបានពិចារណាទៅលើវាក្យខណ្ឌ ៤៧(១)នៃក្រមព្រហ្មទណ្ឌ ដែលកំណត់ពីការទទួលខុសត្រូវចំពោះការចូលរួមប្រព្រឹត្តរួមគ្នា និងទៅលើមាត្រា៣០០ ដល់៣០២ និង៣១២ ដែលមាត្រាទាំងនេះ បានទទួលស្គាល់ពីបំណងឧក្រិដ្ឋ ដែលរួមមានទាំង *ការយល់ដឹងនូវលទ្ធផលដែលទំនងជាកើតពីអំពើណាមួយ* ។ ដូច្នេះ ការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មរបស់ក្រុមដែលស្ថិតនៅក្រៅផែនការព្រហ្មទណ្ឌ ប៉ុន្តែជាអំពើដែលគេអាចព្យាករបាន (JCE III) ត្រូវបានគាំទ្រនៅក្នុងច្បាប់ប្រទេសហូឡង់មុនឆ្នាំ១៩៧៥។ នៅក្នុងសេចក្តីសន្និដ្ឋានបញ្ចប់ដែលថា ប្រទេសអាល្លឺម៉ង់មិនគាំទ្រ JCE III នោះ អង្គជំនុំជម្រះសាលាដំបូងបានពឹងផ្អែកទៅលើសំណុំរឿងមួយរបស់តុលាការកំពូលមានតាំងពីឆ្នាំ១៩១១[177] ប៉ុន្តែករណីយុត្តិសាស្ត្ររបស់អាល្លឺម៉ង់ជាបន្តបន្ទាប់បង្ហាញថា ការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដោយចេតនារបស់ក្រុម ប៉ុន្តែអាចព្យាករបាន គឺជាឧក្រិដ្ឋកម្មដែលមានបញ្ញត្តិនៅអាល្លឺម៉ង់ យ៉ាងហោចណាស់គិតត្រឹមឆ្នាំ៩៦៧

---

[176] (ចក្រភពអង់គ្លេស សូមអានកំណត់សម្គាល់ជើងទំព័រ លេខ160) *R ទល់នឹង Anderson និង Morris និង*(ឆ្នាំ1966) 2 QB 110។*R ទល់នឹង Betts និង Ridley* (ឆ្នាំ1930) 29 Cox CC 259។*R ទល់នឹង Smith* (ឆ្នាំ1963) 3 All ER 597។*R ទល់នឹង Swindall និង Osborne* (ឆ្នាំ1846) 2 Car. & K. 230។ (សហរដ្ឋអាមេរិក សូមអានកំណត់សម្គាល់ជើងទំព័រ លេខ140) ក្រមព្រហ្មទណ្ឌនៃរដ្ឋ Kansas, ឆ្នាំ1969, s. 21-3205។ក្រមព្រហ្មទណ្ឌនៃរដ្ឋ Minnesota, ឆ្នាំ1963, s. 609.05។ក្រមព្រហ្មទណ្ឌនៃរដ្ឋ Texas, ឆ្នាំ1973, s. 7.02(b)។ ក្រមព្រហ្មទណ្ឌនៃ Wisconsin, ឆ្នាំ1955, s. 939.05(2)(c)។ *Pinkerton ទល់នឹង សហរដ្ឋអាមេរិក* 328 US 640 (ឆ្នាំ1946)។ *សហរដ្ឋអាមេរិក ទល់នឹង Decker* 543 F.2d 1102 (ឆ្នាំ1976)។ សូមអានផងដែរ *Park ទល់នឹង Huff* 506 F.2d 849 (ឆ្នាំ1975) ត្រង់កថាខណ្ឌ 855។ *រដ្ឋ ទល់នឹង Moore* 580 SW.2d 747 (ឆ្នាំ1979) ត្រង់កថាខណ្ឌ 752។ *រដ្ឋ ទល់នឹង Stein* 70 NJ 369 (ឆ្នាំ1976)។ (ប្រទេសបារាំង សូមអានកំណត់សម្គាល់ជើងទំព័រ លេខ124) ក្រមព្រហ្មទណ្ឌនៃប្រទេសបារាំង, ឆ្នាំ1810, មាត្រា 97, 265, 266, 313។ *ការជំនុំជម្រះក្តីលើករណីរបស់ Gustav Becker, Wilhelm Weber និងអ្នក១៨នាក់ ផ្សេងទៀត* (តុលាការយោធា អចិន្ត្រៃយ៍ នៅទីក្រុង Lyon, បិទបញ្ចប់នៅថ្ងៃទី17 កក្កដា 1947), UNWCC, វ៉ុលទីVII ត្រង់ទំព័រ67។ ព្រឹត្តិប័ត្រសាលដីកាព្រហ្មទណ្ឌនៃតុលាការកំពូលស្តីពីការ ឆ្នាំ1947, លេខ 270 (31 ធ្នូ 1947); តុលាការកំពូល, សភាព្រហ្មទណ្ឌ, 7 ធ្នូ 1966។ តុលាការកំពូល សភាព្រហ្មទណ្ឌ 29 ធ្នូ 1970។ តុលាការកំពូល សភាព្រហ្មទណ្ឌ 15 មិថុនា 1960 (s.1861 I 398) តុលាការកំពូល សភាព្រហ្មទណ្ឌ 9 មិថុនា 1948។

[177] សាលក្រមរបស់តុលាការយុត្តិអធិរាជ, RGSt 44. 321 (២ កម្ភៈ ១៩១១)។

ដែរ[178]។ ស្រដៀងគ្នានេះ បើសិនជាអង្គជំនុំជម្រះសាលាដំបូងបានពិនិត្យមើលនីតិបញ្ញត្តិរបស់ U.S.S.R ក្នុងន័យទូលំទូលាយមួយ ម្ល៉េះសមអង្គជំនុំជម្រះបានទទួលស្គាល់នូវឧក្រិដ្ឋកម្មជាក់លាក់ និងទូលំទូលាយចំពោះអំពើប្រព្រឹត្តដោយគ្មានចេតនា ប៉ុន្តែអាចព្យាករបាន[179]។ ធ្វើដូច្នេះ វាក៏នឹងនាំទៅដល់ការបកស្រាយមួយដែលមានលក្ខណៈប្រាកដនិយមជាងនេះថា ច្បាប់សូវៀតពិតជាគាំទ្រមែន ឬយ៉ាងហោចណាស់ បើតាមគោលការណ៍ ក៏វាស៊ីសង្វាក់គ្នានឹងការទទួលខុសត្រូវ JCE III ដែរ។ ចំណែកច្បាប់កម្ពុជាវិញ ទោះមិនបញ្ជាក់ច្បាស់ពីការទទួលយក JCE III ក៏ដោយ ប៉ុន្តែបានទទួលស្គាល់ទាំងការដាក់ទោសចំពោះការទទួលខុសត្រូវឧក្រិដ្ឋកម្មជាក្រុម និងការទទួលខុសត្រូវដែលពង្រីកហួសពីចេតនាផ្ទាល់[180]។ អាស្រ័យហេតុនេះ ការវិភាគមួយរបស់អង្គជំនុំជម្រះសាលាដំបូងដែលមានលក្ខណៈតឹងរឹងជាងនេះ លើការត្រួតពិនិត្យមើលឡើងវិញរបស់ប្រទេសទាំងប្រាំពីរ មិនគាំទ្រការសន្និដ្ឋានចុងក្រោយរបស់ខ្លួនឡើយដែលថា "ការអនុវត្តជាក់ស្តែងមានភាពផ្ទុយគ្នាយ៉ាងខ្លាំង" ចំពោះការអនុវត្ត JCE III នោះ។

---

[178] សេចក្តីសម្រេចរបស់តុលាការយុត្តិធម៌សហពន្ធន៍អាល្លឺម៉ង់, Germany, BGH 17.33 (1967)។ សេចក្តីសម្រេចរបស់តុលាការយុត្តិធម៌សហពន្ធន៍អាល្លឺម៉ង់, BGH, 11.05 (1971) - VI ZR 211/69។ *សហរដ្ឋអាមេរិក ទល់នឹង Goebell, និងគូកន.*, បណ្ណសាររបស់សហរដ្ឋអាមេរិក, ការបោះពុម្ពផ្សាយលេខ M1103, កំណត់ហេតុនៃការជំនុំជម្រះក្តីឧក្រិដ្ឋកម្មសង្គ្រាមសហរដ្ឋអាមេរិក, ៦ កុម្ភៈ - ២១ មីនា ១៩៤៦ ("*រឿងក្តី Borkum Island*")។ *របាយការណ៍ច្បាប់អំពីការជំនុំជម្រះក្តីឧក្រិដ្ឋជនសង្គ្រាម,* វ៉ុល១, គម្រោងទូទៅនៃកិច្ចដំណើរការនីតិវិធី និងកំណត់ត្រាផ្សេងៗ (តុលាការយោធាអង់គ្លេសដើម្បីកាត់សេចក្តីឧក្រិដ្ឋជនសង្គ្រាម, Essen) 1947 ("រឿងក្តី Essen Lynching") ត្រង់ទំព័រ 89, 91។ *ការកាត់សេចក្តីឧក្រិដ្ឋជនសង្គ្រាមនៅចំពោះមុខតុលាការយោធាអន្តរជាតិ,* Nuremberg, ២២ សីហា - ១ តុលា ១៩៤៦, UNWCC, វ៉ុល១, ("រឿងក្តី Sauckel"); ត្រង់ទំព័រ 461, 515 *ការកាត់សេចក្តីឧក្រិដ្ឋជនសង្គ្រាមសំខាន់ៗនៅចំពោះមុខតុលាការយោធាអន្តរជាតិ,* វ៉ុល១, ១៤ វិច្ឆិកា - ១ តុលា ១៩៤៦ ("រឿងក្តី Speer") ត្រង់ទំព័រ 331, 332។

[179] គោលការណ៍ជាមូលដ្ឋាននៃច្បាប់ព្រហ្មទណ្ឌរបស់ U.S.S.R., ១៩២៤, មាត្រា៨។ ក្រមព្រហ្មទណ្ឌរបស់ U.S.S.R., ១៩៦០, មាត្រា៣, ៨, ៩។ Ferdinand Joseph Maria Feldbrugge, Gerard Pieter Van den Berg និង William Bradford Simons (eds.), "សមោធាននៃច្បាប់សូវៀត" (Martinus Nifhoff Publishers, 1985) ត្រង់ទំព័រ 2, 3, 78; Richard Arens, "Nuremberg និងការចោទប្រកាន់ជាក្រុម" (1951) ការចុះផ្សាយច្បាប់ប្រចាំត្រីមាសនៃសកលវិទ្យាល័យលេខ៣២៩ (Washington University Law Quarterly 329) ត្រង់ទំព័រ 345, កំណត់សំគាល់ជើងទំព័រ៦៨។ John C. Hogan, "យុត្តិធម៌នៅសហភាពសូវៀត: ការកាត់សេចក្តី Beria និងជំនួយការ ចំពោះអំពើក្បត់ជាតិ" (1955) 41 ទនានុប្បវត្តិគណៈមេធាវីសហរដ្ឋអាមេរិក 408 ត្រង់ទំព័រ 477។

[180] ក្រមព្រហ្មទណ្ឌកម្ពុជា, ១៩៥៦, មាត្រា១៤៥ ("មានអ្នកចូលរួមប្រព្រឹត្តច្រើននៅពេលណាមានអ្នកប្រព្រឹត្តចាប់ពីពីរនាក់ឡើងទៅ ដែលបានព្រមព្រៀងគ្នាប្រព្រឹត្តបទល្មើសណាមួយជាសហចារី ឬអ្នកសមគំនិត តាមរយៈការជួយ និងទំនុកបម្រុង"), 231 (ផ្តន្ទាទោស "ដោយគ្មានការបែងចែក" ចំពោះអ្នកចូលរួមប្រព្រឹត្តទាំងអស់នៅក្នុងក្រុមឧក្រិដ្ឋកម្ម មិនថាមានវត្តមាន ឬអត់ក្នុងពេលប្រព្រឹត្តឧក្រិដ្ឋកម្មនោះទេ រួមទាំង "ជនដែលបានដឹកនាំការបះបោ ឬដែលអាចជាអ្នកកាន់មុខតំណែងណាមួយនៅក្នុងក្រុម ឬមុខនាទីណាមួយនៃការបញ្ជា")។ មាត្រា២៣១ អនុវត្តបានយ៉ាងច្បាស់លាស់ចំពោះឧក្រិដ្ឋកម្មទាំងឡាយដូចមានចែងក្នុងមាត្រា២២៥ រួមទាំងការវាយប្រហារដើម្បី "ញុះញង់ឲ្យមានសង្គ្រាមស៊ីវិលតាមរយៈការបំពាក់អាវុធ ឬចំណាយប្រាក់ឲ្យមនុស្សចាប់យកអាវុធដោយខ្លួនឯងប្រឆាំងនឹងគ្នា ឬដើម្បីនាំមកនូវការបំផ្លិចបំផ្លាញ ការសម្លាប់រង្គាល និងការឆក់ប្លន់"។ សូមមើលផងដែរ ក្រមព្រហ្មទណ្ឌកម្ពុជា, ១៩៥៦, មាត្រា៥០៥។

57. ដោយសារការបកស្រាយបំភ្លឺលើការអនុវត្តនៅតាមបណ្តាប្រទេស ដែលជាក់ស្តែងគឺមានលក្ខណៈដូចគ្នា និងជាតំណាង ព្រមទាំងមានលក្ខណៈទូលំទូលាយគ្រប់គ្រាន់ នោះវាទំនងជាថា ចាប់ពីឆ្នាំ ១៩៧៥ មក ការទទួលខុសត្រូវខាងព្រហ្មទណ្ឌជាបុគ្គលចំពោះឧក្រិដ្ឋកម្មនានា ដែលមិនមានចេតនាប្រព្រឹត្តទេ ក៏ប៉ុន្តែជាឧក្រិដ្ឋកម្មដែលអាចប្រមាណបានយ៉ាងសមហេតុសមផល ដែលកើតចេញមកពីការព្រមព្រៀងគ្នា ឬជាសហកម្ម ប្រព្រឹត្តបទឧក្រិដ្ឋរួម ត្រូវបានបង្កើតឡើងយ៉ាងរឹងមាំនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ។ អាស្រ័យហេតុដូច្នេះ សហព្រះរាជអាជ្ញាជូនសេចក្តីសន្និដ្ឋានថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសនៅក្នុងការរកឃើញថាពុំមានភស្តុតាង ដែលត្រូវគ្នាទៅនឹងការអនុវត្តនៅតាមបណ្តាប្រទេសឲ្យបានគ្រប់គ្រាន់ ហើយតាមគោលការណ៍ទស្សនៈផ្លូវច្បាប់ ដែលថាការបង្កើតជា JCE III មានអត្ថិភាពជាផ្នែកនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅចន្លោះឆ្នាំ ១៩៧៥ និង១៩៧៩[181]។

## V. សេចក្តីសន្និដ្ឋាន និងដំណោះស្រាយដែលបានស្នើសុំ

58. សរុបមក សហព្រះរាជអាជ្ញាជូនសេចក្តីសន្និដ្ឋានថា ផ្អែកលើមូលដ្ឋាននៃសម្អាងហេតុដែលបានលើកឡើងខាងលើ អង្គជំនុំជម្រះសាលាដំបូង (ទី១) មានកំហុសនៅក្នុងការយល់ឃើញ គោលការណ៍គ្មានបទល្មើស គ្មានច្បាប់ចែង រារាំងការអនុវត្តសហឧក្រិដ្ឋកម្មរួមទម្រង់ទី III (ទី២) មានកំហុសក្នុងការយល់ឃើញថា សហឧក្រិដ្ឋកម្មរួមទម្រង់ទី III មិនមែនជាផ្នែកនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិមុនឆ្នាំ១៩៧៥ និង (ទី៣) មានកំហុសក្នុងការបដិសេធមិនពិចារណាលើទម្រង់នៃការទទួលខុសត្រូវក្នុងសំណុំរឿង០០២។ យុត្តិសាស្ត្រនានាពីសង្គ្រាមលោកលើកទីពីរ និងការអនុវត្តប្រកបដោយភាពស៊ីសង្វាក់គ្នានៅតាមប្រទេស បង្កើតបានយ៉ាងរឹងមាំនូវទម្រង់នៃការទទួលខុសត្រូវតាមទម្រង់ពង្រីក សម្រាប់បុគ្គលទាំងឡាយណាដែលចូលរួមដោយចេតនា នៅក្នុងសហឧក្រិដ្ឋកម្មរួម ដោយដាក់ឲ្យទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនានាដែលអាចព្យាករបានពីលទ្ធផល។ បន្ថែមលើនេះ គោលការណ៍ស្តីពី *គ្មានបទល្មើស បើគ្មានច្បាប់ចែង* មិនច្រាន JCE III ចោលជាមុននោះទេ ដោយហេតុថាគោលការណ៍នេះគឺត្រឹមត្រូវហើយ ប្រសិនបើបុគ្គលជាប់ចោទនោះបានទទួលការជូនដំណឹងថាការប្រព្រឹត្តរបស់គាត់គឺជាបទល្មើសព្រហ្មទណ្ឌ។ ដោយសារ អង្គជំនុំជម្រះសាលា

[181] អូស្ត្រាលី អូទ្រីស បឹងក្លាដែស ប៊ែមុដា បូស្តវ៉ាណា កម្ពុជា កាណាដា អេហ្ស៊ីប អេត្យូពី ហ្វីជី បារាំង អាល្លឺម៉ង់ ហ្គាណា ក្រិក ឥណ្ឌា អ៊ីរ៉ាក់ អ៊ីស្រាអែល ជប៉ុន កេនយ៉ា ម៉ាឡាវី ម៉ាឡេស៊ី នូវែលហ្សេឡង់ នីហ្សេរីយ៉ា ប៉ាគីស្ថាន ប៉ាពួហ្គីណេ ហ្វីលីពីន ប៉ូឡូញ សាធារណរដ្ឋសហភាពសូវៀត("U.S.S.R.") សីសែល អាហ្វ្រិកខាងត្បូង កូរ៉េខាងត្បូង សេរីលង្កា តង់ហ្សានីយ៉ា ថៃឡង់ដ៍ អ៊ូហ្គាន់ដា ចក្រភពអង់គ្លេស សហរដ្ឋអាមេរិក អ៊ូរូហ្គាយ សាម៉ៅខាងលិច និង ហ្សំប៊ី។

ដំបូងបានរកឃើញថា ទម្រង់ជាមូលដ្ឋាននៃការទទួលខុសត្រូវសហឧក្រិដ្ឋកម្មរួម JCE I ជាផ្នែកនៃច្បាប់ទម្លាប់អន្តរជាតិ ហើយជាអ្វីដែលគេអាចព្យាករបាន និងអាចរកបាន ដោយជនជាប់ចោទនៅ អ.វ.ត.ក ដូច្នេះវាមិនមានតក្កវិជ្ជាទេចំពោះការរកឃើញថា ការដាក់ឲ្យមានការទទួលខុសត្រូវចំពោះ JCE III ជាការរំលោភគោលការណ៍ *គ្មានបទល្មើសបើគ្មានច្បាប់ចែង* នោះ។ អំពើជាលក្ខខណ្ឌតម្រូវសម្រាប់ការទួលខុសត្រូវ JCE III គឺកើតចេញពីចេតនា និងការរួមចំណែកមានលក្ខណៈសំខាន់ទៅក្នុងសហឧក្រិដ្ឋកម្មរួម ដើម្បីប្រព្រឹត្តឧក្រិដ្ឋកម្មណាមួយដែលស្ថិតនៅក្រោមយុត្តាធិការរបស់តុលាការ - ដូចគ្នានឹងអំពើជាលក្ខខណ្ឌតម្រូវសម្រាប់ការដាក់ឲ្យទទួលខុសត្រូវនៅក្រោម JCE I ដែរ។ ជនណាដែលបានចូលរួមចំណែកដូច្នេះ ដោយមានបំណងជម្រុញឲ្យមានឧក្រិដ្ឋកម្មមួយដែលស្ថិតនៅក្រោមយុត្តាធិការរបស់ អ.វ.ត.ក មិនអាចនិយាយថា ខ្លួនមិនដឹងពីឧក្រិដ្ឋភាពនៃអំពើរបស់ខ្លួននោះឡើយ។

59. ដូចមូលហេតុរៀបរាប់ខាងលើ សហព្រះរាជអាជ្ញាស្នើឲ្យអង្គជំនុំជម្រះតុលាការកំពូល

ក. ទទួលយកបណ្តឹងសាទុក្ខនេះ និង

ខ. ប្រកាសពីការអនុវត្តទម្រង់នៃការទទួលខុសត្រូវសហឧក្រិដ្ឋកម្មរួមទីបី (ឬ“ទម្រង់ពង្រីក”) នៃទម្រង់នៃការទទួលខុសត្រូវសហឧក្រិដ្ឋកម្មរួម នៅចំពោះមុខ អ.វ.ត.ក៕

| **កាលបរិច្ឆេទ** | **ឈ្មោះ** | **ទីកន្លែង** | **ហត្ថលេខា** |
|---|---|---|---|
| ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៤ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | [signature] |
| | **លោក Nicholas KOUMJIAN**<br>សហព្រះរាជអាជ្ញា | | [signature] |